# របាយការណ៍
# ស្តីពី
## អំពើហិង្សាលើយេនឌ័រ-លើស្ត្រីជនជាតិដើមភាគតិច
## នៅក្នុងខេត្តចំនួនបីនៃប្រទេសកម្ពុជា ឆ្នាំ២០២០



សហការរៀបចំដោយ :

បោះពុម្ពឆ្នាំ២០២២

## សេចក្តីថ្លែងអំណរគុណ

របាយការណ៍បានរៀបចំឡើងដោយមានការគាំទ្រជំនួយថវិកា និងបច្ចេកទេសពីសំណាក់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា (OHCHR)។

សមាគមស្រ្តីជនជាតិដើមភាគតិចកម្ពុជា(CIWA) ដែលពីមុនត្រូវបានគេស្គាល់ថាជាក្រុមការងារស្រ្តីជនជាតិដើមភាពតិច មុនពេលប្តូរឈ្មោះនៅក្នុងឆ្នាំ២០២១ ដែលបានស្ម័គ្រចិត្តចុះសម្ភាសន៍ដោយផ្ទាល់នៅក្នុងខេត្តមណ្ឌលគិរី រតនគិរី និង ស្ទឹងត្រែង។ CIWA សូមថ្លែងអំណរគុណដល់អាជ្ញាធរថ្នាក់ខេត្ត អាជ្ញាធរប្រចាំថ្នាក់មូលដ្ឋាន និង មេដឹកនាំប្រពៃណីជនជាតិដើមភាគតិចនៅក្នុងខេត្តមណ្ឌលគិរី រតនគិរី និង ស្ទឹងត្រែង ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមផ្តល់បទសម្ភាសសម្រាប់កិច្ចការស្រាវជ្រាវមួយនេះ។ ក្រុមការងារស្រាវជ្រាវសូមសម្តែងនូវការដឹងគុណជាពិសេសដល់ជនរងគ្រោះ និងសមាជិកក្រុមគ្រួសារជនរងគ្រោះទាំងអស់គ្នាសម្រាប់សេចក្តីក្លាហាន និងឆន្ទៈខ្ពស់ក្នុងការចែករំលែកនូវបទពិសោធន៍របស់ពួកគេ។

CIWA សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះ កញ្ញា ម៉ាយ៉ា ឌីអ័រណ្ឌ ទីប្រឹក្សាឯករាជ្យ និង កញ្ញា បុណ្យ រចនា នាយិកានៃអង្គការក្លាហាន ដែលបានសរសេរសេចក្តីព្រាងបឋមនៃរបាយការណ៍នេះ។

របាយការណ៍នេះផលិតឡើងក្រោមជំនួយថវិការបស់ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា(OHCHR) ប្រទេសស៊ុយអែត និងសហភាពអឺរ៉ុប។ ខ្លឹមសារនៃរបាយការណ៍នេះគឺជាទទួលខុសត្រូវទាំងស្រុងរបស់ សមាគមស្រ្តីជនជាតិដើមភាគតិចកម្ពុជា(CIWA) និងមិនឆ្លុះបញ្ចាំងពីទស្សនៈឬការយល់ឃើញណាមួយ របស់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា(OHCHR) ប្រទេសស៊ុយអែត និងសហភាពអឺរ៉ុបឡើយ ។

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

សហភាពអឺរ៉ុប

ស៊ុយអែត
Sverige

**មាតិកា** ទំព័រ


សេចក្តីសង្ខេប ៤

សេចក្តីផ្តើម ៩

១.១. បរិបទ ៩

១.២. គោលបំណង ១១

១.៣. វិធីសាស្រ្ត ១១

វិធីសាស្រ្តការពារ ១១

បញ្ហាប្រឈមនានានៅក្នុងគម្រោងស្រាវជ្រាវ ១៣

២. ក្របខ័ណ្ឌច្បាប់ គោលនយោបាយនិងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ១៤

២.១. និយមន័យនៃអំពើហិង្សាផ្អែកលើយេនឌ័រ ១៥

២.២. ច្បាប់សិទ្ធិមនុស្សអន្តរជាតិពាក់ព័ន្ធនឹងស្ត្រីជនជាតិដើមនៅកម្ពុជា ១៥

២.៣. ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងស្ត្រីជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា ១៥

ច្បាប់ជាតិ ១៥

គោលនយោបាយជាតិ ១៧

៣. ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ១៨

៣.១. ប្រព័ន្ធយុត្តិធម៌ផ្លូវការ ១៨

៣.២. ប្រព័ន្ធយុត្តិធម៌បែបប្រពៃណីនិងយន្តការដោះស្រាយវិវាទ ១៩

៤.របកគំហើញ និងការវិភាគ ២៣

៤.១. ទិដ្ឋភាពទូទៅនៃអ្នកផ្តល់បទសម្ភាសនិងករណីដែលបានរាយការណ៍ ២៣

៤.២. ទំនោរ អត្រាប្រេវ៉ាឡង់និងស្ថានភាពអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងស្ត្រីជនជាតិដើមភាគតិច ២៦

ករណីបានរាយការណ៍ទៅអាជ្ញាធរ ២៦

តើអ្នកណាជាជនរងគ្រោះ/ជនរងគ្រោះរស់រានដ្ឋជីវិត? ២៩

តើអ្នកណាជាជនល្មើស? ២៩

៤.៣. ការបំពានយេនឌ័រមិនត្រឹមត្រូវលើមូលហេតុដើមនៃអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងស្ត្រីជនជាតិដើមភាគតិច ៣១

៤.៤. អាពាហ៍ពិពាហ៍កុមារនៅក្នុងសហគមន៍ជនជាតិដើមភាគតិច ៣៥

៤.៥. ការមាក់ងាយនិងការលំបាកក្នុងការរស់រានដ្ឋជីវិតពីអំពើហិង្សាផ្អែកលើយេនឌ័រ ៣៧

៤.៦. ការទទួលបានយុត្តិធម៌ដោយជនរងគ្រោះ ជនរងគ្រោះរស់រានដ្ឋជីវិត ៣៧

ប្រព័ន្ធយុត្តិធម៌ផ្លូវការ ៣៩
ការចាប់ខ្លួននិងការផ្តន្ទាទោសជនសង្ស័យដែលចោទប្រកាន់ ៤០
ការដាក់ពាក្យបណ្តឹង ៤២
ស្ថានភាពករណីចាប់រំលោភ ៤៣
វិធីសាស្ត្រដោះស្រាយវិវាទបែបប្រពៃណី ៤៧
៤.៧. លទ្ធភាពទទួលបាននិងការឆ្លើយតបនៃយន្តកាការពារជនរងគ្រោះរស់រានជីវិត ៥០
សេវាសុខាភិបាល រួមទាំងការប្រឹក្សាយោបល់ផ្នែកចិត្តសង្គម ៥២
ជំនួយហិរញ្ញវត្ថុនិង សម្ភារៈ ៥៤
៤.៨. កិច្ចខិតខំប្រឹងប្រែងការពារនិងឧបសគ្គរារាំងការខិតខំទាំងនេះ ៥៤
៥. សេចក្តីសន្និដ្ឋាននិងអនុសាសន៍ ៥៨
៥.១. សេចក្តីសន្និដ្ឋាន ៥៨
៥.១.១. ទំនោរនិងស្ថានភាពអំពើហិង្សាផ្នែកលើយេនឌ័រប្រឆាំងស្ត្រីជនជាតិដើមភាគតិច ៥៨
៥.១.២. ការបំពានយេនឌ័រមិនត្រឹមត្រូវលើដើមហេតុនៃអំពើហិង្សាលើយេនឌ័រ លើស្ត្រីជនជាតិដើមភាគតិច ៥៩
៥.១.៣. ការមាក់ងាយនិងការលំបាកក្នុងការរស់រានមានជីវិតពីអំពើហិង្សាលើយេនឌ័រ ៦០
៥.១.៤. ច្បាប់និងចំណុចខ្វះខាត ៦១
៥.១.៥. ការទទួលបានយុត្តិធម៌ដោយអ្នកនៅរស់រានមានជីវិត ៦២
៥.១.៦. ភាពងាយស្រួលនិងការឆ្លើយតបនៃការគាំទ្រនិងការការពារជនរងគ្រោះ ៦៣
៥.២. អនុសាសន៍ ៦៤
៥.២.១. សកម្មភាពចាំបាច់ដើម្បីដោះស្រាយបុព្វហេតុឬទប់ស្កាត់អំពើហង្សាប្រឆាំងនឹងយេនឌ័រ ៦៥
៥.២.២. សកម្មភាពចាំបាច់ដើម្បីពង្រឹងការឆ្លើយតបចំពោះអំពើហិង្សាលើយេនឌ័រលើស្ត្រី ជនជាតិដើមភាគតិច ៦៨
ឧបសម្ព័ន្ធ ៧២

## សេចក្តីសង្ខេប

ការសិក្សាស្រាវជ្រាវនេះបានសម្រេចធ្វើឡើងក្រោយពេលដែលអង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធ ដែលកំពុងបំពេញបេសកកម្មការងារជាមួយសហគមន៍ជនជាតិដើមភាគតិច បានផ្តល់សេចក្តីរាយការណ៍ពីការកើនឡើងនៃករណីអំពើហិង្សាលើយេនឌ័រប្រឆាំងស្ត្រីជនជាតិដើមភាគតិចជាច្រើន។ ករណីអំពើហិង្សាផ្លូវភេទ រួមទាំងអំពើរំលោភសេពសន្ថវៈ ត្រូវបានរាយការណ៍ថាបានកើតឡើងនៅក្នុងសហគមន៍ ទោះបីជាមិនសូវញឹកញាប់ក៏ដោយ។ ដោយឡែកអាជ្ញាធរមូលដ្ឋានបានរបាយការណ៍ថា អំពើហិង្សាក្នុងគ្រួសារ គឺជាករណីអំពើហិង្សាដែលបានកើតឡើងញឹកញាប់នៅតាមបណ្តាសហគមន៍នៅក្នុងភូមិនានា។ ជនរងគ្រោះរស់រានជីវិត និងក្រុមគ្រួសាររបស់ពួកគេ បានធ្វើសេចក្តីរាយការណ៍ទៅអាជ្ញាធរមូលដ្ឋានពីករណីជាច្រើននៃការរំលោភសេពសន្ថវៈ រួមទាំងអំពើរំលោភសេពសន្ថវៈបង្កឡើងដោយសាច់ញាតិ ការប៉ុនប៉ងរំលោភសេពសន្ថវៈ ការរំលោភសេពសន្ថវៈនិងសម្លាប់ជនរងគ្រោះ និង ករណីការបៀតបៀនផ្លូវភេទផងដែរ។ ទោះបីជាហេតុការណ៍នេះបានកើតឡើងជាបន្តបន្ទាប់ នៅមិនទាន់មានការបង្កើតឡើងនូវប្រព័ន្ធគ្រប់គ្រង និងប្រមូលទិន្នន័យគ្រប់ជ្រុងជ្រោយទាក់ទងនិងអំពើហិង្សាផ្អែកលើយេនឌ័រនៅឡើយទេ ហើយបច្ចុប្បន្ននេះភ្នាក់ងាររដ្ឋនីមួយៗ មានប្រភពព័ត៌មានរៀងខ្លួន។ ដូច្នេះពុំមានការចងក្រងទិន្នន័យ ការបំបែកទិន្នន័យ ទៅតាមជាតិពន្ធុ ឬការចុះក្នុងបញ្ជីគោលទេ។

ការសិក្សាស្រាវជ្រាវបានចង្អុលបង្ហាញថា ដើមចមនៃអំពើហិង្សាផ្អែកលើយេនឌ័រ រួមទាំងអំពើហិង្សាផ្លូវភេទកើតឡើងដោយសារតែអតុល្យភាពនៃទំនាក់ទំនងអំណាចរវាងបុរសនិងស្ត្រី នៅក្នុងវិស័យសាធារណៈ និងវិស័យឯកជនដែលបន្តកើតឡើងដោយសារតែបទដ្ឋានសង្គមដែលមានលក្ខណៈរើសអើង ភាពក្រីក្រ និងប្រព័ន្ធអភិបាលកិច្ចដែលមាក់ងាយស្ត្រីនិងកង្វះនីតិរដ្ឋ។ ភាពក្រីក្រក៏ជាបុព្វហេតុមួយនៅក្នុងប្រទេសកម្ពុជា និងបានរួមចំណែកធ្វើឲ្យបន្តកើតមាននៃអំពើហិង្សាផ្អែកលើយេនឌ័រ។ ទោះយ៉ាងណា ការយល់ដឹងអំពីបុព្វហេតុនិងវិធានការណ៍នានាដើម្បីទប់ស្កាត់អំពើហិង្សាបែបនេះ ហាក់នៅមានកម្រឹតទាបនៅឡើយនៅក្នុងចំណោមអាជ្ញាធរខេត្ត និងអាជ្ញាធរមូលដ្ឋាន។ ទន្ទឹមនេះដែរ ជំនឿទាក់ទងនិងការរើសអើងយេនឌ័រ និងការរើសអើងពូជសាសន៍ក្នុងចំណោមភាគីពាក់ព័ន្ធផ្សេងៗ ហាក់កំពុងតែក្លាយជាឧបសគ្គរារាំងការទប់ស្កាត់ និងដាក់ចេញនូវវិធានការណ៍ឆ្លើយតបដែលមានប្រសិទ្ធភាព។ ដើម្បីទប់ស្កាត់ និងឆ្លើយតបប្រកបដោយប្រសិទ្ធភាពនៅក្នុងករណីអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងស្ត្រីជនជាតិដើមនៅក្នុងប្រទេសកម្ពុជា ភាគីពាក់ព័ន្ធគ្រប់រូបចាំបាច់ណាស់ត្រូវបង្កើនការយល់ដឹងដ៏ត្រឹមត្រូវ និងច្បាស់លាស់អំពីបុព្វហេតុនៃអំពើហិង្សា រួមទាំងលុបបំបាត់នូវជំនឿសន្មត់ដែលរើសអើងប្រឆាំងនឹងស្ត្រីជនជាតិដើមផងដែរ។

ជនរងគ្រោះរស់រានជីវិតពីអំពើហិង្សាផ្អែកលើយេនឌ័រ ត្រូវបានសង្គមមាក់ងាយនិងផាត់ចេញ។ វិធានការទប់ស្កាត់នានាដែលអនុវត្តដោយអាជ្ញាធរ និងដោយជនរងគ្រោះរស់រានជីវិតដោយផ្ទាល់ផងនោះ ហាក់ដូចជាស្តីបន្ទោសជនរងគ្រោះទៅវិញ តួយ៉ាងការស្នើឲ្យស្ត្រីផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគេជាជាងការដាក់

បន្ទុកទៅលើជនល្មើស និងទាមទារឲ្យជនល្មើសទទួលខុសត្រូវចំពោះអំពើរបស់ពួកគេ។ ដូចដែលគណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងស្ត្រី បានកត់សម្គាល់នៅក្នុងសេចក្តីសង្កេតសន្និដ្ឋានក្នុងឆ្នាំ២០១៩ ថាការមាក់ងាយនៅក្នុងសង្គម និងវប្បធម៌ គឺជារនាំងឧបសគ្គក្នុងការទទួលបានយុត្តិធម៌។ បទសម្ភាសន៍ជាមួយជនរងគ្រោះរស់រានក្តជីវិត បានបង្ហាញថាការមាក់ងាយបានបង្កផលប៉ះពាល់អវិជ្ជមានទៅលើសុខភាពផ្លូវចិត្តរបស់ជនរងគ្រោះរស់រានក្តជីវិតទាំងនោះ និងរារាំងដល់ការសិក្សា និងជីវភាពសង្គមរបស់ពួកគេ។

ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយនៅក្នុងប្រទេសកម្ពុជា ដែលបានដាក់ចេញដើម្បីដោះស្រាយនូវអំពើហិង្សាផ្អែកលើយេនឌ័រនៅតែមានភាពខ្វះចន្លោះ និងគួរតែត្រូវបានធ្វើវិសោធនកម្ម ដើម្បីធានាឲ្យបាននូវការគោរពតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ។ បន្ថែមលើនេះ ច្បាប់ដែលមានស្រាប់ក៏មិនត្រូវបានអនុវត្តឲ្យបានត្រឹមត្រូវ និងជាប់លាប់។

នៅមានកង្វះខាតនៃការឆ្លើយតបប្រកបដោយប្រសិទ្ធភាពពីសំណាក់អាជ្ញាធរថ្នាក់លើ ចំពោះករណីសំណុំរឿង ដែលអាជ្ញាធរថ្នាក់មូលដ្ឋានបានបញ្ជូនទៅពួកគេ។ អ្វីដែលជាការព្រួយបារម្ភនោះ គឺមានសំណុំរឿងខ្លះត្រូវបានដោះស្រាយបញ្ចប់នៅត្រឹមការិយាល័យប៉ុស្តិ៍នគរបាលឃុំ និងឬស្រុកតែប៉ុណ្ណោះ។ មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចបញ្ជូនសំណុំរឿងបន្តទៅតុលាការ និងមិនគួរដោះស្រាយករណីទាំងនោះដោយផ្ទាល់ទេ។ បន្ថែមលើនេះក៏មានកង្វះសេវាកម្មគាំពារសម្រាប់ជនរងគ្រោះរស់រានក្តជីវិត និងក្រុមគ្រួសារ ដែលគ្មានលទ្ធភាពដើម្បីបន្តការដាក់បណ្តឹងករណីព្រហ្មទណ្ឌ និងធ្វើដំណើរទៅមកតុលាការ ដោយគ្មានជំនួយឧបត្ថម្ភផ្នែកច្បាប់ និងហិរញ្ញវត្ថុ។ កង្វះខាតនេះបណ្តាលឲ្យប៉ះពាល់ដល់សិទ្ធិទទួលបានយុត្តិធម៌របស់ជនរងគ្រោះរស់រានក្តជីវិត និងក្រុមគ្រួសារជនរងគ្រោះ/ជនរងគ្រោះរស់រានក្តជីវិតទាំងនោះ។

នៅមានករណីខ្លះ ដែលទំនាស់រវាងសិទ្ធិជនរងគ្រោះរស់រានក្តជីវិត និងសិទ្ធិផ្នែកវប្បធម៌របស់ជនជាតិដើមភាគតិចបានកើតឡើង ដូចមានករណីមួយចំនួនត្រូវបានដោះស្រាយដោយមធ្យោបាយបែបប្រពៃណីដែលតម្រូវឲ្យជនល្មើសបង់ប្រាក់សំណងដើម្បីបិទបញ្ចប់សំណុំរឿង ដោយមិនចាំបាច់ប្រឈមជាមួយប្រព័ន្ធច្បាប់ចំពោះអំពើរបស់ពួកគេ។ វិធានការដំណោះស្រាយបែបប្រពៃណីទាំងនោះ មិនបានប្រើប្រាស់វិធីសាស្ត្រដែលផ្តោតលើអត្ថប្រយោជន៍ជនរងគ្រោះរស់រានក្តជីវិតនោះទេ ផ្ទុយទៅវិញគឺផ្តោតទៅលើអ្វីដែលត្រូវបានគេជឿជាអត្ថប្រយោជន៍សម្រាប់សហគមន៍ទាំងមូល។

ជំនឿសន្ទត់ផ្អែកលើពូជសាសន៍មួយចំនួននៅតែកើតមានដែលបង្ហាញនូវភាពលម្អៀង និងការរើសអើងប្រឆាំងជនជាតិដើមភាគតិចផ្អែកលើផ្នត់គំនិតបែបទូទៅនីយកម្ម ដែលបង្ហាញឲ្យឃើញនូវកង្វះការយល់ដឹងពីប្រពៃណី និងវប្បធម៌ជនជាតិដើមភាគតិច។ ខណៈដែលអាជ្ញាធរដែលមិនមែនជាជនជាតិដើមភាគតិច

អាចគ្មានចេតនាបង្កហានិភ័យនោះ ការយល់ដឹងបន្ថែមពីវប្បធម៌ និងប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច អាចនឹងជួយឲ្យពួកគេអាចផ្តល់ការគាំទ្រ និងជួយសហគមន៍ទាំងនោះបានកាន់តែប្រសើរឡើង។

ការគាំទ្រដល់ជនរងគ្រោះរស់រានដ្ឋជីវិតពីអំពើហិង្សាផ្អែកលើយេនឌ័រត្រូវការការពង្រឹង និងធ្វើឲ្យប្រសើរឡើង ដើម្បីឲ្យពួកគេអាចទទួលបានសេវាគ្រប់ជ្រុងជ្រោយ រួមមានជំនួយផ្នែកវេជ្ជសាស្ត្រ និងផ្នែកចិត្តសង្គម ជំនួយជីវភាពរស់នៅ ការបណ្តុះបណ្តាលជំនាញ និងជំនួយផ្នែកច្បាប់។ ជាការល្អប្រសើរដែលភ្នាក់ងារនគរបាល បានរៀបចំឲ្យមានប៉ុស្តិ៍នគរបាលបន្ថែមទៀតនៅក្នុងតាមបណ្តាភូមិទាំងនោះ ដើម្បីបង្កើនភាពងាយស្រួលសម្រាប់ជនរងគ្រោះរស់រានដ្ឋជីវិត ឬក្រុមគ្រួសារ ក្នុងការធ្វើសេចក្តីរាយការណ៍អំពីករណីអំពើហិង្សាផ្អែកលើយេនឌ័រ។ បន្ថែមលើនេះការដែលភ្នាក់ងារនគរបាលបានស្នើរសុំវគ្គបណ្តុះបណ្តាលសម្រាប់ពួកគេដើម្បីឲ្យពួកគេអាចយល់ដឹងកាន់តែប្រសើរឡើងអំពីយេនឌ័រ និងជួយសហគមន៍បន្ថែមទៀតនោះក៏ជាការប្រសើរដែរ។

## អនុសាសន៍សង្ខេបៈ

## សកម្មភាពដើម្បីដោះស្រាយឬសគល់/ទប់ស្កាត់អំពើហិង្សាផ្អែកលើយេនឌ័រ

### អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា

១. គួរតែធ្វើការសិក្សាស្រាវជ្រាវបន្ថែមជុំវិញ ករណីអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងស្ត្រីជនជាតិដើមភាគតិច និងធ្វើការវិភាគដោយហ្មត់ចត់ ដោយផ្តោតការយកចិត្តទុកដាក់លើបុព្វហេតុនានាដែលជម្រុញឲ្យមានការកើនឡើងនៃអំពើហិង្សាទាំងនេះ និងជម្រុញការចូលរួមរបស់សមាជិកផ្សេងៗទៀតក្នុងគ្រួសារនៅក្នុងករណីជាច្រើន។

២. គួរតែធ្វើការជាមួយអង្គការសិទ្ធិស្ត្រី អង្គការសិទ្ធិមនុស្ស អង្គការជនជាតិដើមភាគតិច និងទីភ្នាក់ងារនានានៃអង្គការសហប្រជាជាតិ ដើម្បីរៀបចំបង្កើតកម្មវិធីបណ្តុះបណ្តាលគ្រប់ជ្រុងជ្រោយសម្រាប់មន្ត្រីសាធារណៈដើម្បីដោះស្រាយបុព្វហេតុនៃអំពើហិង្សាផ្អែកលើយេនឌ័រ រួមទាំងអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាបង្កឡើងដោយដៃគូស្និទ្ធស្នាល។

៣. គួរតែបង្កើតនូវកម្មវិធីលើកកម្ពស់ការយល់ដឹងចំពោះបញ្ហាទាំងនេះ ដើម្បីធានាថាមន្ត្រីសាធារណៈ និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងអង្គការមហាជននានា រួមទាំងអង្គការស្ត្រីជនជាតិដើមភាគតិច មានការយល់ដឹងត្រឹមត្រូវអំពីយេនឌ័រ និងគួរតែសហការឲ្យបានពេញលេញជាមួយពួកគេ ដើម្បីធានាថាការបណ្តុះបណ្តាលត្រូវបានធ្វើឡើងក្នុងលក្ខណៈទូលំទូលាយ ជាពិសេសនៅក្នុងតំបន់ភូមិសាស្ត្រដែលរដ្ឋាភិបាលមិនមានធនធានគ្រប់គ្រាន់ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលនោះ។

៤. គួរតែសម្របសម្រួលបង្កើនការយល់ដឹងអំពីវប្បធម៌ប្រពៃណីសហគមន៍ជនជាតិដើមភាគតិច ក្នុងចំណោមអាជ្ញាធរមានសមត្ថកិច្ចដែលមិនមែនជាជនជាតិដើមភាគតិច ដើម្បីបង្កើនលទ្ធភាពរបស់ពួកគេក្នុងការផ្តល់ការគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិចឲ្យកាន់តែប្រសើរ។

៥. គួរតែបង្កើតនូវយន្តការគ្រប់គ្រងទិន្នន័យ ដែលធ្វើការបំបែកទិន្នន័យតាម អាយុ ភេទ និងជាតិពន្ធុ ជាពិសេសនៅក្នុងខេត្តនានាដែលមានសហគមន៍ជនជាតិដើមភាគតិចរស់នៅ និងបង្កើតផែនការនានាដើម្បីសម្រេចបាននូវទិន្នន័យបំបែកពេញលេញមួយដែលមានរយៈពេល៥ឆ្នាំ។ ការប្រមូល ការគ្រប់គ្រង និងការប្រើប្រាស់ទិន្នន័យស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រ គួរតែអនុវត្តនូវវិធីសាស្រ្តផ្តោតលើសិទ្ធិមនុស្សដោយប្រកាន់ខ្ជាប់នូវគោលការណ៍នៃការចូលរួម ការបំបែកទិន្នន័យ ស្វ័យអត្តសញ្ញាណ តម្លាភាព ឯកជនភាព និងគណនេយ្យភាព។
៦. គួរតែបន្តការងាររបស់ខ្លួនលើការទប់ស្កាត់អាពាហ៍ពិពាហ៍កុមារ រួមទាំងបន្តនូវរាល់កិច្ចសហការរបស់ខ្លួនជាមួយអង្គការមូលដ្ឋាននិងអន្តរជាតិនានាទៅលើបញ្ហានេះ។
៧. គួរតែធ្វើវិសោធនកម្មក្របខណ្ឌច្បាប់ រួមទាំងដាក់ចេញនូវច្បាប់ស្តីពីការរើសអើងប្រឆាំងស្រ្តី ពង្រីកវិសាលភាពនិយមន័យនៃអំពើបៀតបៀនផ្លូវភេទ និងធ្វើការត្រួតពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មច្បាប់ស្តីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដូចដែលគណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងស្រ្តីបានផ្តល់ជាអនុសាសន៍។
៨. គួរតែចាត់វិធានការនានាដើម្បីធានាថារាល់ក្របខណ្ឌច្បាប់ត្រូវបានអនុវត្តត្រឹមត្រូវនៅគ្រប់ករណីនៃអំពើហិង្សាផ្អែកលើយេនឌ័រ ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដើម្បីធានាថាជនល្មើសមានការទទួលខុសត្រូវចំពោះសកម្មភាពរបស់ពួកគេ ហើយជនរងគ្រោះទទួលបានយុត្តិធម៌ តាមរយៈការបន្តផ្តល់ជំនួយផ្នែកច្បាប់ និងអនុវត្តយុទ្ធនាការអប់រំផ្សព្វផ្សាយសាធារណៈ អំពីសេរីភាពជាមូលដ្ឋាននិងសិទ្ធិមនុស្ស ព្រមទាំងផ្តល់ព័ត៌មានទាក់ទងនឹងមធ្យោបាយដាក់ពាក្យបណ្តឹង ក្នុងករណីអំពើហិង្សាផ្លូវភេទនិងអំពើហិង្សាផ្អែកលើយេនឌ័រ។

**អនុសាសន៍សម្រាប់ដៃគូអភិវឌ្ឍន៍ និងសហគមន៍អន្តរជាតិ**

១. គួរតែផ្តល់ការគាំទ្រដល់អង្គការសង្គមស៊ីវិល ក្នុងការធ្វើការសិក្សាស្រាវជ្រាវទាក់ទងនឹងអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងស្រ្តីជនជាតិដើមភាគតិច
២. គួរតែផ្តល់ការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាលលក្ខណៈទូលំទូលាយនិងផ្តួចផ្តើមគំនិតលើកកម្ពស់ការយល់ដឹងដើម្បីដោះស្រាយឫសគល់នៃអំពើហិង្សាផ្អែកលើយេនឌ័រ។
៣. គួរតែផ្តល់ការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រមូលទិន្នន័យជាទៀងទាត់ និងគ្រប់ជ្រុងជ្រោយទាក់ទងនិងអំពើហិង្សាផ្អែកលើយេនឌ័រ នៅតាមទីភ្នាក់ងាររដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធ រួមទាំងធ្វើការបំបែកទិន្នន័យតាម អាយុ ភេទ និងជាតិពន្ធុ និងបង្កើតផែនការដើម្បីសម្រេចបាននូវទិន្នន័យបំបែកពេញលេញមួយដែលមានរយៈពេល៥ឆ្នាំ។
៤. គួរតែគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីទប់ស្កាត់អាពាហ៍ពិពាហ៍កុមារ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើក្រុមកុមាររស់នៅក្នុងសហគមន៍ជនជាតិដើមភាគតិច។កម្មវិធីអន្តរាគមន៍

នានាគួរតែផ្តោតការយកចិត្តទុកដាក់ទៅលើទាំងកុមារា និងកុមារី ដើម្បីលើកទឹកចិត្តពួកគេកុំឲ្យរៀបការមុនអាយុ១៨ឆ្នាំ និងលើកទឹកចិត្តក្មេងស្រីកុំឲ្យមានកូនក្នុងវ័យជំទង់។

៥. គួរតែគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើវិសោធនកម្មក្របខណ្ឌច្បាប់ដើម្បីធានានូវការគោរពតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ។

## សកម្មភាពចំបាច់នានាដើម្បីពង្រឹងការឆ្លើយតបចំពោះអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងស្ត្រីជនជាតិដើមភាគតិច

<u>អនុសាសន៍ជូនចំពោះរាជរដ្ឋាភិបាលកម្ពុជា</u>

១. គួរតែដាក់ចេញនូវវិធានការចាំបាច់និងសមស្របនានា ដើម្បីអនុវត្តនូវរាល់អនុសាសន៍របស់គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ ដែលបានធ្វើឡើងនៅក្នុងសេចក្តីសន្និដ្ឋានឆ្នាំ២០១៩។[1]

២. គួរតែដាក់ចេញនូវវិធានការចាំបាច់និងសមស្របនានា ដើម្បីអនុវត្តនូវរាល់អនុសាសន៍របស់គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងពូជសាសន៍ ដែលបានធ្វើឡើងនៅក្នុងសេចក្តីសន្និដ្ឋានឆ្នាំ២០២០។[2]

៣. គួរតែបែងចែកធនធានហិរញ្ញវត្ថុនិងធនធានមនុស្សជាជំហានៗដើម្បីផ្តល់សេវាកម្មដល់ជនរងគ្រោះរស់រានដ្ឋជីវិតពីអំពើហិង្សាផ្អែកលើយេនឌ័រ និងបង្កើនភាពងាយស្រួលដល់ដល់ជនរងគ្រោះរស់រានជីវិតក្នុងការទទួលបាននូវសេវាកម្មទាំងនោះ រួមទាំងជនរងគ្រោះរស់រានជីវិតដែលជាជនជាតិដើមភាគតិច។

៤. គួរតែចាត់វិធានការនានា ដើម្បីធានាថាក្របខណ្ឌច្បាប់ត្រូវបានអនុវត្តដោយសមរម្យនៅក្នុងគ្រប់ទម្រង់នៃការចោទប្រកាន់ទាំងឡាយ និងគ្រប់ករណីនៃអំពើហិង្សាផ្អែកលើយេនឌ័រ ស្របជាមួយវិធាននិងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដើម្បីធានាឲ្យមានការទទួលខុសត្រូវពីជនល្មើសទាំងនោះ។

៥. គួរតែរៀបចំកម្មវិធីបណ្តុះបណ្តាលគ្រប់ជ្រុងជ្រោយ និងផ្តួចផ្តើមគំនិតលើកកម្ពស់ការយល់ដឹងដល់មន្ត្រីសាធារណៈ ដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះការចោទប្រកាន់និងករណីអំពើហិង្សាលើយេនឌ័រ ស្របតាមក្របខ័ណ្ឌច្បាប់ជាតិនិងអន្តរជាតិ។

៦. គួរតែលើកទឹកចិត្តដល់អាជ្ញាធរថ្នាក់ជាតិ និងមូលដ្ឋាន ឲ្យបង្កើនការយល់ដឹងអំពីទំនៀមទម្លាប់ និងវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិច និងចាត់វិធានការដើម្បីលើកកំពស់ការយលល់ដឹងកាន់តែទូលំទូលាយរវាងសហគមន៍ជនជាតិដើមភាគតិច និងបុគ្គលមិនមែនជនជាតិដើមភាគតិចដើម្បីទប់ស្កាត់ការធ្វើបុរេវិនិច្ឆ័យ និងការរើសអើង។

[1] CEDAW/C/KHM/CO/6.
[2] CERD/C/KHM/14-17.

៧. គួរតែធ្វើឲ្យប្រសើរឡើងនូវការសម្របសម្រួលរវាងអាជ្ញាធរគ្រប់ផ្នែកទាំងអស់ដែលពាក់ព័ន្ធក្នុងការដោះស្រាយអំពើហិង្សាផ្អែកលើយេនឌ័រ ដើម្បីធានាថាសេវាកម្មនានាអាចកើនឡើងកាន់តែច្រើនសម្រាប់ជនរងគ្រោះដែលរស់រានដ្ឋជីវិត ហើយជនល្មើសត្រូវបានគេនាំយកមករកយុត្តិធម៌។

៨. គួរតែបញ្ចូលភាសាជនជាតិដើមភាគតិចនៅក្នុងប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍របស់នគរបាល ដើម្បីបង្កើនភាពងាយស្រួលដល់ស្ត្រីជនជាតិដើមភាគតិច ដើម្បីរាយការណ៍ករណីនៃអំពើហិង្សាផ្អែកលើយេនឌ័រ។

**<u>អនុសាសន៍សម្រាប់ដៃគូអភិវឌ្ឍន៍ និងសហគមន៍អន្តរជាតិ</u>**

១. គួរតែបន្តការគាំទ្រដល់ដៃគូអភិវឌ្ឍន៍ និងសហគមន៍អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលកំពុងបំពេញបេសកកម្មដើម្បីដោះស្រាយអំពើហិង្សាផ្អែកលើយេនឌ័រ។

២. គួរតែផ្តល់ការគាំទ្រដល់បណ្តាអង្គការជនជាតិដើមភាគតិចដែលមានជំហរនិងបេសកកម្មការងារជាក់លាក់ដើម្បីជម្រុញឲ្យមានការផ្លាស់ប្តូរនៅក្នុងសហគមន៍ជនជាតិដើមភាគតិច។

៣. គួរតែផ្តល់ការគាំទ្រ និងលើកទឹកចិត្តដល់បណ្តាអង្គការ សមាគមនានាដែលកំពុងផ្តល់សេវាប្រឹក្សាផ្នែកចិត្តសង្គម ដើម្បីនាំយកសេវាកម្មរបស់ពួកគេទៅដល់ស្ត្រីជនជាតិដើមភាគតិច។

# ១ សេចក្តីផ្តើម

## ១.១ បរិបទ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា "រាល់ទម្រង់នៃអំពើរើសអើងប្រឆាំងនឹងស្ត្រីត្រូវលុបបំបាត់"។[3] រដ្ឋធម្មនុញ្ញក៏បានធានានូវសិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រី ព្រមទាំងហាមឃាត់រាល់ការកេងប្រវ័ញ្ចផ្នែកការងារផងដែរ។ មាត្រា៣៨ បានហាមឃាត់រាល់ទម្រង់នៃអំពើហិង្សាផ្លូវកាយ។ ក្រមព្រហ្មទណ្ឌ និង ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក៏បានផ្តល់នូវការការពារពីរាល់ទម្រង់នៃអំពើហិង្សាប្រឆាំងស្ត្រី និងក្មេងស្រី។ កម្ពុជាក៏បានដាក់ចេញនូវក្របខណ្ឌច្បាប់ជាក់លាក់ ដូចជាច្បាប់ស្តីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះក្នុងឆ្នាំ(២០០៥) និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទក្នុងឆ្នាំ(២០០៨)។[4]

រដ្ឋធម្មនុញ្ញមិនបានផ្តល់និយមន័យផ្លូវការអំពីជនជាតិដើមភាគតិច ឬកិច្ចការពារជាក់លាក់ដល់សិទ្ធិរបស់ក្រុមជនជាតិដើមភាគតិចឡើយ តែមាត្រា៣២ បានផ្តល់ការធានានូវសមភាពចំពោះមុខច្បាប់ និងសមភាពនៃកិច្ចការពារចំពោះមុខច្បាប់ និងសិទ្ធិស្មើគ្នាសម្រាប់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ដោយគ្មានការបែងចែកពូជសាសន៍ ពណ៌សំបុរ ភេទ ភាសា ជំនឿ សាសនា ទស្សនៈនយោបាយ កំណើត ស្ថានភាពសង្គម ធនធាន និងតួនាទីណាមួយឡើយ។

យោងតាមរបាយការណ៍ចង្អុលបង្ហាញថា បច្ចុប្បន្ននេះមានជនជាតិដើមភាគតិចចំនួន២៤ក្រុមផ្សេងៗគ្នាដែលកំពុងតែរស់នៅក្នុងប្រទេសកម្ពុជាដែលមានស្ថិតិសរុបប្រមាណ២៥០,០០០នាក់ ទៅ ៤០០,០០០ នាក់ ឬ ២ ទៅ ៣ ភាគរយនៃចំនួនប្រជាជនសរុប។[5] ពួកគេតាំងទីលំនៅនៅក្នុងខេត្តចំនួន១៦ និងពង្រាយនៅក្នុងភូមិ៤៥៥ ជុំវិញផ្ទៃប្រទេស។ ជនជាតិដើមភាគតិចកម្ពុជាបានរក្សានូវទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងដី ព្រៃ ទន្លេ និងធនធានធម្មជាតិផ្សេងៗទៀតរបស់ពួកគេ។[6] ពួកគេមានវប្បធម៌ ប្រពៃណី ជំនឿ និងភាសាផ្សេងគ្នា ហើយការចិញ្ចឹមជីវិតរបស់ពួកគេ ពឹងផ្អែកយ៉ាងខ្លាំងទៅលើធនធានធម្មជាតិនិងដីធ្លី។ របាយការណ៍នេះគ្របដណ្តប់លើខេត្តចំនួនបី គឺខេត្តមណ្ឌលគិរី រតនគិរី និងខេត្តស្ទឹងត្រែង ដោយមានក្រុមជនជាតិដើមចំនួន ៥ ដាច់ដោយឡែកពីគ្នាគឺ៖ ពូនង ចារ៉ាយ កាចក់ គ្រឹង និងព្រៅ។

[3] មាត្រា៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[4] រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ ព្រះរាជក្រមលេខ នស/រកម០២០៨/០០៥ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចផ្លូវភេទ។ ភ្នំពេញ ឆ្នាំ២០០៨

[5] ក្រុមការងារអន្តរជាតិទទួលបន្ទុកកិច្ចការជនជាតិដើមភាគតិច (២០១៩)/ កម្ពុជា. ជនជាតិដើមភាគតិចនៅកម្ពុជា។ អាចរកបាននៅទីនេះ៖ https://www.iwgia.org/en/cambodia.html ដកស្រង់នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

[6] ផាត.ម., & សុវត្ថាណា.ស.(២០១២)។ កំណត់ត្រាបច្ចេកទេសប្រចាំប្រទេសស្តីពីបញ្ហាប្រឈមរបស់ជនជាតិដើមភាគតិច។ ធ្វើនៅភ្នំពេញ ឆ្នាំ២០១២។ ទំព័រ ២-៤

ជនជាតិដើមភាគតិច និងសិទ្ធិរបស់ពួកគេត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ និងច្បាប់ជាតិឯទៀត។ ជាក់ស្តែងមាត្រា២៣ នៃច្បាប់ភូមិបាលឆ្នាំ២០០១ របស់ប្រទេសកម្ពុជាបានចែងថា៖ "សហគមន៍ជនជាតិដើមភាគតិច គឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ចប្រតិបត្តិរបៀបរស់នៅតាមប្រពៃណីនិងដាំដុះលើដី ដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព។"

ទោះបីជាមានការការពារដោយច្បាប់ និងរដ្ឋធម្មនុញ្ញក្តី ព័ត៌មានដែលប្រមូលបានពីបទសម្ភាសន៍សម្រាប់កិច្ចការស្រាវជ្រាវនេះ បានបង្ហាញថាស្ត្រីជនជាតិដើមភាគតិចបានជួបការលំបាកជាច្រើនដូចជា ការទទួលបានការអប់រំ សេវាថែទាំសុខភាព លំនៅដ្ឋានសមរម្យ ការចូលរួមក្នុងជីវភាពផ្នែកវប្បធម៌ និងការប្រើប្រាស់សិទ្ធិដីធ្លី និងធនធានធម្មជាតិ។ ភាគច្រើនក្នុងចំណោមពួកគេកំពុងរស់នៅក្នុងភាពក្រីក្រ និងខ្វះចំណូលការរើសអើង ហើយកង្វះចំណេះដឹងផ្នែកភាសាបានក្លាយជាឧបសគ្គរាំងស្ទះស្ត្រីជនជាតិដើមភាគតិចក្នុងការប្រើប្រាស់សិទ្ធិរបស់ពួកគេបានពេញលេញ។[7] កុមារជនជាតិដើមភាគតិចរស់នៅក្នុងតំបន់ដាច់ស្រយាលតែងតែធ្វើដំណើរយៈផ្លូវឆ្ងាយដើម្បីទៅសាលារៀន និងដោយសារតែមានចំនួនករណីនៃអំពើហិង្សាផ្អែកលើយេនឌ័របានកើនឡើងនោះ កុមារីជនជាតិដើមភាគតិចនិងក្រុមគ្រួសារមួយចំនួន បានបង្ហាញភាពភ័យខ្លាចនៅពេលដែលពួកគេត្រូវធ្វើដំណើរម្នាក់ឯង។ តួរលេខក្នុងឆ្នាំ២០១៨ របស់អង្គការសហប្រជាជាតិបង្ហាញថាសាលារៀនជាច្រើននៅក្នុងផ្ទៃប្រទេសខ្វះទឹកស្អាតសម្រាប់បរិភោគនិង អនាម័យ[8] នេះក៏ជាបញ្ហាដែលប៉ះពាល់ដល់ស្ត្រីជនជាតិដើមភាគតិចផងដែរ។ នៅក្នុងរបាយការណ៍របស់អង្គការក្លាហាន និង OHCHR ស្ត្រីជនជាតិដើមភាគតិចម្នាក់បានរាយការណ៍ថា នាងត្រូវខ្នះខ្នែងពន្យល់ដល់ឪពុកម្តាយនាងដើម្បីទទួលបានការអនុញ្ញាតិឲ្យបន្តការសិក្សានៅកម្រឹតឧត្តមសិក្សាដោយសារតែឪពុកម្តាយនាង ... ជឿថាការសិក្សាគឺជាបុព្វសិទ្ធិដែលក្មេងប្រុសគួរទទួលបានជាជាងក្មេងស្រី[9] ស្ត្រីជនជាតិដើមភាគតិចម្នាក់ទៀតបានបញ្ជាក់ថាតាមបទពិសោធន៍ផ្ទាល់របស់នាង សមាជិកគ្រួសារភេទស្រីរបស់នាងមិនបានគិតថាការទទួលបានការសិក្សាអប់រំគឺជាកត្តាដែលអាចជួយឲ្យលក្ខខណ្ឌជីវភាពរបស់ពួកគេបានល្អប្រសើរ ឬអាចផ្តល់ចំណីអាហារសម្រាប់ទ្រទ្រង់ជីវិតរបស់ពួកគេនោះទេ។[10]

នៅក្នុងការសិក្សាឆ្នាំ២០០៩ ស្តីពីស្ត្រីជនជាតិដើមភាគតិចនិងការចូលរួមនៅក្នុងវិស័យនយោបាយ ស្ត្រីជនជាតិដើមភាគតិចបានបញ្ជាក់ថា ពួកគេគ្មានលទ្ធភាពចូលរួមប្រកបដោយអត្ថន័យពេញលេញនៅក្នុង

---

[7] បទសម្ភាសន៍ជាមួយស្ត្រីជនជាតិដើមភាគតិចដែលជាមេធាវី នៅក្នុងថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០

[8] កម្មវិធីត្រួតពិនិត្យរួមរបស់ WHO និង UNICEF ស្តីអំពីការផ្គត់ផ្គង់ទឹក និងអនាម័យ ការវាយតម្លៃអំពីសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅតាមសាលារៀននៅកម្ពុជា ដែលធ្វើបច្ចុប្បន្នភាពនៅក្នុងខែសីហា ឆ្នាំ២០១៨ និងបានដាក់បញ្ចូលនៅក្នុងរបាយការណ៍ស្រមោល ធ្វើឡើងនៅក្នុងខែកញ្ញា ឆ្នាំ២០១៩ របស់អង្គការ NGO-CEDAW ដែលបានបញ្ជូនទៅគណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើង រាល់ទម្រង់ប្រឆាំងនិងស្ត្រីភេទ សម្រាប់ការត្រួតពិនិត្យ លើកទី៧៤

[9] Klahaan/OHCHR, ការស្វែងយល់អំពីទំនាក់ទំនងរវាងសិទ្ធិផ្នែកសេដ្ឋកិច្ចនិងសង្គម និងការរំលោភលើសិទ្ធិដីធ្លីនិងលំនៅដ្ឋាននៅកម្ពុជាឆ្នាំ២០១៩

[10] សក្ខីកម្មរបស់ស្ត្រីជនជាតិដើមភាគតិចដែលជាមេធាវី នៅក្នុងថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០

អភិបាលកិច្ចនិងកិច្ចការនយោបាយទេ។ តួនាទីរបស់ពួកគេក្នុងការដឹកនាំតាមបែបប្រពៃណីក៏បានចាប់ផ្តើមធ្លាក់ចុះ ហើយពួកគេគ្មានតំណាងគ្រប់គ្រាន់ក្នុងជួរអាជ្ញាធរផ្លូវការដូចជាក្រុមប្រឹក្សាឃុំទេ។ ក្រុមប្រឹក្សាឃុំជនជាតិដើមភាគតិចមួយចំនួនបានរាយការណ៍ថា ពួកគេត្រូវបានគេមើលរំលងហើយផ្តល់តួនាទីឲ្យត្រឹមតែជាអ្នកមើលការខុសត្រូវលើ "បញ្ហាស្ត្រី" (ដឹកនាំគណៈកម្មាធិការស្ត្រីនិងកុមារ) ដោយសារតែ ភេទរបស់ពួកគេជាភេទស្រី។[11] ស្ត្រីជនជាតិដើមភាគតិចជាច្រើនត្រូវប្រឈមជាមួយការចោទប្រកាន់ និងបណ្តឹងព្រហ្មទណ្ឌផងដែរដោយសារតែសកម្មភាពការការពារដីធ្លីរបស់ពួកគេ។

ខណៈដែលការសិក្សាចំនួនពីរកន្លងមកទាក់ទងនិងស្ត្រីជនជាតិដើមភាគតិច[12] មិនបានរកឃើញថាអំពើហិង្សាផ្លូវភេទបានកើតឡើងក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិច (ចង្អុលបង្ហាញពីអង្គការCARE កម្ពុជា) ការសិក្សាធ្វើឡើងដោយសមាជិកនៃក្រុមការងារស្ត្រីជនជាតិដើមភាគតិចកម្ពុជា(CIWWG)[13] បានបង្ហាញថា ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះមានការកើនឡើងនៃអំពើហិង្សាផ្លូវភេទ និងអំពើហិង្សាផ្អែកលើយេនឌ័រដ៏ទៃទៀតនៅក្នុងសហគមន៍។ ពួកគេបានប្រមូលទិន្នន័យពីសហគមន៍ ប្រព័ន្ធផ្សព្វផ្សាយ និងបទសម្ភាសន៍ ជាមួយ អាជ្ញាធរមូលដ្ឋាន និងក្រុមគ្រួសារជនរងគ្រោះ/ជនរងគ្រោះរស់រានជីវិតពីអំពើហិង្សាផ្អែកលើយេនឌ័រ[14] ដែលបង្ហាញថាយ៉ាងហោចណាស់ មាន២៥ករណីនៃអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងស្ត្រីជនជាតិដើមភាគតិចបានកើតឡើងនៅក្នុងខេត្តក្រចេះ មណ្ឌលគិរី ព្រះវិហារ រតនគិរី និងស្ទឹងត្រែងចន្លោះឆ្នាំ២០១៥ និងឆ្នាំ២០២០។

## ១.២. គោលបំណង

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងចំនួន៣ដែលមានទំនាក់ទំនងគ្នាយ៉ាងសំខាន់ដូចខាងក្រោម៖

១. ធ្វើការកំណត់បញ្ហាទាក់ទងនានានិងកំណត់អំពើសណ្ឋាននៃអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងស្ត្រីជនជាតិដើមភាគតិច;

២. ធ្វើការវិភាគទិន្នន័យប្រមូលបានដើម្បីវាយតម្លៃប្រសិទ្ធភាពនៃការឆ្លើយតបរបស់អាជ្ញាធរមូលដ្ឋាន និង វិស័យយុត្តិធម៌ចំពោះករណីទាំងនេះ និង;

[11] ម៉ាហ្វីល, ម., & ហុង, ស. (២០០៩)។ ការលើកកម្ពស់ការចូលរួមរបស់ស្ត្រីជនជាតិដើមភាគតិចនៅក្នុងវិស័យនយោបាយ។ ធ្វើនៅភ្នំពេញ មូលនិធិហេនរិចបូល

[12] ម៉ាហ្វីល, ម., & ហុង, ស. (២០០៩)។ ការលើកកម្ពស់ការចូលរួមរបស់ស្ត្រីជនជាតិដើមភាគតិចនៅក្នុងវិស័យនយោបាយ។ ធ្វើនៅភ្នំពេញ មូលនិធិហេនរិចបូល និង ភើរេស ភើរ៉េរ៉ូ, អ., ឡូប៉េ ខទីណា, ជេ., ប្រ៊ីហ្គាន ខនស៊ុលធីង, "ការមានផ្ទៃពោះក្នុងវ័យជំទង់& អាពាហ៍ពិពាហ៍វ័យក្មេងនៅក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិចនៅភាគឥសាន្តនៃប្រទេសកម្ពុជា", អង្គការ CARE Cambodia, ២០១៨, ទំព័រ ៣១-៣២។ របាយការណ៍ស្រាវជ្រាវទាំងពីរបានកត់សម្គាល់ថា អំពើហិង្សាផ្លូវភេទប្រឆាំងស្ត្រីជនជាតិដើមភាគតិចគឺកម្រកើតមានណាស់។

[13] CIWWG គឺជាអង្គកាមហាជនកម្រឹតមូលដ្ឋានដែលបង្កើតឡើងដោយស្ត្រីជនជាតិដើមភាគតិច និងមានសមាជិកសុទ្ធតែជាស្ត្រីជនជាតិដើមភាគតិច ដែលកំពុងធ្វើការក្នុងវិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងឬជាភ្នាក់ងាររដ្ឋាភិបាល។

[14] CIWWG, របាយការណ៍ស្តីពីអំពើរំលោភសេពសន្ថវៈ និងឃាតកម្មនៅក្នុងខេត្តរតនគិរី ចន្លោះឆ្នាំ២០១៧-២០១៩ ធ្វើនៅភ្នំពេញ ឆ្នាំ២០១៩។

៣. ផ្តល់ការគាំទ្រដល់ជនរងគ្រោះរស់រានមានជីវិតពីអំពើរំលោភសេពសន្ថវៈ និងជនរងគ្រោះ/ក្រុមគ្រួសារជនរងគ្រោះរស់រានមានជីវិត ដើម្បីទទួលបានតំណាងផ្នែកច្បាប់ និងសេវាសាធារណៈឆ្លើយតបនឹងយេនឌ័រ។

## ១.៣. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះប្រើប្រាស់វិធីសាស្ត្របែបគុណវិស័យ ដែលព្យាយាមផ្តល់នូវការពិពណ៌នាយ៉ាងល្អិតល្អន់ពីបទពិសោធន៍របស់ជនរងគ្រោះរស់រានមានជីវិត និង/ឬ ក្រុមគ្រួសារជនរងគ្រោះនៃអំពើហិង្សាផ្អែកលើយេនឌ័រក្នុងការស្វែងរកយុត្តិធម៌តាមរយៈយន្តការដោះស្រាយនានា រួមទាំងតាមរយៈយន្តការបែបប្រពៃណីជនជាតិដើមភាគតិច និងប្រព័ន្ធយុត្តិធម៌ផ្លូវការ។

ក្រុមត្រួតពិនិត្យចំនួន២២នាក់ត្រូវបានបង្កើតឡើងដោយមានការសហការរវាងការិយាល័យOHCHR ដែលតំណាងដោយទីប្រឹក្សាបច្ចេកទេសឯករាជ្យ តំណាងនៃអង្គការក្លាហាន និងក្រុមការងារCIWA ដែលតំណាងដោយជនជាតិដើមភាគតិចចំនួន២០នាក់មកពីសហគមន៍ជនជាតិដើមចំនួន៦។[15]

ជាជំហានដំបូងក្រុមការងារត្រួតពិនិត្យ ត្រូវបានបណ្តុះបណ្តាលយ៉ាងយកចិត្តទុកដាក់អំពីរបៀបនៃការចងក្រងឯកសារស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រ ដោយផ្តោតលើគោលការណ៍មិនបង្កគ្រោះថ្នាក់ និងការយល់ដឹងត្រឹមត្រូវអំពីយេនឌ័រនៅពេលធ្វើការត្រួតពិនិត្យនិងបច្ចេកទេសប្រមូលទិន្នន័យវាល។ តំណាងនៃអង្គការក្លាហាន ទីប្រឹក្សាបច្ចេកទេស និងបុគ្គលិកនៃការិយាល័យ OHCHR និងតំណាងនៃអង្គការមិនមែនរដ្ឋាភិបាលមួយដែលកំពុងបំពេញបេសកកម្មការងារប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាផ្លូវភេទនិងការជួញដូរមនុស្សនៅកម្ពុជាបានសម្របសម្រួលកម្មវិធីបណ្តុះបណ្តាលនេះ។

របាយការណ៍ស្រាវជ្រាវនេះផ្អែកលើព័ត៌មានប្រមូលបានពីបទសម្ភាសន៍ចំនួន៥៤ ដែលធ្វើឡើងដោយក្រុមត្រួតពិនិត្យនៅចន្លោះខែសីហា-តុលាឆ្នាំ២០២០ជាមួយជនរងគ្រោះអំពើរំលោភសេពសន្ថវៈ ជនរងគ្រោះនៃការប៉ុនប៉ងរំលោភសេពសន្ថវៈ ជនរងគ្រោះនៃអំពើបៀតបៀនផ្លូវភេទនិងអំពើហិង្សាក្នុងគ្រួសារ។ ក្រុមគ្រួសារជនរងគ្រោះ/ជនរងគ្រោះរស់រានមានជីវិត និងអាជ្ញាធរមូលដ្ឋាននានា មេដឹកនាំបែបប្រពៃណី និងតំណាងអង្គការមិនមែនរដ្ឋាភិបាល។ សកម្មភាពទាំងនេះត្រូវបានធ្វើឡើងនៅខេត្តចំនួនបី នៃប្រទេសកម្ពុជា (មណ្ឌលគិរី រតនគិរី និងស្ទឹងត្រែង) និងជាមួយអង្គការអន្តរជាតិមួយនៅភ្នំពេញ។ ដូចបានកត់សម្គាល់នៅទំព័រទី៧ខាងលើការសិក្សាស្រាវជ្រាវក៏បានត្រួតពិនិត្យលើរបាយការណ៍ និងឯកសារស្រាវជ្រាវ រួមទាំងគោលនយោបាយពាក់ព័ន្ធនានាផងដែរ។

[15] ក្រុមការងារត្រួតពិនិត្យដែលជាសមាជិករបស់ CIWWG ត្រូវបានជ្រើសរើសចេញពីសហគមន៍ជនជាតិដើមភាគតិចចំនួន០៦ រួមមាន ពូនង ចារ៉ាយ គ្រឹង គួយ ព្រៅ និងទំពួន។

បន្ទាប់ពីការថ្លឹងថ្លែងអំពីហានិភ័យនានាដែលអាចនឹងកើតមានដល់ជនរងគ្រោះ និង ក្រុមគ្រួសារជនរងគ្រោះរស់រានជីវិត ក្រុមការងារត្រួតពិនិត្យបានបង្កើតទំនាក់ទំនងជាមួយ មេឃុំ/មេភូមិ ដើម្បីដើរតួជាអន្តការីក្នុងទំនាក់ទំនងជាមួយជនរងគ្រោះរស់រានជីវិត និងក្រុមគ្រួសាររបស់ពួកគេ។

ក្រុមការងារCIWA ដែលបានទទួលព័ត៌មានបឋមអំពីករណីអំពើហិង្សាផ្នែកលើយេនឌ័រ បានកំណត់អត្តសញ្ញាណជនរងគ្រោះរស់រានជីវិត ក្រុមគ្រួសារជនរងគ្រោះ និងមេដឹកនាំប្រពៃណីជនជាតិដើមភាគតិចដែលបានព្រមព្រៀងសហការផ្តល់ព័ត៌មានក្នុងការសិក្សាស្រាវជ្រាវនេះ។ អន្តរការីនៅតាមឃុំនីមួយៗនៅក្នុងស្រុកគោលដៅក៏បានបញ្ជូនព័ត៌មានអំពីករណីមួយចំនួនមកកាន់ក្រុមការងារ CIWA ផងដែរ។

នៅក្នុងខេត្តរតនគិរី ក្រុមការងារត្រួតពិនិត្យបានជួបសន្ទនាជាមួយមន្ត្រីគរបាលថ្នាក់ខេត្ត មន្ត្រីទទួលបន្ទុកការងារនៅមន្ទីរកិច្ចការនារី និងមន្ត្រីផ្នែកយុត្តិធម៌នៅសាលាដំបូងខេត្តរតនគិរី ដោយសារតែខេត្តនេះមានករណីអំពើហិង្សាផ្អែកលើយេនឌ័រច្រើនជាងគេ។

## វិធានការការពារ

ក្រុមត្រួតពិនិត្យបានកំណត់កត្តាហានិភ័យដែលអាចកើតឡើងនៅក្នុងដំណើរការត្រួតពិនិត្យ និងបានចាត់វិធានការដើម្បីកាត់បន្ថយហានិភ័យទាំងអស់នោះ។ ជាក់ស្តែងបទសម្ភាសន៍នីមួយៗត្រូវធ្វើឡើងនៅទីតាំងដែលមានសុវត្ថិភាពដែលត្រូវបានជ្រើសរើស និងយល់ព្រមពីភាគីចូលរួមនៅក្នុងបទសម្ភាសន៍។ គ្រប់កិច្ចសម្ភាសន៍ទាំងអស់ធ្វើឡើងតែក្នុងអំឡុងពេលថ្ងៃប៉ុណ្ណោះ ដើម្បីធានាថាក្រុមការងារនិងអ្នកផ្តល់បទសម្ភាសមិនចាំបាច់ធ្វើដំណើរពេលយប់ទេ។

ទន្ទឹមនេះដើម្បីសម្រួលកិច្ចពិភាក្សាឲ្យបានគ្រប់ជ្រុងជ្រោយ និងច្បាស់លាស់ និងគ្មានការយល់ច្រឡំ ឬបាត់អត្ថន័យភាសាមូលដ្ឋានជនជាតិដើមភាគតិចក៏ត្រូវបានប្រើប្រាស់សម្រាប់កិច្ចសម្ភាសន៍ផងដែរ។ បន្ថែមលើនេះភាសាខ្មែរ និងភាសាអង់គ្លេសក៏ត្រូវបានប្រើប្រាស់នៅក្នុងបទសម្ភាសន៍ជាមួយអាជ្ញាធរថ្នាក់ខេត្ត និងតំណាងនៃអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ។ ភាសាខ្មែរ និងភាសាជនជាតិដើមភាគតិច ដែលមានដូចជា ពូនង ចារ៉ាយ គ្រឹង និងព្រៅ ត្រូវបានប្រើប្រាស់នៅក្នុងបទសម្ភាសន៍ជាមួយអាជ្ញាធរមូលដ្ឋានជនជាតិដើមភាគតិច ជនរងគ្រោះរស់រានជីវិត និងក្រុមគ្រួសារជនរងគ្រោះ និងមេដឹកនាំប្រពៃណី។

មុននឹងចាប់ផ្តើមសម្ភាសន៍នីមួយៗ អ្នកផ្តល់បទសម្ភាសន៍បានទទួលព័ត៌មានអំពីគោលបំណង និងដំណើរការនៃការសិក្សាស្រាវជ្រាវ និងរបៀបដែលរបកគំហើញនឹងត្រូវប្រើប្រាស់។ អ្នកចូលរួមនីមួយៗបានទទួលទម្រង់បញ្ជាក់ការយល់និងព្រមព្រៀង ព្រមទាំងផ្តល់នូវពេលវេលាគ្រប់គ្រាន់ដើម្បីអាន និងចុះហត្ថលេខា

មុននឹងកិច្ចសម្ភាសន៍ និងការថតសម្លេងចាប់ផ្តើមធ្វើឡើង។ ក្នុងចេតនាដើម្បីធានាថា អ្នកតបសម្ភាសន៍អាចផ្តល់ព័ត៌មានយ៉ាងក្បោះក្បាយព្រមទាំងដើម្បីរក្សាការសម្ងាត់នៃប្រភពផងនោះ របាយការណ៍នេះមិនបានបង្ហាញអត្តសញ្ញាណបុគ្គលណាម្នាក់ឡើយ។

### បញ្ហាប្រឈមនានានៅក្នុងគម្រោងស្រាវជ្រាវ

ករណីអំពើហិង្សាទាំងអស់ដែលបង្ហាញនៅក្នុងរបាយការណ៍នេះបានកើតឡើងនៅចន្លោះឆ្នាំ២០១៥និងឆ្នាំ ២០២០ នៅក្នុងខេត្តចំនួន៣នៃភាគឦសានប្រទេសកម្ពុជា រួមមានខេត្តមណ្ឌលគិរី រតនគិរី និងស្ទឹងត្រែង។ មានករណីខ្លះអាជ្ញាធរមូលដ្ឋានមិនបានអនុញ្ញាតឲ្យក្រុមស្រាវជ្រាវបានជួបជាមួយក្រុមគ្រួសារ និងជនរងគ្រោះ/ជនរងគ្រោះភ្លាមៗនោះទេ ដោយសារតែអាជ្ញាធរត្រូវអនុវត្តវិធានការណ៍សុខាភិបាលដើម្បីឆ្លើយតបនឹងទប់ស្កាត់ការីករាលនៃជំងឺកូវីដ១៩ ឬ ដោយសារតែកង្វះការផ្តល់ព័ត៌មានពីអាជ្ញាធរជាន់ខ្ពស់អំពីគម្រោងស្រាវជ្រាវនេះ ទោះបីជាជួបបញ្ហាប្រឈមទាំងនេះក្រុមសិក្សាស្រាវជ្រាវបានជួបសម្ភាសន៍ និងប្រមូលព័ត៌មានគ្រប់គ្រាន់សម្រាប់ការវិភាគ។ បន្ថែមលើនេះការទទួលបានទិន្នន័យអំពើហិង្សាផ្អែកលើយេនឌ័រខុសៗគ្នាពីសំណាក់ភាគីពាក់ព័ន្ធក៏បានបង្កផលលំបាកដល់ការវិភាគទិន្នន័យផងដែរ។ បច្ចុប្បន្នទិន្នន័យប្រមូលបានគ្មានការបែងចែកតាម អាយុ ភេទ ជាតិពិន្ទុ ម្យ៉ាងទៀតភ្នាក់ងាររដ្ឋាភិបាលនីមួយៗបានបង្ហាញស្ថិតិខុសៗគ្នា ដោយសារតែប្រភពនិងវិធីសាស្ត្រប្រមូលព័ត៌មានខុសៗគ្នា និងខ្វះការសហការរវាងអន្តរស្ថាប័នផងដែរ។ អាស្រ័យហេតុនេះក្រុមស្រាវជ្រាវបានកត់ត្រាទិន្នន័យ ប៉ុន្តែមិនអាចបញ្ជាក់អំពីចំនួនករណីអំពើហិង្សាផ្អែកលើយេនឌ័រដែលបានកើតឡើងជាក់លាក់ទេ។

គួរកត់សម្គាល់ផងដែរថារបាយការណ៍ និងឯកសារសិក្សាស្រាវជ្រាវដែលមានស្រាប់ស្តីអំពីយន្តការដំណោះស្រាយវិវាទបែបប្រពៃណីដែលប្រើប្រាស់ដោយសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជាមានចំនួនតិចតួចបំផុត។ ដូច្នេះរបាយការណ៍នេះពឹងផ្អែកលើប្រភពចំនួនពីរដែលធ្វើឡើងនៅក្នុងឆ្នាំ២០០៧ និងឆ្នាំ២០១៥ និងព័ត៌មានប្រមូលបានក្នុងអំឡុងពេលជួបសម្ភាសន៍ជាមួយភាគីពាក់ព័ន្ធនានា។

## ២.ក្របខណ្ឌច្បាប់ ប្រព័ន្ធគោលនយោបាយ និងយុត្តិធម៌ក្នុងប្រទេសកម្ពុជា

### ២.១. និយមន័យអំពើហិង្សាផ្អែកលើយេនឌ័រ

អំពើហិង្សាផ្អែកលើយេនឌ័រគឺជាអំពើរំលោភសិទ្ធិមនុស្ស។ អំពើនេះរួមបញ្ចូលនូវការរំលោភលើសិទ្ធិរស់រានមានជីវិត សន្តិសុខ និងបូរណៈភាពរាងកាយនិងផ្លូវចិត្ត អាចជាការរំលោភទៅលើសេរីភាពនៃការរួចផុតពីការធ្វើទារុណកម្មនិងអំពើឃោរឃៅ និងរួចផុតពីការប្រព្រឹត្តអំពើថោកទាបនិងអំពើមិនគប្បីផ្សេងៗទៀត ឬអាចជាការរំលោភទៅលើសមភាពនិងសេរីភាពរួចផុតពីការរើសអើង។ អំពើនេះក៏អាចជាការរំលោភទៅលើសិទ្ធិទទួលសេវាថែទាំសុខភាពដែលមានគុណភាព។ យោងតាមគណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងស្ត្រី “អំពើហិង្សាផ្អែកលើយេនឌ័រ គឺជាអំពើហិង្សាដែលត្រូវបានប្រព្រឹត្តទៅលើបុគ្គលណា

ម្នាក់ដោយសារតែលក្ខណៈភេទ /ឬអត្តសញ្ញាណយេនឌ័រ /ឬនិន្នាការភេទ /ឬបង្កផលប៉ះពាល់ដែលមិនសមាមាត្រដល់ក្រុមណាមួយដោយសារតែអត្តសញ្ញាណយេនឌ័ររបស់ពួកគេ។ អំពើនេះរួមបញ្ចូលទាំងសកម្មភាពដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្តនិង /ឬការធ្វើទុក្ខទោស ឬការរងទុក្ខផ្នែកសេដ្ឋកិច្ច ការគំរាមកំហែងពីសកម្មភាពបែបនេះ ការបង្ខិតបង្ខំ និងការដកហូតសេរីភាពដទៃទៀត។" គណៈកម្មាធិការបានបញ្ជាក់ថាការហាមឃាត់អំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងនឹងស្ត្រីភេទ គឺជាបទដ្ឋានប្រពៃណីនៃច្បាប់អន្តរជាតិ។ ទម្រង់ខ្លះៗនៃអំពើហិង្សាផ្អែកលើយេនឌ័រមានដូចជា អំពើរំលោភសេពសន្ថវៈ និងទម្រង់ដទៃទៀតនៃអំពើហិង្សាផ្លូវភេទ ការបង្ខំឲ្យរៀបការ និងអាពាហ៍ពិពាហ៍កុមារ អំពើហិង្សាក្នុងគ្រួសារ អំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ និងការកាត់ច្រឹបប្រដាប់ភេទរបស់ក្មេងស្រី។[16]

## ២.២.ច្បាប់សិទ្ធិមនុស្សអន្តរជាតិពាក់ព័ន្ធនឹងស្ត្រីជនជាតិដើមភាគតិចនៅកម្ពុជា

សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិជាច្រើនដែលកម្ពុជាបានផ្តល់សច្ចាប័ន មានជាប់ពាក់ព័ន្ធនឹងការការពារបុគ្គលប្រឆាំងនិងអំពើហិង្សាផ្អែកលើយេនឌ័រ ជាពិសេសអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទនិងពិធីសារបន្ថែម កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ចសង្គមនិងវប្បធម៌ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ប្រទេសកម្ពុជាក៏បានបោះឆ្នោតគាំទ្រដល់ការអនុម័តសេចក្តីប្រកាសស្តីពីសិទ្ធិជនជាតិដើមភាគតិច(UNDRIP) របស់អង្គការសហប្រជាជាតិ។[17] កម្ពុជាក៏បានផ្តល់សច្ចាប័នទៅលើកតិកាសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងពូជសាសន៍(CERD)ផងដែរ។ មាត្រា៣១នៃរដ្ឋធម្មនុញ្ញកម្ពុជា ធានានូវការអនុវត្តសន្ធិសញ្ញាទាំងនេះនៅក្នុងប្រទេស។ នៅឆ្នាំ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាបានដាក់ចេញនូវសេចក្តីសម្រេចដើម្បីផ្តល់ការបញ្ជាក់បន្ថែមថាសន្ធិសញ្ញាសិទ្ធិមនុស្សដែលត្រូវបានផ្តល់សច្ចាប័នដោយកម្ពុជាគឺជាផ្នែកមួយនៃច្បាប់ជាតិ និងគួរតែត្រូវបានអនុវត្តដោយចៅក្រមនៅក្នុងតុលាការកម្ពុជា។[18]

## ២.៣ ក្របខណ្ឌច្បាប់ និងគោលនយោបាយស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រទាក់ទងនិងស្ត្រីជនជាតិដើមភាគតិចនៅកម្ពុជា

### ច្បាប់ជាតិនានា

បទប្បញ្ញត្តិច្បាប់ជាក់លាក់ពាក់ព័ន្ធនិងអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងជនជាតិដើមភាគតិចនៅកម្ពុជា គឺគ្មានចែងច្បាស់លាស់ទេ។ ច្បាប់និងគោលនយោបាយពាក់ព័ន្ធនិងជនជាតិដើមភាគតិចផ្តោតសំខាន់លើសិទ្ធិទទួលបានការអភិវឌ្ឍនិងសិទ្ធិដីធ្លី ជាពិសេសប័ណ្ណកម្មសិទ្ធិដីសមូហភាព។ ទាក់ទងនិងអំពើហិង្សាផ្លូវភេទក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ហាមឃាត់និងផ្តន្ទាទោសអំពើរំលោភសេពសន្ថវៈ (មាត្រា ២៣៩-២៤៥)

---

[16] អនុសាសន៍រួមលេខ ៣៥នៃអនុសញ្ញា CEDAW, CEDAW/C/GC/35 ចុះថ្ងៃទី២៦ខែកក្កដាឆ្នាំ២០១៧។

[17] https://www.ohchr.org/en/issues/ipeoples/pages/declaration.aspx ដកស្រង់នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១

[18] https://cambodia.ohchr.org/en/rule-of-law/overview ដកស្រង់នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១

ការប្រទូស្តកេរខ្មាស (មាត្រា ២៤៦-២៤៨) ការបង្ហាញកេរភេទ (មាត្រា ២៤៩) ការរុកកួនខាងផ្លូវភេទ (មាត្រា ២៥០-២៥២) និង អំពើសញ្ចារកម្ម (មាត្រា ២៨៤-២៩៥)។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឆ្នាំ២០០៥ បានកំណត់អំពើហិង្សាក្នុងគ្រួសារនិងរៀបរាប់លំអិតអំពីទំនួលខុសត្រូវរបស់អាជ្ញាធរពាក់ព័ន្ធក្នុងការការពារនិងដោះស្រាយករណីអំពើហិង្សាក្នុងគ្រួសារ។ បន្ថែមលើនេះ ច្បាប់ស្តីពីការបង្ក្រាបការជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ បានហាមឃាត់ការជួញដូរនិងការកេងប្រវ័ញ្ចផ្លូវភេទតាមរយៈពេស្យាចាររូបភាពអាសអាភាសនិងអំពើមិនសមរម្យ។

ការផ្តល់និយមន័យនៃការអំពើរុកកួនខាងផ្លូវភេទនៅក្រោមច្បាប់កម្ពុជា មានលក្ខណៈចង្អៀត និងត្រូវបានអនុវត្តតែចំពោះស្ថានភាពដែលកើតឡើងនៅកន្លែងការងារតែប៉ុណ្ណោះ។[19] ច្បាប់មិនបានផ្តន្ទាទោសចំពោះករណីអំពើបៀតបៀនផ្លូវភេទដែលកើតឡើងនៅក្នុងទីសាធារណៈដែលបង្កឡើងដោយជនចំលែកមុខ និងមិនបានគិតគូដល់អំពើបៀតបៀនផ្លូវភេទនៅកន្លែងការងារដែលប្រព្រឹត្តដោយបុគ្គលិកក្រោមបង្គាប់ ឬសហការីដែលមានឋានៈតួនាទីស្មើគ្នាដែរ។[20] ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារឆ្នាំ២០០៥ មិនបានផ្តល់និយមន័យពេញលេញអំពីអំពើហិង្សាក្នុងគ្រួសារទេ[21]ដោយបានលុបចោលនូវសកម្មភាពជាក់លាក់មួយចំនួន និងការគំរាមគំហែងនានាដែលបង្កគ្រោះថ្នាក់ដល់ផ្លូវកាយ ផ្លូវចិត្ត ផ្លូវសេដ្ឋកិច្ច ឬផ្លូវភេទ ហើយក៏មិនរាប់បញ្ចូលការតាមដានសកម្មភាពដែរ។ ច្បាប់នេះក៏បានផ្តោតនិយមន័យបែបចង្អៀត អំពីបុគ្គលដែលអាចក្លាយជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ។ ជាក់ស្តែងច្បាប់នេះបានផាត់ចេញដៃគូស្និទ្ធស្នាល (រៀបការ ឬមិនរៀបការ ឬសូម្បីតែអតីតដៃគូស្និទ្ធស្នាល) និងសមាជិកគ្រួសារដែលមិនបានរស់នៅក្រោមដំបូលផ្ទះតែមួយ និងមិនទទួលស្គាល់ពីរបៀបដែលអំពើហិង្សាក្នុងគ្រួសារអាចកើតឡើងទៅលើកុមារ បុគ្គលស្រលាញ់ភេទដូចគ្នា បុគ្គលមានពិការភាព និងអ្នកធ្វើការតាមផ្ទះ។ ច្បាប់ក៏បានអនុញ្ញាតឲ្យមានការដាក់ "វិន័យ" ទៅលើប្តីប្រពន្ធនិងកូនផងដែរ។[22]

របាយការណ៍សន្និដ្ឋានឆ្នាំ២០១៩ របស់គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទបានផ្តល់អនុសាសន៍ថារាជរដ្ឋាភិបាលកម្ពុជាត្រូវពិនិត្យឡើងវិញនូវរាល់ខ្លឹមសារច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារនិងធ្វើវិសោធនកម្មបទប្បញ្ញត្តិពាក់ព័ន្ធដើម្បី "កំណត់ ហាមឃាត់ និងផ្តន្ទាទោស រាល់ទម្រង់នៃអំពើហិង្សាផ្អែកលើយេនឌ័រ រួមទាំងអំពើហិង្សាក្នុងគ្រួសារ អំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ដើម្បីសម្រួលដល់ដំណើរការនៃការទទួលបានវិធានការពារ និងដើម្បីធានាថាជនរងគ្រោះ/ អ្នករស់រានមានជីវិត

[19] មាត្រា ២៥០ ចែងថា៖ "ការបៀតបៀនផ្លូវភេទ" គួរមានន័យថា ជាអំពើរំលោភបំពានដោយបុគ្គលម្នាក់មានសិទ្ធិអំណាចដែលបានទទួលតាមរយៈមុខងាររបស់ខ្លួនទៅលើបុគ្គលម្នាក់ទៀតក្នុងគោលបំណងដើម្បីដាក់សម្ពាធម្តងហើយម្តងទៀតដើម្បីទទួលបានប្រយោជន៍ផ្លូវភេទនោះ។

[20] បុណ្យ , រ., "ប្រព័ន្ធបាក់បែក៖ ស្ថានភាពនៃស្ត្រីកម្មករនៅក្នុងឧស្សាហកម្មកាត់ដេរនៅកម្ពុជា" ,ឆ្នាំ២០២០។

[21] ពិនិត្យមាត្រា ២-៨នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥។

[22] បណ្ឌិត ពុង ឈីវហ្កេច, បទបង្ហាញអំពី "ភាពចន្លោះប្រហោងនៅក្នុងច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារនាពេលបច្ចុប្បន្ន៖ លទ្ធផល និងរបកគំហើញនៃក្រុមការងារ NGO លើវិសោធនកម្មច្បាប់ស្តីពី អំពើហិង្សាក្នុងគ្រួសារ" នាថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០១៩។

ពីអំពើហិង្សាក្នុងគ្រួសារអាចទទួលបានមធ្យោបាយដោះស្រាយប្រកបដោយប្រសិទ្ធភាពហើយជនល្មើសត្រូវទទួលខុសត្រូវ”។[23]

ខណៈគ្មានការកំណត់បញ្ជាក់ច្បាស់លាស់អំពីអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារបានលើកឡើងអំពី “ការរំលោភដោយកម្រោល” ហើយបញ្ញត្តិនេះគ្របដណ្តប់លើករណីនៃអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍។[24] មាត្រា២៣៩ នៃក្រមព្រហ្មទណ្ឌបានកំណត់អំពើរំលោភសេពសន្ថវៈថា “គ្រប់អំពើបញ្ចូលអង្គជាតិតាមបែបណាក៏ដោយ ឬអំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាតិដែលប្រព្រឹត្តទៅលើ ទោះបីមានភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមគំហែង ឬ ដោយការឆ្មក់ឱកាសក្តី”។ ដោយសារតែបញ្ញាតិនេះមិនបានបញ្ជាក់ជាក់លាក់ពីប្រភេទនៃជនល្មើស ឬជនរងគ្រោះ បញ្ញាតិក៏អាចយកមកអនុវត្តក្នុងករណីសហព័ទ្ធបានដែរ។ ទោះយ៉ាងណា គេក៏នៅមិនទាន់មានភ័ស្តុតាងបញ្ជាក់ថាបញ្ញាតិនេះត្រូវបានប្រើប្រាស់ដោយជោគជ័យនៅចំពោះមុខតុលាការកម្ពុជានៅឡើយទេ។ បច្ចុប្បន្ននេះនៅមិនទាន់មានការដាក់បញ្ចូលនិយមន័យជាក់លាក់ទាក់ទងនិងករណីនៃអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍នៅឡើយទេ។

ជាចុងក្រោយ មាត្រា៩៤៨ នៃក្រមរដ្ឋប្បវេណីកម្ពុជា បានហាមឃាត់អាពាហ៍ពិពាហ៍កុមារដោយកំណត់អាយុ១៨ឆ្នាំគឺជាអាយុដែលបុរសនិងស្ត្រីអាចរៀបការបាន និងយ៉ាងទាបបំផុតគឺអាយុ១៦ឆ្នាំ ប្រសិនបើមានការព្រមព្រៀងពីសំណាក់ឪពុកម្តាយ ឬអាណាព្យាបាល។

ច្បាប់ជាតិរបស់កម្ពុជាមិនបានហាមឃាត់ការរើសអើង រួមទាំងការរើសអើងផ្អែកលើយេនឌ័រ។ គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទបានបញ្ជាក់ថា “បញ្ហានេះនៅតែជាក្តីបារម្ភ ដោយសារតែគ្មានបទបញ្ញត្តិជាក់លាក់នៅក្នុងរដ្ឋធម្មនុញ្ញដែលកំណត់អំពីការរើសអើងដោយផ្ទាល់ និងដោយប្រយោលលើស្ត្រី ខណៈដែលក្រមព្រហ្មទណ្ឌហាមឃាត់តែទម្រង់ជាក់លាក់នៃការរើសអើងដោយផ្ទាល់ដូចជាការបដិសេធការទទួលបានទំនិញ សេវាកម្ម ឬការងារ។ គណៈកម្មាធិការក៏បានកត់សម្គាល់ផងដែរថាច្បាប់មួយចំនួនដែលបានធ្វើវិសោធនកម្មថ្មីៗនេះមិនបានដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវវិសមភាពរវាងបុរស

[23] CEDAW, សេចក្តីសន្និដ្ឋានស្តីពីរបាយការណ៍របស់ប្រទេសកម្ពុជាតាមកាលកំណត់លើកទី៦ នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៩, CEDAW/C/KHM/CO/6, កថាខណ្ឌ២៤ (b)។

[24] Van der Keur,D. បញ្ហាច្បាប់ និងយេនឌ័រស្តីពីអាពាហ៍ពិពាហ៍ និងការលែងលះនៅប្រទេសកម្ពុជា។ គេហទំព័រសារព័ត៌មាន ច្បាប់ និងគោលនយោបាយកម្ពុជា ចេញផ្សាយលើកទី៣ ខែធ្នូ ឆ្នាំ២០១៤។ អាចរកបាន៖ http://cambodialpj.org/article/legal-and-gender-issues-of-marriage-and-divorce-in-cambodia/ ដកស្រង់នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១។

និងស្ត្រី និងមានការសោកស្ដាយចំពោះកង្វះខាតនៃការវាយតម្លៃផលប៉ះពាល់យេនឌ័រនៅមុនពេលអនុម័ត ឬធ្វើវិសោធនកម្មច្បាប់”។[25]

## គោលនយោបាយជាតិ

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគោលការណ៍ណែនាំ និងគោលនយោបាយនានាដូចជា ក្រមសីលធម៌និងក្រមប្រតិបត្តិសម្រាប់រាយការណ៍ព័ត៌មានស្ដីពីអំពើហិង្សាលើស្ត្រីឆ្នាំ២០១៧ គោលការណ៍ណែនាំស្ដីពីការបញ្ជូនជនរងគ្រោះស្ត្រីនិងក្មេងស្រីដែលរងគ្រោះដោយអំពើហិង្សាផ្អែកលើយេនឌ័រឆ្នាំ២០១៦ ផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាប្រឆាំងនឹងស្ត្រីលើកទី២ ឆ្នាំ២០១៤-២០១៨ (NAPVAW 2) និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ឆ្នាំ២០១៤-២០១៨សម្រាប់សមភាពយេនឌ័រនិងភាពអង់អាចរបស់ស្ត្រី។ ខណៈដែលគ្មានការដោះស្រាយស្ថានភាពដោយផ្ទាល់សម្រាប់ស្ត្រីជនជាតិដើមភាគតិច គោលនយោបាយ និងគោលការណ៍ណែនាំទាំងនេះក៏អាចយកមកអនុវត្តផងដែរចំពោះស្ត្រីជនជាតិដើមភាគតិច។ជំងឺកូវីដ១៩ បានធ្វើឲ្យមានការពន្យារពេលនៃការអនុម័តផែនការយុទ្ធសាស្ត្រនារីរតនៈទី០៥ និងផែនការសកម្មភាពថ្នាក់ជាតិលើកទី០៣ ប៉ុន្តែចុងក្រោយផែនការនេះបានអនុម័តនិងផ្សព្វផ្សាយនៅដើមខែមករា ឆ្នាំ២០២១។

នៅក្នុងរបាយការណ៍ស្រមោលឆ្នាំ២០១៩របស់ NGO-CEDAW ដែលដាក់ជូនទៅគណៈកម្មការស្ដីពីការលុបបំបាត់នូវរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ បានចង្អុលបង្ហាញថាគោលនយោបាយជាច្រើនហាក់ផ្ដោតទៅលើសកម្មភាពរយៈពេលខ្លី និងបានកំណត់វិសាលភាពហិរញ្ញវត្ថុនិងតំបន់ភូមិសាស្ត្រដោយផ្អែកលើមូលនិធិរបស់ដៃគូអភិវឌ្ឍន៍ និងបានទទូចថាគោលនយោបាយទាំងនេះគួរផ្ដោតចក្ខុវិស័យរយៈពេលវែង និងត្រូវការធនធានថវិកាជាតិ។ របាយការណ៍ដដែលក៏បានចង្អុលបង្ហាញថា គួរតែមានការដាក់បង្ហាញ ទិន្នន័យជាសាធារណៈ និងគួរតែបែងចែកទិន្នន័យតាមយេនឌ័រ និងគួរតែចងក្រងទិន្នន័យទុកសម្រាប់វាស់វែងពីប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយទាំងនេះ។[26]

# ៣.ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា

## ៣.១ ប្រព័ន្ធយុត្តិធម៌ផ្លូវការ

អង្គការសង្គមស៊ីវិលនៅកម្ពុជាបានកត់សម្គាល់ថាអំពី តម្រូវការក្នុងការធ្វើវិសោធនកម្មច្បាប់ជាក់លាក់មួយចំនួននោះ បន្ថែមលើនេះក៏បានបញ្ជាក់ថាការអនុវត្តច្បាប់ដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាពនៅក្នុងករណីនៃអំពើហិង្សាផ្អែកលើយេនឌ័រនៅតែជាក្តីព្រួយបារម្ភណ៍។ ពួកគេបានកត់សម្គាល់ថាមានករណីអំពើ

---

[25]CEDAW, សេចក្តីសន្និដ្ឋានស្តីពីរបាយការណ៍របស់ប្រទេសកម្ពុជាតាមកាលកំណត់លើកទី៦ នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៩, CEDAW/C/KHM/CO/6, កថាខណ្ឌ៨។

[26] សេចក្តីសំណើររបស់ NGO-CEDAW នៅក្នុងរបាយការណ៍ស្រមោលសម្រាប់កិច្ចប្រជុំលើកទី៧៤ ដែលបានបញ្ជូនទៅគណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងស្ត្រី (CEDAW) នៅខែកញ្ញា ឆ្នាំ២០១៩។

ហិង្សាផ្នែកលើយេនឌ័រតិចតួចណាស់ដែលត្រូវបានផ្តន្ទាទោស ហើយការដាក់ចេញនូវដីការការពារនៅក្នុងឆ្នាំកន្លងមកក៏មានចំនួនតិចតួចដែរ។[27]

ទន្ទឹមនេះការទទួលបានជំនួយផ្នែកច្បាប់នៅមានការលំបាកនៅឡើយនៅកម្ពុជា ជាពិសេសនៅតាមតំបន់ដាច់ស្រយាលដោយសារតែមេធាវីភាគច្រើនគឺស្ថិតនៅក្នុងទីក្រុង។ ស្របគ្នានេះ គ្មានបញ្ញត្តិច្បាប់ដាក់លាក់ធានាថាជនរងគ្រោះនៃអំពើហិង្សាផ្នែកលើយេនឌ័រអាចទទួលបានជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ។ ស្ត្រីនិងជនជាតិដើមភាគតិច នៅខ្វះវត្តមានតំណាងបំពេញការងារនៅក្នុងវិស័យយុត្តិធម៌។ បច្ចុប្បន្ននេះវត្តមានមេធាវីចៅក្រម និងព្រះរាជអាជ្ញាជាស្ត្រីនៅមានចំនួនតិចតួចនៅឡើយ។[28] គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៩ នៅក្នុងចំណោមចៅក្រមសរុបចំនួន៣០០នាក់ ដែលកំពុងបំពេញការងារនៅក្នុងតុលាការនិងស្ថាប័ន(មិនរួមបញ្ចូលសិក្ខាកាម) មានវត្តមានស្ត្រីត្រឹមតែ៤៦នាក់ប៉ុណ្ណោះ និងក្នុងចំណោមព្រះរាជអាជ្ញារចំនួន១៦៦ ដែលកំពុងបំពេញការងារនៅក្នុងតុលាការនិងស្ថាប័ន(មិនរួមបញ្ចូលសិក្ខាកាម) មានវត្តមានស្ត្រីត្រឹមតែ ២៥ នាក់ប៉ុណ្ណោះ ដែលតំណាងឲ្យប្រមាណជា១៥ភាគរយក្នុងអាជីពនីមួយៗ។ ស្ថិតិនេះបង្ហាញការកើនឡើងតិចតួចប៉ុណ្ណោះចាប់តាំងពីឆ្នាំ២០១៣ ដែលនៅពេលនោះមានវត្តមានចៅក្រមជាស្ត្រីចំនួន១៤ភាគរយ និងវត្តមានព្រះរាជអាជ្ញារជាស្ត្រីចំនួន១០ភាគរយ។[29] គិតត្រឹមខែមិនា ឆ្នាំ២០២១ ក្នុងចំណោមមេធាវីសរុបចំនួន២,៣៦៩នាក់ មានបុរសចំនួន១,៧៩៥នាក់និងស្ត្រីចំនួន៥៧៤នាក់ (ឬប្រមាណជា២៤ភាគរយ)។[30] ជាទូទៅជនជាតិដើមភាគតិចនៅតែបន្តខ្វះវត្តមានតំណាងនៅក្នុងវិស័យយុត្តិធម៌ និងវិស័យច្បាប់ដដែល។ រហូតមកទល់ពេលនេះមានជនជាតិដើមភាគតិចតែម្នាក់គត់ ដែលមានតួនាទីជាចៅក្រម ឬព្រះរាជអាជ្ញាគឺប្រធានតុលាការខេត្តស្ទឹងត្រែង និងក្រឡាបញ្ជីតែពីរឬបីនាក់ប៉ុណ្ណោះ។ ទោះយ៉ាងនេះក្តីនៅឆ្នាំ២០២០ គេឃើញមានវត្តមានមេធាវីជនជាតិដើមភាគតិចចំនួន៨នាក់ ដែលក្នុងនោះ៥នាក់ជាស្ត្រី ហើយក៏មានអង្គការមិនមែនរដ្ឋាភិបាលដែលជាជនជាតិដើមភាគតិច កំពុងជំរុញយុវជនជនជាតិដើមភាគតិចឲ្យសិក្សាផ្នែកច្បាប់ផងដែរ។

សាលាដំបូងមានទីតាំងស្ថិតនៅទីរួមខេត្ត និងរាជធានី ប៉ុន្តែសហគមន៍ជនជាតិដើមភាគតិចភាគច្រើនជាទូទៅរស់នៅក្នុងតំបន់ជនបទឆ្ងាយពីទីប្រជុំជន។ រយៈចម្ងាយនិងគុណភាពផ្លូវដែលត្រូវធ្វើដំណើរពីភូមិទៅកាន់ទីរួមខេត្តបានក្លាយទៅជាឧបសគ្គដល់ស្ត្រីជនជាតិដើមភាគតិច ក្នុងការធ្វើដំណើរទៅមកតុលាការ។ បន្ថែមលើនេះគិតត្រឹមខែមេសា ឆ្នាំ២០២០ សាលាឧទ្ធរណ៍មានតែមួយគត់នៅក្នុងប្រទេសកម្ពុជា ហើយ

[27] សេចក្តីសំណើររួមគ្នារបស់សង្គមស៊ីវិល នៅក្នុងរបាយការណ៍ស្រមោល ស្តីពីសិទ្ធិទទួលបានយុត្តិធម៌ សម្រាប់កិច្ចប្រជុំលើកទី៧៤ ដែលបានបញ្ជូនទៅ គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងស្ត្រី (CEDAW នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៩។

[28] របាយការណ៍ខាងលើ។

[29] សេចក្តីសំណើររបស់ NGO-CEDAW នៅក្នុងកិច្ចប្រជុំលើកទី៧៤ (ថ្ងៃទី២១ ខែតុលាដល់ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៩) របស់ គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងស្ត្រី (CEDAW) ។

[30] https://www.bakc.org.kh/index.php/en/2020-02-02-04-06-24.

មានទីតាំងស្ថិតនៅរាជធានីភ្នំពេញ ដែលជាបន្ទុកបន្ថែមសម្រាប់ស្ត្រីជនជាតិដើមភាគតិចដែលរស់នៅខេត្តឆ្ងាយដើម្បីបន្តស្វែងរកយុត្តិធម៌នៅកម្រិតបណ្តឹងឧទ្ធរណ៍។ សាលាឧទ្ធរណ៍ថ្នាក់តំបន់ត្រូវបានបង្កើតឡើងចំនួន៣ បន្ថែមទៀតនៅក្នុងឆ្នាំ២០២០ ដែលមានទីតាំងស្ថិតនៅខេត្តបាត់ដំបង និងត្បូងឃ្មុំ[31] ដែលគ្របដណ្តប់ខេត្តដែលសហគមន៍ជនជាតិដើមភាគតិចរស់នៅផងដែរ និងខេត្តព្រះសីហនុ។[32] ក្រៅពីការចំណាយថវិកា និងពេលវេលាធ្វើដំណើរទៅមកតុលាការ បញ្ហាប្រឈមទាក់ទងនិងការថែទាំកុមារ និងមនុស្សចាស់ដែលភាគច្រើនធ្លាក់មកលើស្ត្រី[33] ក៏បានជះឥទ្ធិពលមកលើលទ្ធភាពចូលរួមនៅក្នុងដំណើរការនីតិវិធីដ៏វែងរបស់តុលាការ របស់ស្ត្រីជនជាតិដើមភាគតិចដែលរងគ្រោះដោយអំពើហិង្សាផ្អែកលើយេនឌ័រ។

## ៣.២. ប្រព័ន្ធគ្រប់គ្រងច្បាប់បែបប្រពៃណីនិងយន្តការដោះស្រាយទំនាស់

ការសិក្សាមួយធ្វើឡើងដោយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ(UNDP)ក្នុងឆ្នាំ២០០៧ បានឲ្យដឹងថាគ្មានការចងក្រងទុកជាឯកសារលាយលក្ខណ៍ស្តីពីច្បាប់ប្រពៃណីទំនៀមទំលាប់ និងដំណើរការនៃនីតិវិធីដោះស្រាយទំនាស់នៅកម្ពុជាដែរ ខុសពីប្រព័ន្ធច្បាប់ផ្លូវការដែលមានការចងក្រងជាក់លាក់។ គោលដៅចម្បងនៃយន្តការដោះស្រាយទំនាស់បែបប្រពៃណី គឺដើម្បីរក្សាសាមគ្គីភាពនៅក្នុងសហគមន៍។ ដោយចាត់ទុកការថែរក្សាភាពសុខដុមរមនាជាចម្បងនោះ ការដោះស្រាយវិវាទ គឺមានគោលបំណងធ្វើយ៉ាងណាឲ្យភាគីទំនាស់ឈានដល់ការព្រមព្រៀងតាមរយៈការផ្តល់សំណងដល់ភាគីរងគ្រោះ និងដាក់ទោសអ្នកដែលប្រព្រឹត្តកំហុស។[34] យន្តការនេះខុសគ្នាពីប្រព័ន្ធច្បាប់ផ្លូវការដែលអនុវត្តច្បាប់ដែលមានស្រាប់ទៅលើបុគ្គលគ្រប់រូប ។

ភាពតានតឹងរវាងយន្តការដោះស្រាយវិវាទបែបប្រពៃណី និងប្រព័ន្ធច្បាប់ផ្លូវការបានកើតឡើងនៅក្នុងករណីបទល្មើសឧក្រិដ្ឋ។ អនុលោមតាមច្បាប់កម្ពុជា មន្ត្រីនគរបាលយុត្តិធម៌គួរតែស៊ើបអង្កេតករណីឧក្រិដ្ឋកម្ម ហើយជនត្រូវចោទត្រូវទទួលការកាត់ទោស និងផ្តន្ទាទោសនៅក្នុងប្រព័ន្ធតុលាការដែលជាស្ថាប័នតែមួយគត់ដែលមានអាណត្តិក្នុងការកំណត់ពីភាពមានទោស ឬគ្មានទោសកំហុសរបស់ជនជាប់ចោទ។ ដូច្នោះ សហគមន៍ជនជាតិដើមភាគតិច ត្រូវបានជំរុញដោយអាជ្ញាធរមូលដ្ឋានឲ្យធ្វើរាយការណ៍អំពីឧក្រិដ្ឋកម្មទាំង

---

[31] ដេវិឌ, ស. (២ មេសា ២០២០)។ កាសែតខ្មែរថាមស៍៖សាលាឧទ្ធរណ៍ថ្មីចំនួន២ក្នុងចំណោម៣ ចាប់បើកសាវនាការ។ រកបាននៅ https://www.khmertimeskh.com/708511/two-of-three-new-appeal-courts-start-hearings/ ដកស្រង់នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២០។

[32] ដេវិឌ, ស. (៧ កញ្ញា ២០២០)។ កាសែតខ្មែរថាមស៍៖ សាលាឧទ្ធរណ៍ខេត្តព្រះសីហនុចាប់ផ្តើមដំណើរការពេញលេញ។ រកបាននៅ https://www.khmertimeskh.com/50761092/preah-sihanouk-appeal-court-in-full-service/ ដកស្រង់នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០២០។

[33] ការសិក្សាទៅលើតួនាទីយេនឌ័រ ធ្វើឡើងក្នុងឆ្នាំ២០១៣ ដោយអង្គការសហប្រជាជាតិ បានរកឃើញថា មាន៨២%នៃបុរស និង៩៣%នៃស្ត្រី ជឿជាក់ថា តួនាទីដ៏សំខាន់របស់ស្ត្រីគឺការមើលថែផ្ទះសម្បែង និងការរៀបចំម្ហូបម្ហារសម្រាប់គ្រួសារ។ ហ្វូលូ, អ៊ី, វ៉ាននឺរ, អេក្ស, ម៉ៃខែម៉ា, ស., ជូកេស, រ., រ៉ូស៊ែលី, ធី. និង លាង, ជេ (ឆ្នាំ២០១៣)។ ហេតុអ្វីបានជាបុរសខ្លះប្រើអំពើហិង្សាប្រឆាំងស្ត្រី និងតើយើងអាចទប់ស្កាត់បានយ៉ាងដូចម្តេច? របកគំហើញបែបបរិមាណវិស័យពីការសិក្សាពហុប្រទេសរបស់អង្គការសហប្រជាជាតិ ស្តីពី បុរស និងអំពើហិង្សាក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក។ ដោយ UNDP, UNFPA, UN Women និង UNV។ ទីក្រុងបាងកក។

[34] ប៉ៃកស្ត្រម, អឹម., អ៊ីរ៉ែនសាដ, ជេ., ភីតធើស៊ុន, ជី., ផេដរី, ជេ., & ប៊ឺដ, អាយ. (ឆ្នាំ២០០៧)។ យន្តការដោះស្រាវិវាទបែបប្រពៃណីជនជាតិដើមភាគតិច និងយន្តការដំណោះស្រាយវិវាទផ្លូវច្បាប់នៅក្នុងខេត្តរតនគិរី និងមណ្ឌលគិរី ក្នុងប្រទេសកម្ពុជា។ ដោយ UNDP។ ទីក្រុងបាងកក។

អស់មកកាន់អាជ្ញាធរមូលដ្ឋាន និងនគបាលយុត្តិធម៌ដើម្បីស្វែងរកដោះស្រាយតាមប្រព័ន្ធច្បាប់ផ្លូវការ។

ចំពោះករណីទំនាស់តូចៗ តួយ៉ាងទំនាស់នៅក្នុងគ្រួសារ និងទំនាស់រវាងសមាជិកសហគមន៍ អាចត្រូវបានដោះស្រាយតាមរយៈ "Kra Srok"[35] ចាស់ព្រឹទ្ធាចារ្យដែលជាទូទៅគឺជាបុរសវ័យចំណាស់ដែលមានចៅ និងត្រូវបានទទួលស្គាល់ពីសហគមន៍ថាមានចំណេះដឹង មានប្រាជ្ញា ទេពកោសល្យ និងបទពិសោធន៍។ "Kra srok" ជានិមិត្តរូបតំណាងឲ្យសន្តិភាពនៅក្នុងភូមិ ប៉ុន្តែគ្មានលទ្ធភាព និងគ្មានការទទួលស្គាល់ថាអាចប្រើអំណាចផ្លូវច្បាប់ណាមួយនិងមិនអាចបង្ខំឲ្យអ្នកភូមិប្រព្រឹត្តតាមរបៀបបែបណានោះទេ លុះត្រាតែគាត់ត្រូវបានសហគមន៍អញ្ជើញឲ្យធ្វើបែបនោះ។ ទោះបីជាក្នុងករណីបែបនោះក៏ដោយ គាត់នឹងធ្វើការងារនោះក្នុងឋានៈជា "អ្នកប្រឹក្សាយោបល់" ជាជាងជាអ្នកធ្វើការសម្រេចចិត្តដោយឯកតោភាគី"។[36]

ការសិក្សាដែលបានទទួលការឧបត្ថម្ភពីUNDP ក្នុងឆ្នាំ២០០៧ក៏បានកត់សម្គាល់ថា " ... ប្រព័ន្ធច្បាប់បែបប្រពៃណីរបស់ក្រុមជនជាតិដើមភាគតិចគឺស្រដៀងគ្នា ទោះបីជាភាពខុសគ្នាមួយចំនួនរវាងក្រុមជនជាតិដើមនីមួយៗ និងរវាងភូមិនីមួយៗក៏ដោយ" ជាទូទៅការដំណោះស្រាយទំនាស់តាមបែបប្រពៃណីគឺតែងតែអនុវត្តតាមនីតិវិធីខាងក្រោមនេះ៖

១. បុគ្គលដែលមានអារម្មណ៍ថាអ្នកណាម្នាក់បានប្រព្រឹត្តខុសឆ្គងមកលើខ្លួន អាចរៀបចំបណ្តឹងប្រឆាំងនឹងជននោះដើម្បីទាមទារឲ្យមានការទទួលខុសត្រូវ តាមរយៈការទៅជួបបុគ្គលនោះដោយផ្ទាល់ ឬក្នុងករណីដែលជឿជាក់ថាកំហុសមានសភាពធ្ងន់ធ្ងរនោះគេអាចពឹងពាក់សម្រុះសម្រួល /អ្នកស៊ើបអង្កេតដើម្បីពិនិត្យមើលការចោទប្រកាន់ និងរកមធ្យោបាយដើម្បីឈានទៅដល់ការព្រមព្រៀងគ្នា។
២. ប្រសិនបើអ្នកសម្រុះសម្រួលមិនអាចនាំភាគីពាក់ព័ន្ធឲ្យរកដំណោះស្រាយបានទេ ភាគីអាចនាំគ្នាទៅរកអ្នកវិនិច្ឆ័យ (ដែលអាចជាមនុស្សម្នាក់រឺច្រើននាក់ដែលភាគីទាំងសងខាងស្នើសុំឲ្យជួយដោះស្រាយបញ្ហា)។
៣. នៅក្នុងសហគមន៍ចារ៉ាយ កាចក់ និងទំពួន គឺចាស់ទុំដែលជួនកាលជាស្ត្រីវ័យចំណាស់ ជាអ្នកស្តាប់របកគំហើញដែលរកឃើញដោយអ្នកសម្រុះសម្រួល/អ្នកស៊ើបអង្កេត និងការសម្រេចចិត្តត្រូវបានធ្វើឡើងតាមសម្លេងភាគច្រើននៃចាស់ទុំ។
៤. ភាគីអាចបន្តដាក់បណ្តឹងទៅអ្នកកាត់ក្តីដទៃ ឬចាស់ទុំដទៃទៀត ឬអាជ្ញាធរថ្នាក់លើ ប្រសិនបើពួកគេមិនយល់ស្របនឹងសេចក្តីសំរេចរបស់ចាស់ទុំទេ។[37]

---

[35] នេះគឺជាវាក្យស័ព្ទជនជាតិដើមភាគតិចទំពួនដោយឡែកក្រុមជនជាតិដើមភាគតិចផ្សេងៗ មានឈ្មោះខុសៗគ្នា សម្រាប់មុខងារមួយនេះ។

[36] Bourdier, F., ឆ្នាំ២០១៥។ ជនជាតិដើមភាគតិចនៅតំបន់អាស៊ីអាគ្នេយ៍៖ កម្ពុជា។ ឆៀងម៉ៃ៖មូលនិធិបណ្តុំជនជាតិដើមភាគតិចតំបន់អាស៊ីអាគ្នេយ៍ ទំព័រ ១២-១៣ អាចរកបាននៅ https://aippnet.org/wp-content/uploads/2020/02/10-Asean-study_Cambodia_15_July_2015_Final.pdf ដកស្រង់នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១។

[37] ប៊ែកស្ត្រម, អឹម., អ៊ីវ៉ែនសាដ, ជេ., ភីតធើស៊ុន, ជី., ផេដរី, ជេ., & ប៊ីដ, អាយ. (ឆ្នាំ២០០៧)។ យន្តការដោះស្រាវិវាទបែបប្រពៃណីជនជាតិដើមភាគតិច និងយន្តការដំណោះស្រាយវិវាទផ្លូវច្បាប់នៅក្នុងខេត្តរតនគិរី និងមណ្ឌលគិរី ក្នុងប្រទេសកម្ពុជា។ ដោយ UNDP។ ទីក្រុងបាងកក។ ទំព័រ ២៥-២៦

ដំណោះស្រាយភាគច្រើនពាក់ព័ន្ធនិងការទូរទាត់បង់ប្រាក់ពិន័យដល់ភាគីដែលរងការខូចខាត ឬភាគីដែលជាអ្នកមានកំហុស អាចត្រូវបានបញ្ជាឲ្យធ្វើការងារឲ្យជនរងគ្រោះជាការដាក់ទណ្ឌកម្ម។ ជួនកាលភាគីទាំងសងខាង ទាំងអ្នករងការខូចខាត និងភាគីមានកំហុសចូលរួមផ្តល់បដិភាគសម្រាប់ការចំណាយរៀបចំពិធីផ្សះផ្សារ។ ជួនកាលអ្នកសម្រុះសម្រួល និងអ្នកវិនិច្ឆ័យក៏អាចទទួលបានការទូទាត់ប្រាក់សម្រាប់ការងាររបស់ពួកគេផងដែរ។[38]

ស្ត្រីមេធាវីជនជាតិដើមភាគតិចម្នាក់បានផ្តល់ការអត្ថាធិប្បាយទៅលើវិធានការណ៍ដោះស្រាយបែបប្រពៃណីរបស់ជនជាតិពូនង ពាក់ព័ន្ធនឹងករណីអំពើហិង្សាផ្អែកលើយេនឌ័រ។ គាត់បានពន្យល់ថា ចាស់ទុំសហគមន៍បានអនុវត្តវិធាននេះយូរយារមកហើយ ដែលរៀបចំឡើងក្នុងគោលដៅដើម្បីការពារសហគមន៍ទប់ស្កាត់អាកប្បកិរិយាដែលមិនសមរម្យនាថ្ងៃអនាគត ហើយទប់ស្កាត់កុំឲ្យមានការខឹងសម្បារពីសំណាក់ព្រលឹងអារក្សដោយសារតែអាកប្បកិរិយាទាំងនេះ។ គាត់បានបន្តលើកឡើងថាប្រសិនបើមានស្ត្រីណាម្នាក់ត្រូវបានរំលោភសេពសន្ថវៈ គ្រួសារនាងនឹងត្រូវជូនដំណឹងដល់សមាជិកគ្រួសារដ៏ទៃទៀត ហើយដោយសារតែព័ត៌មានបែបនេះមិនអាចលាក់បាំងបានផងនោះរឿងនេះក៏នឹងបានដឹងលឺដល់ចាស់ទុំ។

នៅក្នុងករណីនៃអំពើរំលោភសេពសន្ថវៈដែលទើបកើតឡើងថ្មីមួយនៅក្នុងខេត្តមណ្ឌលគិរី ដែលបុរសជាឪពុកបង្កើតត្រូវបានចោទប្រកាន់ពីបទរំលោភសេពសន្ថវៈទៅលើកូនស្រី និងត្រូវបានឃុំឃាំងនៅក្នុងពន្ធនាគារនោះ។ យោងតាមច្បាប់ទំនៀមទម្លាប់របស់សហគមន៍ ជាអកុសល្យគ្រួសារនេះត្រូវផ្តល់សំណងដល់សហគមន៍ចំពោះទង្វើខុសឆ្គងរបស់បុរសជាឪពុក។ ខណៈដែលឪពុកកំពុងជាប់នៅក្នុងពន្ធនាគារនោះការទទួលខុសត្រូវទាំងអស់ក្នុងការរៀបចំពិធីសែនព្រេនសាសនាដើម្បីលួងលោមអារក្សនិងលិះលាង(សង) សហគមន៍បានធ្លាក់មកជាបន្ទុករបស់ជនរងគ្រោះ និងម្តាយរបស់នាង។ ក្នុងករណីនេះផងដែរចាស់ទុំក៏បានស្នើឲ្យជនរងគ្រោះចាកចេញពីភូមិ។ លោកស្រីមេធាវីក៏បានបន្ថែមថាក្នុងករណីខ្លះជនរងគ្រោះខ្លួនឯងបានសម្រេចចិត្តចាកចេញពីភូមិដើម្បីគេចពីភាពខ្មាសអៀន។

នៅក្នុងករណីខ្លះការអនុវត្តច្បាប់ប្រពៃណីមួយចំនួនត្រូវបានលើកលែង ប៉ុន្តែទាមទារឲ្យសហគមន៍ផ្តល់ការឯកភាពលើចំណុចដែលត្រូវផ្លាស់ប្តូរជាក់លាក់។ ឧទាហរណ៍បើអនុវត្តន៍តាមប្រពៃណីទាំងស្រុងនៅក្នុងករណីដែលស្លាប់ដោយគ្រោះថ្នាក់ចៃដន្យ ឬស្លាប់ដោយសារជម្ងឺនោះ មានតែសមាជិកគ្រួសារនៃសពប៉ុណ្ណោះដែលអនុញ្ញាតិឲ្យចូលរួមនៅក្នុងពិធីបុណ្យសព។ ប៉ុន្តែជាក់ស្តែងសហគមន៍ជនជាតិដើមភាគតិច

[38] ដូចខាងលើ។ ទំព័រ២៣។ ពិនិត្យមើល Bourdier, F., ឆ្នាំ២០១៥។ ជនជាតិដើមភាគតិចនៅតំបន់អាស៊ីអាគ្នេយ៍៖ កម្ពុជា។ ឆៀងម៉ៃះមូលនិធិបណ្តុំជនជាតិដើមភាគតិចតំបន់អាស៊ីអាគ្នេយ៍ ទំព័រ ១២-១៣ អាចរកបាននៅ https://aippnet.org/wp-content/uploads/2020/02/10-Asean-study_Cambodia_15_July_2015_Final.pdf ដកស្រង់នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១។

នៅក្នុងខេត្តរតនគិរី បានឯកភាពអនុញ្ញាតិឲ្យអ្នកដែលមិនមែនជាសមាជិកគ្រួសារចូលរួមនៅក្នុងពិធីបុណ្យសព និងជួយក្នុងការប្រមូលបច្ច័យជាធនធាន ឬសម្ភារៈចាំបាច់នានាសម្រាប់រៀបចំពិធីបុណ្យបាន។

នៅតាមតំបន់មួយចំនួនចាស់ទុំ/មេដឹកនាំប្រពៃណីមិនចូលរួមដោះស្រាយករណីអំពើហិង្សាផ្អែកលើយេនឌ័រនោះទេ។ ឧទាហរណ៍មានករណីមួយដែលបានកើតឡើងនៅក្នុងខេត្តស្ទឹងត្រែង ដែលសមាជិកសហគមន៍ទាំងមូលបានដឹងថាបុរសជាឪពុកបានរំលោភបំពានទៅលើកូនស្រី ដែលទង្វើនេះគឺមិនត្រូវបានអនុញ្ញាតិឡើយផ្អែកទៅលើច្បាប់ប្រពៃណីរបស់ជនជាតិព្នង ប៉ុន្តែចាស់ទុំមិនបានអន្តរាគមន៍ឡើយដោយសារតែពួកគេខ្លាចបុរសនោះដោយសារដឹងថាគាត់ជាមនុស្សឃោឃៅ។ មានការរំពឹងទុកថាមេដឹកនាំប្រពៃណីនឹងចូលរួមដោះស្រាយទំនាស់ ប៉ុន្តែបច្ចុប្បន្ននេះឥទ្ធិពលរបស់ពួកគេបានធ្លាក់ចុះ ដូច្នេះហើយពួកគេទទួលខុសត្រូវតែលើកិច្ចការសែនព្រេន និងពិធីសាសនាប៉ុណ្ណោះ។

ករណីទំនាស់មួយចំនួនដែលកើតឡើងរវាងយន្តការនៃការដោះស្រាយវិវាទតាមបែបប្រពៃណី និងនីតិវិធីរដ្ឋបាល និងនីតិវិធីច្បាប់ខ្មែរ បានធ្វើឲ្យការដឹកនាំបែបប្រពៃណីចុះខ្សោយ។ ស្ត្រីជនជាតិដើមភាគតិចម្នាក់ផ្តល់សក្ខីកម្មនៅក្នុងឆ្នាំ២០២០[39]ថា "មេដឹកនាំប្រពៃណីរបស់យើងគ្មានឥទ្ធិពលខ្លាំងទេបច្ចុប្បន្ននេះ ពីព្រោះមេភូមិ[40] បានតម្រូវឲ្យសហគមន៍រាយការណ៍អំពីគ្រប់ករណីជម្លោះទាំងអស់ទៅគាត់ជាជាងធ្វើសេចក្តីរាយការណ៍ទៅមេដឹកនាំប្រពៃណី បើសិនជាយើងចង់មានសណ្តាប់ធ្នាប់និងការអភិវឌ្ឍន៍នៅក្នុងសហគមន៍។ ប្រជាពលរដ្ឋក្នុងសហគមន៍ អនុវត្តតាមការណែនាំរបស់ពួកគេដោយសារតែគាត់គឺជាមន្ត្រីរដ្ឋាភិបាល"។ ការសិក្សាមួយធ្វើឡើងដោយអង្គការ Asia Indigenous Peoples Pact នៅក្នុងឆ្នាំ២០១៥ ក៏បានរកឃើញដូចគ្នាដែរដោយបានកត់សម្គាល់ថា អ្នកភូមិត្រូវបានស្នើឲ្យរាយការណ៍អំពីករណីទំនាស់នានាកាន់មេភូមិ និងមេឃុំ ដោយសារតែមេភូមិ "មេភូមិដែលបានជ្រើសរើសជាច្រើនមានទំនាក់ទំនងដែលមិនអាចខ្វះបានទៅនឹងកម្លាំងនគបាលនិងមន្ត្រីតុលាការខេត្ត"។[41]

ការសិក្សាមួយដែលធ្វើឡើងដោយអង្គការ CARE Cambodia បញ្ជាក់ថាការផ្លាស់ប្តូរការអនុវត្តបែបប្រពៃណីគឺអាចកើតឡើងបាន។ ការសិក្សានេះបានអះអាងថាធនធានដែលសហគមន៍ជនជាតិដើមភាគតិចមានស្រាប់អាចជួយពួកគេក្នុងការសម្របសម្រួលការផ្លាស់ប្តូរបាន៖ "ការរក្សាទុកនូវអក្សរសិល្ប៍ផ្ទាល់

---

[39] គាត់បានផ្តល់សក្ខីកម្ម នៅពេលគាត់បានចូលរួមនៅក្នុងសិក្ខាសាលាបណ្តុះបណ្តាលមួយក្នុងខេត្តរតនគិរី ស្តីពីអនុសញ្ញា CEDAW និងអំពើហិង្សាផ្អែកលើយេនឌ័រ ដែលបានរៀបចំឡើងដោយ NGO-CEDAW និងគ្រូបណ្តុះបណ្តាលដឹកនាំដោយតំណាងនៃអង្គការក្លាហាន នៅក្នុងខែតុលា ឆ្នាំ២០២០។

[40] មេភូមិគឺជាផ្នែកមួយនៃប្រព័ន្ធរដ្ឋបាលផ្លូវការ ដែលមិនត្រូវបានបោះឆ្នោតជ្រើសរើសដោយសហគមន៍ទេ ប៉ុន្តែបានតែងតាំងដោយក្រុមប្រឹក្សាឃុំ។ តាមមាត្រា ២២នៃអនុក្រឹត្យស្តីពី វិមជ្ឈការអំណាច តួនាទី និងភារកិច្ចនៃក្រុមប្រឹក្សាឃុំ ចុះថ្ងៃទី ១មេសា ឆ្នាំ២០០២។

[41] Bourdier, F., ឆ្នាំ២០១៥។ ជនជាតិដើមភាគតិចនៅតំបន់អាស៊ីអាគ្នេយ៍៖ កម្ពុជា។ ឆៀងម៉ៃ៖ មូលនិធិបណ្តុំជនជាតិដើមភាគតិចតំបន់អាស៊ីអាគ្នេយ៍ ទំព័រ ១២-១៣ អាចរកបាននៅ https://aippnet.org/wp-content/uploads/2020/02/10-Asean-study_Cambodia_15_July_2015_Final.pdf ដកស្រង់នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១។

មាត់ និងវប្បធម៌សាសនាជាច្រើនដែលអាចផ្តល់ឲ្យពួកគេនូវនិមិត្តសញ្ញា វាក្យស័ព្ទ ដើម្បីបកស្រាយព្រឹត្តិការណ៍ថ្មីៗ ដែលអាចដាក់បញ្ចូល និងបង្កើតនិមិត្តសញ្ញាជនជាតិដើមភាគតិច[...] និងប្រព័ន្ធច្បាប់ក្នុងស្រុក និងវិធីសាស្រ្តដំណោះស្រាយវិវាទមូលដ្ឋានដែលបានផ្លាស់ប្តូរយ៉ាងឆាប់រហ័សផ្អែកទៅតាមកាលៈទេសៈដូច្នេះអាចសម្រួលឲ្យប្រព័ន្ធដោះស្រាយវិវាទបែបប្រពៃណីអាចបន្តដោះស្រាយវិវាទក្នុងពេលបច្ចុប្បន្ននេះ[...] ដែលមិនធ្លាប់កើតឡើងក្នុងចន្លោះពេលពីរឬបីទសវត្សរ៍កន្លងមកនេះ[និង] មានការយល់ដឹងកាន់តែច្បាស់លាស់អំពីភាពចាំបាច់ក្នុងការផ្លាស់ប្តូរ និងដឹងថាកុមារជនជាតិដើមភាគតិចបច្ចុប្បន្ននេះនឹងត្រូវការជំនាញផ្សេងៗខុសពីជំនាន់ឪពុកម្តាយរបស់ពួកគេនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។

ការសិក្សាដដែលនេះក៏បានអះអាងថា "សញ្ញាណដើមនៃអត្តសញ្ញាណរបស់ជនជាតិដើមភាគតិចមិនបានប្រែប្រួលដោយសារតែការអនុវត្តតាមប្រពៃណីយ៉ាងតឹងរឹងនោះទេ ផ្ទុយទៅវិញការវិវត្តនៃបទដ្ឋានសង្គមនិងកាតព្វកិច្ចរបស់មនុស្សពីមួយជំនាន់ទៅមួយជំនាន់ បាននាំឲ្យសហគមន៍ទទួលបានភាពសុខដុមរមនាមួយកម្រិតថែមទៀត។ [...]ប្រជាពលរដ្ឋជនជាតិដើមភាគតិចមិនបានរំពឹងថាការផ្លាស់ប្តូរនឹងត្រូវបញ្ឈប់នោះទេ។ ផ្ទុយទៅវិញ ពួកគេស្វះស្វែងរកឧបករណ៍នានាជម្រុញឲ្យមានការអភិវឌ្ឍ និងពង្រឹងសមត្ថភាពចាំបាច់ដើម្បីធានាថាកូនចៅៗរបស់ពួកគេអាចទទួលបានភាពជោគជ័យនៅក្នុងជីវិត ខណៈដែលពួកគេជ្រើសរើសផ្លូវជីវិតដែល "ត្រឹមត្រូវ"។[42]

ទស្សនៈនេះក៏ទទួលបានការគាំទ្រពីសំណាក់ អ្នកជំនាញឯករាជ្យក្នុងវិស័យសិទ្ធិផ្នែកវប្បធម៌ផងដែរ។ គាត់បញ្ជាក់ថា "តម្រូវការចាំបាច់នៅក្នុងសហគមន៍នោះគឺការពង្រឹងនូវការអនុវត្តវប្បធម៌វិជ្ជមាន ខណៈលើកកម្ពស់ការយល់ដឹងអំពីការអនុវត្តប្រពៃណីជាក់លាក់មួយចំនួនដែលមានចរិកលក្ខណៈសង្កត់សង្កិន ក្រោមស្លាកនៃការថែរក្សាវប្បធម៌ ពីព្រោះគេអាចបង្កើតដំណើរការនៃ"ចរចារផ្នែកប្បធម៌"នៅក្នុងចំណោមសមាជិកគ្រួសារ បញ្ញាវ័ន្ត និងអ្នកដឹកនាំសហគមន៍បាន។ ដំណើរការនេះអាចផ្តល់ឪកាសសម្រាប់ការបកស្រាយបទបរិយាយថ្មីៗ និងអភិវឌ្ឍការអនុវត្តវប្បធម៌ល្អៗ ជាពិសេសវប្បធម៌ដែលអាចជម្រុញការអនុវត្តសិទ្ធិមនុស្សជាសកលនៅក្នុងបរិបទវប្បធម៌ផ្សេងៗគ្នា"។[43]

## ៤. របកគំហើញ និងការវិភាគ

### ៤.១ ទិដ្ឋភាពទូទៅនៃអ្នកផ្តល់បទសម្ភាសនិងករណីអំពើហិង្សា

CIWWG បានធ្វើបទសម្ភាសជាមួយអ្នកផ្តល់បទសម្ភាសចំនួន៥ក្រុមផ្សេងគ្នា៖ អាជ្ញាធរមូលដ្ឋាន ជនរង

---

[42] ភើរេស ភើរ៉េរ៉ូ, អ., ឡូប៉េ ខទីណា, ជេ., ប្រ៉េហ្គាន ខនស៊ុលធីង, "ការមានផ្ទៃពោះក្នុងវ័យជំទង់& អាពាហ៍ពិពាហ៍វ័យក្មេងនៅក្នុង ចំណោម សហគមន៍ជនជាតិដើមភាគតិចនៅភាគឥសាន្តនៃប្រទេសកម្ពុជា", អង្គការ CARE Cambodia, ២០១៨, ទំព័រ ៣៩-៤០។

[43] របាយការណ៍អ្នកជំនាញឯករាជ្យក្នុងវិស័យសិទ្ធិវប្បធម៌ Ms. Farida Shaheed (A/HRC/14/36, ថ្ងៃទី២២ ខែមីនា ឆ្នាំ ២០១០) កថាខណ្ឌ ៣៦ បានដកស្រង់ចេញពីរបាយការណ៍អ្នករាយការណ៍ពិសេស ស្តីពីអំពើហិង្សាប្រឆាំងស្ត្រី, ឬសគល់ និងផលវិបាករបស់អំពើហិង្សា, Yakin Erturk (E/CN.4/2004/66), កថាខណ្ឌ ៥៥ (b)។

គ្រោះរស់រានមានជីវិត ជនរងគ្រោះ /គ្រួសាររងគ្រោះសាក្សី និងមេដឹកនាំប្រពៃណី។




- ជនរងគ្រោះរស់រានមានជីវិតជាស្រ្តី ដែលមានអាយុចាប់ពី១១ទៅ៥៣ឆ្នាំ ចំនួន១០នាក់បានផ្តល់បទសម្ភាស។ ក្នុងនោះមានម្នាក់ជាជនជាតិពូនង បីនាក់ជាជនជាតិ ចារ៉ាយ ប្រាំនាក់ជាជនជាតិគ្រឹង និងម្នាក់ជាជនជាតិដើមភាគតិចព្រៅ។

- ក្រុមគ្រួសារជនរងគ្រោះរស់រានមានជីវិតចំនួន ១៤នាក់ក្នុងនោះមានបុរសចំនួន០៦នាក់(ភាគច្រើនជាឪពុក) និងស្រ្តីចំនួន០៧នាក់(ម្តាយឬយាយ) បានផ្តល់បទសម្ភាស។ ក្នុងចំណោមនោះមាន បីនាក់ជាជនជាតិពូនង ពីរនាក់ជាជនជាតិចារ៉ាយ ម្នាក់ជាជនជាតិកាចក់ បួននាក់ជាជនជាតិគ្រឹង ពីរនាក់ជាជនជាតិព្រៅ និងពីរនាក់ផ្សេងទៀតជាជនជាតិទំពួន។

- អាជ្ញាធរមូលដ្ឋានចំនួន១៩នាក់បានផ្តល់បទសម្ភាសន៖ ប្រធានភូមិចំនួន១៥នាក់ អនុប្រធានភូមិចំនួន០៣នាក់ និងសមាជិកក្រុមប្រឹក្សាឃុំចំនួន០១នាក់។ ក្នុងចំណោមប្រធានភូមិចំនួន១៥នាក់មានបុរសចំនួន១២និងស្រ្តីចំនួន០៣នាក់។ អនុប្រធានភូមិជាស្រ្តីចំនួន០២នាក់និងបុរស០១នាក់។ សមាជិកក្រុមប្រឹក្សាឃុំជាបុរស០១នាក់។ ក្នុងចំណោមនោះមាន ជនជាតិដើមភាគតិចចារ៉ាយច្រើនជាងគេដោយមានអាជ្ញាធរមូលដ្ឋានចំនួន០៥នាក់ ដែល ០២នាក់ជាស្រ្តី។(ពិនិត្យតារាងខាងក្រោម)

អាជ្ញាធរមូលដ្ឋាន ត្រូវបានសម្ភាសដោយសារតែពួកគេបានធ្វើការជិតស្និទ្ធបំផុតជាមួយសហគមន៍ជនជាតិដើមភាគតិចរួមទាំងការចូលរួមដោះស្រាយវិវាទ។ ក្រៅពីការតាំងការិយាល័យនៅក្បែរសហគមន៍ភាគច្រើនពួកគេក៏ជាជនជាតិដើមភាគតិចដែរ ហើយពួកគេមានការយល់ដឹងច្រើនអំពីវប្បធម៌និងប្រពៃណីរបស់ជនជាតិដើមភាគតិច បើទោះបីជាពួកគេត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោត ឬក្នុងករណីមេភូមិ ត្រូវបានតែងតាំងដោយអាជ្ញាធរឃុំ ដែលខុសពីមេដឹកនាំប្រពៃណីដែលជ្រើសរើសសហគមន៍ដោយផ្ទាល់ក្តី។ ម៉្យាងទៀតអាជ្ញាធរភូមិ និងឃុំ មានភារៈកិច្ចទំនួលខុសត្រូវអនុវត្តផែនការភូមិ-ឃុំមានសុវត្ថិភាព រួមទាំងការទប់ស្កាត់អំពើជួញដូរស្ត្រីនិងកុមារ ពលកម្មកុមារ និងអំពើហិង្សាក្នុងគ្រួសារ។[44]

[44] ផែនការ ភូមិ ឃុំ សុវត្ថិភាព ដាក់ចេញដោយក្រសួងមហាផ្ទៃ នៅ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ រកបាននៅ https://sithi.org/admin/upload/law/Village%20Commune%20Safety%20Policy%20(Eng)%20-%202010.pdf បានដកស្រង់នៅថ្ងៃទី៣ ខែមករា

- មេដឹកនាំប្រពៃណីនៅក្នុងសហគមន៍ជាបុរសចំនួន០៧នាក់ត្រូវបានសម្ភាសន៍[45]៖ ០៣នាក់ជាជនជាតិដើមភាគតិចចារ៉ាយ ០២នាក់ជាជនជាតិគ្រឹង និង០២នាក់ជាជនជាតិទំពួន។ មេដឹកនាំប្រពៃណីត្រូវបានជ្រើសរើសចេញពីសហគមន៍។

មេដឹកនាំប្រពៃណីនៅក្នុងសហគមន៍មានតួនាទីសំខាន់នៅក្នុងសហគមន៍ដូចបរិយាយលំអិតក្នុងតារាងខាងក្រោម។ នៅក្នុងករណីអំពើហិង្សាផ្អែកលើយេនឌ័រ មេដឹកនាំប្រពៃណីបានបញ្ជាក់អំពីតួនាទីរបស់ពួកគេថា៖




១. ណែនាំសមាជិកសហគមន៍ លើកកម្ពស់សិទ្ធិស្ត្រីនិងក្រុមងាយរងគ្រោះ និងណែនាំក្រុមបុរសមិនឲ្យប្រើអំពើហិង្សាលើស្ត្រី។
២. សហការជាមួយអាជ្ញាធរដើម្បីផ្សព្វផ្សាយព័ត៌មានស្តីពីអំពើហិង្សាប្រឆាំងនឹងយេនឌ័រ
៣. ផ្តល់ដំបូន្មានដល់យុវជននិងស្ត្រី
៤. ជួយការការពារសហគមន៍ សង្គម និងសមាជិកនៅក្នុងភូមិ
៥. ទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន
៦. ចូលរួមតាមដានករណីអំពើហិង្សាផ្អែកលើយេនឌ័រ ស្តាប់ពីបញ្ហា និងដោះស្រាយវិវាទរវាងភាគីទាំងពីរ។

- **អាជ្ញាធរថ្នាក់ខេត្ត៖** តាមរយៈការអន្តរាគមន៍ពីការិយាល័យ OHCHR ក្រុមស្រាវជ្រាវបានធ្វើបទសម្ភាសន៍ជាមួយមន្ត្រីតំណាងស្នងការដ្ឋាននគរបាលខេត្តរតនគិរី មន្ទីរកិច្ចការនារីខេត្តរតនគិរី និងប្រធានតុលាការនិងព្រះរាជអាជ្ញាអមសាលាដំបូងខេត្តរតនគិរី។

តារាងខាងក្រោមផ្តល់ព័ត៌មានសង្ខេបអំពីករណីអំពើរំលោភសេពសន្ថវៈ អំពើប៉ុនប៉ងរំលោភសេពសន្ថវៈ និងការបៀតបៀនផ្លូវភេទ ដែលបានលើកឡើងដោយអាជ្ញាធរមូលដ្ឋាន និងវិធីសាស្ត្រដែលប្រើប្រាស់ដើម្បីដោះស្រាយ។ ករណីភាគច្រើនត្រូវបានដោះស្រាយតាមរយៈនីតិវិធីតុលាការ ដោយមានការរាយការណ៍ទៅអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរមានសមត្ថកិច្ច។ មានសំណុំរឿងចំនួន០៥ករណីត្រូវបានសម្រុះសម្រួល

ឆ្នាំ២០២១។ សង្គមស៊ីវិលកត់សម្គាល់ថា ផែនការសុវត្ថិភាពភូមិ ឃុំ នេះ មានសក្តានុពលរឹតត្បិតទៅលើសេរីភាពការបញ្ចេញមតិ និងការប្រមូលផ្តុំ និងអាចប៉ះពាល់ដល់ក្រុមដែលងាយរងគ្រោះនានាដូចជា អ្នករកស៊ីផ្លូវភេទ។

[45] ខណៈដែលបុរស និងស្ត្រី អាចក្លាយជាចាស់ទុំ ជាទូទៅមានវត្តមានបុរសច្រើនជាងស្ត្រីដែលគេជ្រើសរើសជាចាស់ទុំដឹកនាំបែបប្រពៃណី។ ទោះជាយ៉ាងណាក៏មានការលើកកម្ពស់ភាពជាអ្នកដឹកនាំស្ត្រីជនជាតិដើមភាគតិច ជាពិសេសនៅក្នុងកិច្ចការពារធនធានធម្មជាតិ។ Hufstedar C., "ស្ត្រីកំពុងតែដឹកនាំនៅក្នុងប្រទេសកម្ពុជា" បោះពុម្ពថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។ រកបាននៅ https://www.oxfamamerica.org/explore/stories/women-taking-lead-cambodia/ ដកស្រង់នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២១។

រវាងជនរងគ្រោះរស់រានជីវិត និងជនល្មើស ដោយមន្ត្រីនគរបាលដោយមិនបញ្ជូនសំណុំរឿងទៅតុលាការ។ មានករណីមួយចំនួនទៀតត្រូវបានដោះស្រាយតាមរយៈយន្តការបែបប្រពៃណី ឬតាមរយៈការរួមបញ្ចូលគ្នានៃដំណើរការបែបប្រពៃណីនិងដំណើរការតុលាការ។

## ៤.២. ទំនោរ ប្រេវ៉ាឡង់និងស្ថានភាពនៃអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងស្ត្រីជនជាតិដើមភាគតិច

### សំណុំរឿងដែលបានរាយការណ៍ទៅអាជ្ញាធរ




គ្មានការរក្សាទុកទិន្នន័យ នៃពាក្យបណ្តឹងករណីនៃអំពើហិង្សាលើយេនឌ័រ និងគ្មានការបែងចែកទិន្នន័យទៅតាមជាតិពិន្ធដែរ។ ក្រុមស្រាវជ្រាវបានប្រមូលទិន្នន័យនៃចំនួនអំពើហិង្សាផ្អែកលើយេនឌ័រពីការិយាល័យ និងមន្ទីពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។ ព័ត៌មាននេះត្រូវបានបង្ហាញខាងក្រោម។ មន្ត្រីទទួលបន្ទុកផ្នែកប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលខេត្តរតនគិរីបានឲ្យដឹងថា មានការពិបាកក្នុងការចងក្រងឯកសារទិន្នន័យនៃករណីអំពើហិង្សាក្នុងគ្រួសារ ដោយសារអ្នកភូមិ មិនបានរាយការណ៍ ហើយជាទូទៅករណីបែបនេះត្រូវបានដោះស្រាយនៅកម្រិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ ២០១៧ មានករណីរំលោភសេពសន្ថវៈលើក្មេងស្រីដែលមានអាយុពី១៥ ឆ្នាំនិងតិចជាង១៥ ធ្លាក់ចុះជាងមុន។ ករណីកើតឡើងភាគច្រើនគឺបង្កឡើងដោយសាច់ញាតិនៅពេលដែលឪពុកម្តាយទុកកូនៗឲ្យនៅជាមួយសមាជិកគ្រួសារ។ អង្គភាពបានដោះស្រាយសំណុំរឿងចំនួន១៤ ក្នុងចំណោម១៥ ករណីដោយអនុវត្តតាមនីតិវិធីច្បាប់ ហើយបច្ចុប្បន្នជនល្មើសកំពុងអនុវត្តទោសនៅពន្ធនាគារ។[46] ដោយឡែកទិន្នន័យនេះមិនត្រូវបានបែងចែកជាតិពិន្ធទេ។

យោងតាមមន្ទីរកិច្ចការនារីខេត្ត អាជ្ញាធរបានរាយការណ៍ឲ្យដឹងថា ករណីអំពើហិង្សាផ្អែកលើយេនឌ័រចំនួន ៤៩២ ករណីបានកើតឡើងនៅក្នុងខេត្តរតគិរី នៅចន្លោះឆ្នាំ២០១៥ និង២០២០ ក្នុងចំណោមនោះសំណុំរឿងចំនួន៤១២ករណីត្រូវបានបញ្ជូលទៅតុលាការ ដែល៤២សំណុំរឿងជាករណីរំលោភសេពសន្ថវៈ និង ០៣សំណុំរឿងជាករណីរំលោភសម្លាប់។ ក្នុងចំណោម៤២សំណុំរឿង អាជ្ញាធរបានដោះស្រាយចំនួន២២ករណីដោយឡែកភាគីវិវាទបានដោះស្រាយដោយមិនប្រើប្រាស់យន្តការយុត្តិធម៌ផ្លូវការចំនួន២០ករណី។

[46] បទសម្ភាសន៍ជាមួយ ក្រុមការងារប្រឆាំងការជួញដូរ និងអនីតិជននៃស្នងការនគបាលខេត្តរតនគីរី នៅថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០២០ នៅក្រុងបានឡុង ខេត្តរតនគិរី។

មានករណីអំពើហិង្សាក្នុងគ្រួសារចំនួន៤៥០ករណី ក្នុងចំណោមនោះមាន៦០ករណីត្រូវបានដោះស្រាយតាមរយៈនីតិវិធីសម្រុះសម្រួលបែបប្រពៃណី។ ទិន្នន័យនេះមិនត្រូវបានបែងចែកជាតិពិន្ទុដែរ។

មន្ត្រីមន្ទីរកិច្ចការនារី ក៏បានបញ្ជាក់អំពីការលំបាកក្នុងការប្រមូលព័ត៌មានអំពីករណីអំពើរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ ដោយសារតែកង្វះនូវយន្តការជាក់លាក់ក្នុងការទទួលរបាយការណ៍។ សម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្បែរប៉ុស្តិ៍នគបាលឃុំ គេអាចរាយការណ៍ករណីទាំងនោះដោយផ្ទាល់ដើម្បីស្វែងរកដំណោះស្រាយ ឬដើម្បីបញ្ជូនសំណុំរឿងទៅអាជ្ញាធរជាន់ខ្ពស់។ ប្រជាពលរដ្ឋខ្លះទៀតបានធ្វើសេចក្តីរាយការណ៍មកមន្ទីរកិច្ចការនារី ឬ ដាក់បណ្តឹងទៅតុលាការខេត្តដោយផ្ទាល់។ ដូច្នេះមន្ទីរកិច្ចការនារីអាចបញ្ជាក់បានតែចំពោះករណីដែលប្រជាពលរដ្ឋបានរាយការណ៍មកកាន់ក្រុមប្រឹក្សាឃុំដែលទទួលបន្ទុកការងារស្ត្រី។[47]

មន្ត្រីរូបនេះក៏បានបញ្ជាក់ថាកង្វះនូវការប្រមូលទិន្នន័យបែកចែងតាមជាតិពិន្ទុ និងការរក្សាទុកទិន្នន័យដោយអាជ្ញាធរតែមួយស្ថាប័ននៅក្នុងខេត្តរតនគិរី បានបង្កការលំបាកក្នុងការកំណត់ឲ្យច្បាស់លាស់ថាមានករណីអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងស្ត្រីជនជាតិដើមភាគតិចចំនួនប៉ុន្មានបានកើតឡើង។ បញ្ហានេះទំនងជាបានកើតឡើងនៅតាមបណ្តាខេត្តផ្សេងៗដែរ រួមទាំងខេត្តដែលមានប្រជាពលរដ្ឋជនជាតិដើមភាគតិចកំពុងតាំងទីលំនៅ។ កង្វះព័ត៌មានស្តីពីវិសាលភាពនៃបញ្ហារួមទាក់ទងនិងអំពើហិង្សាផ្អែកលើយេនឌ័រ ជាពិសេសផលប៉ះពាល់ទៅលើស្ត្រីជនជាតិដើមភាគតិច អាចបង្កផលប៉ះពាល់ទៅលើលទ្ធភាពក្នុងការដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាពនិងទាន់ពេលវេលា។

ក្នុងចំណោមអាជ្ញាធរ១៩នាក់ដែលបានផ្តល់បទសម្ភាសន៍មាន១៦រូបបានលើកឡើងថា ពួកគេបានទទួលរបាយការណ៍ដោយផ្ទាល់ដែល(១៥រូប)ទទួលរបាយការណ៍អំពើហិង្សាផ្អែកលើយេនឌ័រ និងមួយរូបបានដឹងថាមានការធ្វើសេចក្តីរាយការណ៍ទៅអាជ្ញាធរជាន់ខ្ពស់។ ពួកគេបានលើកឡើងពីករណីរំលោភសេពសន្ថវៈ ការបៀតបៀនផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារ ប៉ុន្តែក្នុងចំណោមអាជ្ញាធរដែលផ្តល់សម្ភាសមានខ្លះមិនបានបញ្ជាក់ពីចំនួនករណីឬប្រភេទនៃករណីដែលបានទទួលនោះទេ។

អាជ្ញាធរ១១រូប ក្នុងចំណោម ១៩រូប បានរាយការណ៍អំពីករណីរំលោភសេពសន្ថវៈមួយដែលបានកើតឡើងនៅក្នុងភូមិរបស់ពួកគេ(សរុបចំនួន១១ករណី)។ អាជ្ញាធរចំនួនបួនរូបបានរាយការណ៍ថាមានចំនួនពីរករណីបានកើតឡើងនៅក្នុងភូមិរបស់ពួកគេ(សរុបចំនួន៨ករណី)ខណៈដែលមានអាជ្ញាធរមួយរូបបានរាយការណ៍ថាមានចំនួន៤ករណីនៅក្នុងភូមិ។ អាជ្ញាធរមួយរូបដែលបានរាយការណ៍អំពីករណីរំលោភសេពសន្ថវៈដែល

[47] ដូចខាងលើ។

បានកើតឡើងនៅក្នុងភូមិក្នុងឆ្នាំនេះបានកត់សម្គាល់ថា ជាទូទៅមានអំពើហិង្សាផ្អែកលើយេនឌ័រចំនួនពីរទៅបីករណីបានកើតឡើងជារៀងរាល់ឆ្នាំ។ ក្នុងនោះដែរមានអាជ្ញាធរចំនួនបីរូប ដែលបញ្ជាក់ថាពួកគេមិនបានទទួលព័ត៌មានទេ។

យោងតាមអាជ្ញាធរមូលដ្ឋាន អត្រានៃករណីអំពើរំលោភសម្លាប់គឺជាករណីកម្រកើតមានណាស់គួរកត់សម្គាល់ថាមានអាជ្ញាធរចំនួន៣រូប ក្នុងចំណោម១៩រូបដែលផ្តល់បទសម្ភាសបានរាយការណ៍ថាបានដឹងលឺអំពីករណីរំលោភសម្លាប់។ ជនរងគ្រោះក្នុងករណីមួយបានស្លាប់ក្នុងរយៈពលមួយឆ្នាំក្រោយពីអំពើរំលោភសេពសន្ថវៈបានកើតឡើង ដោយសារតែរបួសដែលបង្កឡើងកំឡុងពេលរំលោភសេពសន្ថវៈ។ អាជ្ញាធរចំនួន១៣រូបអះអាងថាគ្មានករណីរំលោភសម្លាប់កើតឡើងក្នុងមូលដ្ឋានរបស់ពួកគេទេ ដោយឡែកអាជ្ញាធរ០៣រូប ផ្សេងទៀតបានបញ្ជាក់ថាពួកគេគ្មានព័ត៌មានទេ។ មានករណីរំលោភសម្លាប់តែមួយករណីប៉ុណ្ណោះដែលត្រូវបានរាយការណ៍ដោយក្រុមគ្រួសារជនរងគ្រោះនេះគឺស្របជាមួយព័តមានដែលបញ្ជាក់ដោយអាជ្ញាធរ។

អាជ្ញាធរចំនួន១០នាក់ បានលើកឡើងថាគ្មានករណីអំពើបៀតបៀនផ្លូវភេទបានកើតឡើងទេ ឬពួកគេមិនដឹងអំពីករណីដែលបានកើតឡើងនោះទេ។ មានការចោទប្រកាន់ពីបទបៀតបៀនផ្លូវភេទ០១ករណីទៅលើបុរសម្នាក់ដែលបានលួចថត និងចែកចាយរូបថតរបស់ស្រ្តីម្នាក់ដែលកំពុងតែមុជទឹកនៅក្នុងផ្ទះរបស់នាងដោយគ្មានការយល់ព្រមពីសាម៉ីខ្លួន។ ការកំណត់និយមន័យនៃអំពើបៀតបៀនផ្លូវភេទនៅក្នុងក្រមព្រហ្មទណ្ឌអនុវត្តតែចំពោះស្ថានភាពកន្លែងការងារប៉ុណ្ណោះ ហេតុនេះហើយដែលបណ្តាលឲ្យខ្វះការយល់ដឹងក្នុងចំណោមអាជ្ញាធរមូលដ្ឋានអំពីប្រភេទផ្សេងៗនៃអំពើហិង្សាផ្អែកលើយេនឌ័រ។

តាមរយៈព័ត៌មានរបស់អាជ្ញាធរមូលដ្ឋាន អំពើហិង្សាក្នុងគ្រួសារហាក់ដូចជាទម្រង់ទូទៅមួយនៃអំពើហិង្សាផ្អែកលើយេនឌ័រដែលកើតឡើងនៅក្នុងសហគមន៍ជនជាតិដើមភាគតិច ។ អាជ្ញាធរមូលដ្ឋានចំនួន១៨នាក់ ក្នុងចំណោមទាំង១៩នាក់ បានបញ្ជាក់ថាករណីអំពើហិង្សាក្នុងគ្រួសារកើតឡើងនៅក្នុងភូមិរបស់ពួកគេ។ មាន អាជ្ញាធរមូលដ្ឋានតែមួយរូបប៉ុណ្ណោះដែលអះអាងគាត់គ្មានព័ត៌មាននេះ។ អាជ្ញាធរមូលដ្ឋានចំនួនបីរូបបានអះអាងថាមានកើតឡើងមួយករណី។ អាជ្ញាធរមួយរូបបានអះអាងថាមាន០២ករណី។ អាជ្ញាធរបីរូបបានអះអាងថាមាន ០៤ ករណី។ ដោយឡែកអាជ្ញាធរមួយរូបបានអះអាងថាមាន០៦ ករណី។ អាជ្ញាធរប្រាំរូបបានអះអាងថាមាន១០ករណី។ អាជ្ញាធរមួយរូបបញ្ជាក់ថាមាន១៥ ករណី និងបីរូបផ្សេងទៀតបញ្ជាក់ថាមាន "ច្រើនករណី" ប៉ុន្តែមិនបានបញ្ជាក់ពីចំនួនទេ។

អាជ្ញាធរមួយរូបបានកត់សម្គាល់ថា៖ "មានការកើនឡើងនៃករណីអំពើហិង្សាក្នុងគ្រួសារ ក្នុងឆ្នាំ២០១៩ ប៉ុន្តែករណីនេះបានថយចុះខ្លះក្នុងឆ្នាំ២០២០។ មានមនុស្សមួយចំនួនបានស្លាប់បាត់បង់ជីវិតដោយសារតែ

មិនបានទទួលការគាំទ្រសុខភាពផ្លូវចិត្ត ខណៈគ្រួសារនៅតែប្រឈមនិងអំពើហិង្សាដដែលៗ។ ទោះបីមានអ្នកភូមិ ឬសាច់ញាតិខ្លះបានធ្វើសេចក្តីរាយការណ៍អំពីករណីនេះជំនួសជនរងគ្រោះក៏ដោយ ក៏ដំណោះស្រាយនៅត្រឹមតែជាការចរចាជាមួយជនល្មើសដើម្បីបញ្ឈប់ការប្រព្រឹត្តអំពើហិង្សាប៉ុណ្ណោះ។ នៅក្នុងករណីខ្លះ អំពើហិង្សាក្នុងគ្រួសារបានថយចុះបន្ទាប់ពីជនរងគ្រោះបានរាយការណ៍ទៅអាជ្ញាធរ"។ [48]

អាជ្ញាធរមូលដ្ឋានមួយចំនួន មិនអាចផ្តល់តួលេខពិតប្រាកដនៃករណីអំពើហិង្សាផ្អែកលើយេនឌ័រដែលបានកើតឡើងនៅក្នុងភូមិទេ ហើយកង្វះព័ត៌មានគឺជាក្តីព្រួយបារម្ភមួយផងដែរ។ ការណ៍នេះអាចបណ្តាលមកពីការខ្វះ ចំណេះដឹង ជំនាញ និងធនធាន ទាំងផ្នែកហិរញ្ញវត្ថុនិងគោលការណ៍ណែនាំ សម្រាប់ការចងក្រងឯកសារករណីអំពើហិង្សាទាំងនេះ។ ការស្រាវជ្រាវនេះក៏បានរកឃើញផងដែរថា មិនមែនគ្រប់អាជ្ញាធរមូលដ្ឋានទាំងអស់បានដោះស្រាយករណីអំពើហិង្សាក្នុងគ្រួសារស្របតាមនីតិវិធីច្បាប់ទេ យ៉ាងហោចណាស់ក៏មានអាជ្ញាធរមួយរូបបានបញ្ជាក់ថាគាត់បានដោះស្រាយករណីនេះតាមរយៈ "ការចរចា" ជាជាងតាមរយៈការប្រើប្រាស់នីតិវិធីច្បាប់ដែលបានចែងនៅក្នុងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងក្រមព្រហ្មទណ្ឌ។

## តើនរណាជាជនរងគ្រោះ/ជនរងគ្រោះរស់រានជីវិត?




ជនរងគ្រោះ/ជនរងគ្រោះរស់រានជីវិត ដែលបានផ្តល់បទសម្ភាសន៍មានអាយុចាប់ពី១១ទៅ៥៣ឆ្នាំនេះបង្ហាញឲ្យឃើញថាស្ត្រីជនរងគ្រោះនៃអំពើហិង្សាផ្អែកលើយេនឌ័រអាចមានគ្រប់វ័យ និងតម្រូវឲ្យមានការដោះស្រាយដោយប្រើប្រាស់នូវវិធីសាស្ត្រគិតគូដល់តម្រូវការរបស់កុមារចំពោះករណីដែលជនរងគ្រោះរស់រានជីវិតជាកុមារ។ ជនរងគ្រោះរស់រានជីវិតដែលបានផ្តល់បទសម្ភាសន៍នៅក្នុងការសិក្សាស្រាវជ្រាវនេះជាសមាជិកនៃជនជាតិដើមភាគតិចចំនួន០៤រួមមាន ព្ញូនង ចារ៉ាយ គ្រឹង និងព្រៅ។ ជនរងគ្រោះរស់រានជីវិតចំនួន០៧នាក់បានផ្តល់សក្ខីកម្មថាពួកគេត្រូវបានរំលោភសេពសន្ថវៈ។ ជនរងគ្រោះរស់រានជីវិតម្នាក់បានអះអាងថានាងត្រូវបានរំលោភសេពសន្ថវៈ ហើយជនល្មើសបានប៉ុនប៉ងសម្លាប់នាង។ ជនរងគ្រោះរស់រានជីវិតម្នាក់ទៀតបានពោលថានាងជាជនរងគ្រោះនៃអំពើប៉ុនប៉ងរំលោភសេពសន្ថវៈ ខណៈជនរងគ្រោះរស់រានជីវិតម្នាក់ទៀតបញ្ជាក់ថានាងគឺជាជនរងគ្រោះនៃអំពើបៀតបៀនផ្លូវភេទ ដោយសារតែជនប្រព្រឹត្តបានលួចថតរូបរបស់នាងខណៈពេលដែលនាងបានកំពុងសម្រាក និងបានយករូបភាពរបស់នាងចែកចាយដល់អ្នកដទៃដោយគ្មានការអនុញ្ញាត។

[48] ដូចខាងលើ។

## តើនរណាជាជនល្មើស ?

ព័ត៌មានបឋមទទួលបានពីCIWWG និងអង្គការមិនមែនរដ្ឋាភិបាលដែលជាជនជាតិដើមភាគតិច និងមិនមែនជនជាតិដើមភាគតិចមួយចំនួនបានបង្ហាញថា ជនល្មើសនៃអំពើហិង្សាផ្លូវភេទភាគច្រើនគឺជា " អ្នកខាងក្រៅ" ឬបុគ្គលដែលមិនមែនជនជាតិដើមភាគតិចដែលមិនមែនជាសមាជិកសហគមន៍។ ប៉ុន្តែយោងតាមព័ត៌មានប្រមូលមកពីបទសម្ភាសន៍នៅក្នុងការស្រាវជ្រាវនេះរកឃើញថា ជនល្មើសភាគច្រើនគឺជាបុរសជនជាតិដើមភាគតិចដែលរស់នៅក្នុងសហគមន៍ជាមួយជនរងគ្រោះ ហើយជនល្មើសខ្លះគឺជាសាច់ញាតិរបស់ជនរងគ្រោះរស់រានមានជីវិតដូចជា (ពូ ឪពុកចុង ឬបងប្អូនជីដូនមួយ) និងមានករណីចំនួនតិចតួចប៉ុណ្ណោះដែលប្រព្រឹត្តដោយជនល្មើសដែលមិនមែនជាជនជាតិដើមភាគតិច ដូចការលើកឡើងនៅតំណាក់កាលប្រមូលព័ត៌មានបឋម។

តំណាងមួយរូបរបស់អង្គការជនជាតិដើមភាគតិចដែលមានការិយាល័យនៅមូលដ្ឋាន បានផ្តល់ព័ត៌មានថារូបគាត់ផ្ទាល់ធ្លាប់បានលឺអំពីរំលោភសេពសន្ថវៈ ដែលបានប្រព្រឹត្តដោយសាច់ញាតិរបស់ជនរងគ្រោះរស់រានមានជីវិត/ជនរងគ្រោះផ្ទាល់។ គាត់ក៏បានលើកឡើងថាមានករណីមួយចំនួន ជនល្មើសមិនត្រូវបានកំណត់អត្តសញ្ញាណ និងមិនត្រូវបានចាប់ខ្លួនទេ ប៉ុន្តែក្នុងករណីដែលអាចកំណត់អត្តសញ្ញាណជនល្មើសបានជាទូទៅជនល្មើសច្រើនតែជាសាច់ញាតិ ឬជាបុគ្គលដែលសហគមន៍បានស្គាល់។ អាស្រ័យដោយការខ្វះភ័ស្តុតាង និងសាក្សី ជនសង្ស័យជាញឹកញយមិនត្រូវបានចាប់ខ្លួន ឬចោទប្រកាន់តាមផ្លូវច្បាប់ឡើយ។[49]

អង្គការPLAN International Cambodia បានឲ្យដឹងថាអង្គការបានទទួល របាយការណ៍អំពីករណីអំពើរំលោភសេពសន្ថវៈលើកុមារដែលបង្កឡើងដោយសាច់ញាតិ ប៉ុន្តែដោយសារតែគោលការណ៍នៃការសម្ងាត់ក្រុមការងារអង្គការមិនអាចផ្តល់ព័ត៌មានលម្អិតអំពីករណីទាំងនោះបានទេ។ ក្នុងឆ្នាំ២០១៩ មានករណីអំពើរំលោភសេពសន្ថវៈបង្កឡើងដោយសាច់ញាតិជាច្រើនករណីបានកើតឡើង យ៉ាងហោចណាស់ក៏មានមួយករណីបានកើតឡើងក្នុងរៀងរាល់ខែ។ នៅមុនឆ្នាំ ២០១៩ ករណីនេះកើតឡើងសរុបត្រឹមតែចំនួន ៥ទៅ ៦ ករណីប៉ុណ្ណោះ។ ពួកគេបញ្ជាក់ថាសំណុំរឿងដែលកំពុងត្រូវបានដោះស្រាយក្រៅប្រព័ន្ធតុលាការបានថយចុះដោយសារតែអាជ្ញាធរមូលដ្ឋាន និងសហគមន៍បានយល់ដឹងពីហេតុផលដែលត្រូវរាយការណ៍ពីករណីទាំងនេះ។ គិតត្រឹមខែតុលា ឆ្នាំ២០២០ ពួកគេមិនបានទទួលរបាយការណ៍អំពីករណីរំលោភសេពសន្ថវៈបង្កឡើងដោយសាច់ញាតិទេ។[50]

ជនរងគ្រោះរស់រានមានជីវិតត្រូវបានសាកសួរថាតើពួកគេអាចកំណត់អត្តសញ្ញាណជនល្មើសបានដែរឬទេ។ ជនរងគ្រោះម្នាក់មិនអាចកំណត់អត្តសញ្ញាណជនល្មើសបានទេ ប៉ុន្តែជនរងគ្រោះផ្សេងទៀតអាចផ្តល់អត្ត

[49] បទសម្ភាសន៍ជាមួយសមាជិកបុគ្គលិកភេទស្រី មកពីអង្គការជនជាតិដើមភាគតិច និងសមាជិកនៃ CIWWG នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០។

[50] បទសម្ភាសន៍ជាមួយគណៈគ្រប់គ្រងនៃអង្គការអន្តរជាតិ PLAN ប្រចាំនៅកម្ពុជា នាថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០២០ ក្នុងរាជធានីភ្នំពេញ, កម្ពុជា។

សញ្ញាណជនល្មើសបាន។ ជនល្មើស៥នាក់ មានទំនាក់ទំនងសាច់ញាតិជាមួយជនរងគ្រោះ។ ពីរនាក់ក្នុងចំណោម៥នាក់ គឺជាបងប្អូនជីដូនមួយរបស់ជនរងគ្រោះ ជនល្មើសមួយរូបជាឪពុកចុងរបស់ជនរងគ្រោះ ចំណែកជនល្មើសពីរនាក់ទៀតមិនបានបញ្ជាក់ច្បាស់លាស់ពីទំនាក់ទំនងនោះទេ។ ជនល្មើសមួយរូបគឺជាអ្នកជិតខាងរបស់ជនរងគ្រោះ និងជនល្មើសមួយរូបទៀតជាបងប្អូនរបស់មន្ត្រីមូលដ្ឋាន។ មានជនល្មើសបួនរូបដែលមិនមែនជាសាច់ញាតិរបស់ជនរងគ្រោះ។ជនល្មើសមួយរូបគឺជាដៃគូស្និទ្ធស្នាលរបស់ជនរងគ្រោះ។ ជនល្មើសពីរនាក់ជាបុគ្គលខាងក្រៅដែលមិនមែនជាជនជាតិដើមភាគតិច ម្នាក់ក្នុងចំនោមពួកគេបានរៀបការជាមួយជនជាតិដើមភាគតិចដែលជាសាច់ញាតិរបស់ជនរងគ្រោះ។ បុរសម្នាក់គឺជាជនចម្លែកមុខ។ ជនល្មើលដែលមិនមែនសាច់ញាតិ ចុងក្រោយគឺជាមិត្តភក្តិរបស់ឪពុកជនរងគ្រោះដែលធ្វើចំការនៅក្បែរនោះ ប៉ុន្តែគ្មានការបញ្ជាក់គាត់ជាជនជាតិដើមភាគតិចឬមិនមែននោះទេ។

សាច់ញាតិជនរងគ្រោះដែលផ្តល់បទសម្ភាសន៍បានកត់សម្គាល់ថា មានករណីចំនួន០២(ពីរ)ដែលមិនអាចកំណត់អត្តសញ្ញាណជនល្មើសបាន។ ទោះបីយ៉ាងណានៅក្នុងករណីចំនួន០៦(ប្រាំមួយ)ករណីជនល្មើសគឺជាសាច់ញាតិរបស់ជនរងគ្រោះ(សាច់ញាតិផ្ទាល់ខាងឪពុក ដូចជាអ៊ុំ បងប្អូនជីដូនមួយ ឬឪពុកចុង)។ នៅក្នុងករណីចំនួន០៣(បី) ជនល្មើសជាអ្នករស់នៅក្នុងភូមិជាមួយគ្នាជាមួយជនរងគ្រោះ/ជនរងគ្រោះរស់រានមានជីវិត(ម្នាក់គឺជាដៃគូស្និទ្ធស្នាលរបស់ជនរងគ្រោះ)។ នៅក្នុងករណីចំនួន០២(ពីរ)ករណី ជនល្មើសមិនមែនជនជាតិដើមភាគតិច ទោះបីជនល្មើសម្នាក់បានរៀបការជាមួយស្ត្រីជនជាតិដើមភាគតិច និងបាននឹងកំពុងរស់នៅក្នុងភូមិជាមួយជនរងគ្រោះ។ ជនល្មើសដែលមិនមែនជាជនដើមភាគតិចម្នាក់ទៀតគឺជាជនចម្លែកមុខដែលរស់នៅក្នុងភូមិផ្សេងគ្នា។
ការវិភាគលទ្ធផលនៃបទសម្ភាសន៍បង្ហាញថាអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងស្ត្រីជនជាតិដើមភាគតិច គឺមានច្រើនសណ្ឋានដូចជា អំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាបង្កដោយដៃគូរស្និទ្ធស្នាល និងអំពើរំលោភសេពសន្ថវៈ ដែលប្រព្រឹត្តដោយបុរសជនជាតិដើមភាគតិចនិងបុរសដែលមិនមែនជាជនជាតិដើមភាគតិច ព្រមទាំងអំពើហិង្សាផ្អែកលើយេនឌ័រ(ភាគច្រើនអំពើរំលោភសេពសន្ថវៈ) ដែលប្រព្រឹត្តនៅក្រៅលំនៅដ្ឋានដោយបុរសជនជាតិដើមភាគតិចនិងបុរសមិនមែនជាជនជាតិដើមភាគតិច។ ភាគច្រើននៃករណីដែលក្រុមការងារបានជួបសម្ភាសន៍ជនល្មើស គឺជាបុរសជនជាតិដើមភាគតិចដែលស្គាល់គ្នាជាមួយជនរងគ្រោះ/ជនរងគ្រោះរស់រានមានជីវិត។

## ៤.៣.ជំនឿសន្មត់យេនឌ័រដែលខុសឆ្គងជាឫសគល់នៃអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងស្ត្រីជនជាតិដើមភាគតិច

ការសិក្សាមួយធ្វើឡើងនៅក្នុងឆ្នាំ២០១៨ ដោយអង្គការ Care Cambodia បានកត់សម្គាល់ថានៅក្នុងទីប្រជុំជនដូចជាតាវែង (រតនគិរី) និងសែនមនោរម្យ (មណ្ឌលគីរី) ក្នុងចំណោមប្រជាពលរដ្ឋដែលមិនមែនជាជនជាតិដើមភាគតិចមានទស្សនៈថាស្ត្រីជនជាតិដើមភាគតិចនឹងយល់ព្រមរួមភេទប្រសិនបើទទួលសំណង

(ជាសាច់ប្រាក់ឬអំណោយ)នោះ។ ទស្សនៈនេះត្រូវបានរកឃើញជាទូទៅក្នុងចំណោមបុរសដែលមិនមែនជាជនជាតិដើមភាគតិចដែលប្រកបរបរជាបើកបររថយន្តឈ្នួល ដែលតែងតែស្វែងរកស្ត្រីជនជាតិដើមភាគតិចដើម្បីរួមភេទជាមួយនោះ។ នៅក្នុងការសិក្សាដដែលនេះក៏បានកត់សម្គាល់ថា "យើងគួរតែបង្ហាញភាពស្ទាក់ស្ទើរក្នុងការធ្វើទូទៅនីយកម្មអំពីទស្សនៈបែបនេះ ស្របពេលដែលគួរតែដឹងថាការលើកឡើងនិងការទទួលយកនូវទស្សនៈទាក់ទងនិងលទ្ធភាពទទួលបានសេវាផ្លូវភេទពីស្ត្រីជនជាតិដើម អាចបង្កើតឲ្យមានជំនឿសន្មត់អំពីយេនឌ័របែបអវិជ្ជមានប្រឆាំងជនជាតិដើមភាគតិច"។ [51]

សមាជិកមួយរូបនៃអង្គការជនជាតិដើមភាគតិចមួយប្រចាំនៅខេត្តរតនគិរីបានពោលថា ពួកគេជឿជាក់អំពើរំលោភសេពសន្ថវៈបណ្តាលមកពីការធ្វើចំណាកស្រុកនិងការប្រើប្រាស់គ្រឿងញៀន។ ពួកគេយល់ថាបុរសដែលប្រើប្រាស់គ្រឿងញៀនអាចបំបាត់ភាពងងុយ និងអាចធ្វើការងារបានច្រើន ទោះបីជាការកាប់ឈើខុសច្បាប់ ឬការធ្វើការងារនៅក្នុងចម្ការកៅស៊ូ។[52]

មន្ត្រីនៅមន្ទីរកិច្ចការនារីខេត្តបានបង្ហាញការជឿជាក់ថា ឫសគល់នៃអំពើហិង្សាផ្អែកលើយេនឌ័រគឺបណ្តាលមកពីជនល្មើសបានសេពគ្រឿងស្រវឹងច្រើនពេក ព្រមទាំងបណ្តាលមកពីអាពាហ៍ពិពាហ៍កុមារ/ ឬឆាប់រៀបការពេក។ ពួកគេបានកំណត់ដើមចមនៃអំពើហិង្សាក្នុងគ្រួសារថាបណ្តាលមកពីមានការអប់រំកម្រិតទាប។ មូលហេតុបន្ទាប់ គឺបណ្តាលមកពីសមាជិកគ្រួសារភាគច្រើនហាក់ដូចជាមិនអាចពិភាក្សាអំពីបញ្ហានៅក្នុងគ្រួសារបាន ដូច្នេះពួកគេជ្រើសរើសប្រើកម្លាំងដើម្បីដោះស្រាយបញ្ហាទៅវិញ។ មូលហេតុកំណត់ទីបីនោះគឺបណ្តាលមកពីភាពក្រីក្រដោយសារតែជនល្មើសភាគច្រើនគឺកំពុងរស់នៅក្នុងស្ថានភាពក្រីក្រ។

ក្រុមមន្ត្រីរបស់អង្គការផ្លែនអន្តរជាតិបានបង្ហាញទស្សនៈថា ជនរំលោភបំពានរំលោភកុមារជាបុគ្គលដែលស្ថិតក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង មានការអប់រំកម្រិតទាប និងបានមើលភាពយន្តអាសអាភាស។ ពួកគេក៏បានលើកឡើងអំពីការធ្វេសប្រហែលរបស់ឪពុកម្តាយដែលមិនយកចិត្តទុកដាក់ថែរក្សាកូនៗ និងទុកកូនៗឲ្យនៅជាមួយសាច់ញាតិនៅពេលពួកគេធ្វើការងារនៅតំបន់ឆ្ងាយទៅចម្ការ ឬទៅព្រៃ ប៉ុន្តែការធ្វេសប្រហែសនេះក៏បានរកឃើញក្នុងចំណោមឪពុកម្តាយដែលមិនមែនជាជនជាតិដើមភាគតិចផងដែរ។ ពួកគេបានបន្តស្នើថាដើម្បីទប់ស្កាត់បញ្ហានេះមិនគួរទុកឲ្យកុមារចោលតែឯងទេ។ ពួកគេក៏បានបញ្ជាក់ថាបានដឹងរបាយការណ៍ទាក់ទងនិងបុរសដែលមិនមែនជាជនជាតិដើមភាគតិចដែលបានប្រព្រឹត្តអំពើរំលោភសេពសន្ថវៈលើស្ត្រី និងក្មេងស្រីជនជាតិដើមភាគតិច ហើយជនល្មើសទាំងនោះគឺជា" ជនចំណូលថ្មីនៅក្នុងតំបន់"។ ពួកគេក៏បានបញ្ជាក់ពីជំនឿសន្មត់ដែលលើកឡើងថាស្ត្រីជនជាតិដើមភាគតិចនឹងព្រមរួមភេទជាថ្នូរនិងការទទួល

[51] ភើរេស ភើរ៉េរ៉ូ, អ., ឡូប៉េ ខទីណា, ជេ., ប្រ៊ីហ្គាន ខនស៊ុលធីង, "ការមានផ្ទៃពោះក្នុងវ័យជំទង់& អាពាហ៍ពិពាហ៍វ័យក្មេងនៅក្នុង ចំណោម សហគមន៍ជនជាតិដើមភាគតិចនៅភាគឥសាន្តនៃប្រទេសកម្ពុជា", អង្គការ CARE Cambodia, ២០១៨, ទំព័រ ៣១។

[52] បទសម្ភាសន៍ជាមួយគណៈគ្រប់គ្រងនៃអង្គការជនជាតិដើមភាគតិច នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ នៅក្រុងបានលុង ខេត្តរតនគិរី។

បានប្រាក់ ហើយអ្នកបើកបររថយន្តឈ្នួលតែងតែលើកឡើងអំពីជំនឿសន្មត់នេះ។ ពួកគេក៏បានកត់សម្គាល់ផងដែរថានៅក្នុងអាពាហ៍ពិពាហ៍កុមារ ការរួមភេទគឺធ្វើឡើងដោយព្រមព្រៀង។[53] នីតិភាពនៃអាយុដែលអាចផ្តល់ការព្រមព្រៀងរួមភេទនៅកម្ពុជាគឺនៅអាយុ១៥ឆ្នាំ។[54] ក្រមរដ្ឋប្បវេណីបានហាមឃាត់អាពាហ៍ពិពាហ៍មុនអាយុ១៨ឆ្នាំ លុះត្រាភាគីមួយអាយុលើស១៨ឆ្នាំ ហើយភាគីមួយទៀតមានអាយុត្រឹម១៦ឆ្នាំ ហើយពួកគេទទួលបានការអនុញ្ញាតិពីអាណាព្យាបាលស្របច្បាប់។[55] ទោះជាមានច្បាប់ចែងបែបនេះក្តី ក្មេងស្រីកម្ពុជាជាច្រើនបានរៀបការនៅវ័យក្មេង ហើយក្មេងស្រីមួយចំនួនបានរៀបការមុនអាយុ១៦ឆ្នាំ ដែលការណ៍បង្ហាញពីកង្វះប្រសិទ្ធិភាពនៅក្នុងការអនុវត្តច្បាប់។ ធ្លាក់ចុះពី៣០ ភាគរយក្នុងឆ្នាំ ១៩៩៩ ដល់ ១៩ ភាគរយនៅឆ្នាំ ២០០៩ ។ ទោះជាអាពាហ៍ពិពាហ៍កុមារមានការធ្លាក់ចុះនៅកំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ[56] នៅក្នុងខេត្តមណ្ឌលគីរី និងរតនៈគីរី ដែលមានប្រជាពលរដ្ឋជាជនជាតិភាគតិចកំពុងរស់នៅនោះអាត្រាអាពាហ៍ពិពាហ៍ក្មេងស្រីមុនអាយុ១៨ឆ្នាំ នៅតែខ្ពស់ដដែល។ ពោលគឺ ៣៦ភាគរយនៃស្ត្រីដែលមានអាយុ ២០-២៤ ឆ្នាំបានរៀបការមុនអាយុ ១៨ឆ្នាំ។

អាជ្ញាធរមូលដ្ឋាន ជនរងគ្រោះរស់រានជីវិត ក្រុមគ្រួសារជនរងគ្រោះ និងមេដឹកនាំប្រពៃណីបានលើកឡើងអំពីកត្តាដែលនាំឲ្យមានអំពើហិង្សាផ្អែកលើយេនឌ័រស្រដៀងៗគ្នានៅកិច្ចសម្ភាសន៍។ អាជ្ញាធរមូលដ្ឋានអះអាងថាការប្រើប្រាស់គ្រឿងញៀននិងគ្រឿងស្រវឹងរបស់ជនល្មើសថាជាកត្តាចំបង។ កត្តារួមផ្សំផ្សេងទៀតដែលជម្រុញឲ្យមានអំពើហិង្សាផ្លូវភេទគឺភាពអត់ការងារធ្វើ ឬជីវភាពក្រីក្រ កង្វះការអប់រំ ជនចំណូលស្រុកថ្មី ការប្រច័ណ្ឌហួងហែង ការបង្ខិតបង្ខំ ការមិនចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយអប់រំ ជនល្មើសមិនស្តាប់អាជ្ញាធរ និងចំណង់ផ្លូវភេទរបស់ជនល្មើស។ កត្តាទាំងអស់នេះបានដាក់ការស្តីបន្ទោសទៅលើជនល្មើស។

ប៉ុន្តែក៏នៅមានកត្តាកំណត់មួយចំនួនផ្សេងទៀតដែលហាក់ដូចជាស្តីបន្ទោសជនរងគ្រោះទៅវិញ។ កត្តាទាំងនេះរួមមានស្ត្រីធ្វើដំណើទៅសាលារៀន ឬធ្វើដំណើរទៅចំការ កាត់តាមចំការកៅស៊ូ ឬព្រៃស្ងាត់តែម្នាក់ឯង ឬស្ត្រីបានបង្កើតមិត្តភក្តិជាមួយមនុស្សចម្លែកមុខឬ"មនុស្សអាក្រក់" ឬស្ត្រីដែលបដិសេធមិនឆ្លើយតបចំពោះសកម្មភាពលេបខាយរបស់ជនល្មើស ឬស្ត្រីបានស្លៀកសម្លៀកបំពាក់លេចលើលេចក្រោម ឬស្ត្រីដែលធ្វើដំណើផ្លូវឆ្ងាយនិងស្ងាត់ ម្យ៉ាងទៀតមានការលើកឡើងថាស្ត្រីជនជាតិដើមភាគតិចមានភាពទន់ខ្សោយ និង

---

[53] បទសម្ភាសន៍ជាមួយគណៈគ្រប់គ្រងនៃអង្គការអន្តរជាតិ PLAN ប្រចាំនៅកម្ពុជា នាថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០២០ ក្នុងរាជធានីភ្នំពេញ, កម្ពុជា។

[54] នីតិភាពនៃការព្រមព្រៀងរួមភេទនៅកម្ពុជាគឺចាប់ពីអាយុ១៥ឆ្នាំ ហើយចំណុចនេះបានកំណត់ដោយមាត្រា៨ ជំពូក៤ (អំពើអនាចារ)នៃច្បាប់ស្តីពីការបង្ក្រាបអំពើជំរឹត អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលបានអនុម័តដើម្បីហាមឃាត់នូវអំពើរួមភេទជាមួយកុមារក្រោមអាយុ១៥ឆ្នាំ។ ច្បាប់នេះបានហាមឃាត់ "អំពើអនាចារ" ជាមួយកុមារក្រោម១៥ឆ្នាំ ហើយលក្ខខណ្ឌនេះ (ពាក្យដើមជាភាសាខ្មែរ អនាចារ ត្រូវបានបកស្រាយដោយតុលាការថា ហាមឃាត់រាល់គ្រប់រូបភាពនៃការរួមភេទ (ដោយមានការព្រមព្រៀង និងដោយគ្មានការព្រមព្រៀង ទាំងការរួមភេទដោយបង់ប្រាក់ ឬមិនបង់ប្រាក់)ជាមួយកុមារក្រោមអាយុ១៥ឆ្នាំ។

[55] មាត្រា ៩៤៨នៃក្រមរដ្ឋប្បវេណី (២០០៧)

[56] UNICEF, ទម្រង់ព័ត៌មានស្ថិតិស្តីអំពីកិច្ចការពារកុមារនៅកម្ពុជា ចុះនៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១៨ រកបាននៅ https://www.unicef.org/cambodia/reports/statistical-profile-child-protection-cambodia ដកស្រង់នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០២១

ទឹកចិត្តល្អ។ ដោយសារតែមានការភ័យខ្លាចចំពោះអំពើហិង្សាផ្លូវភេទ ស្ត្រីជនជាតិដើមភាគតិចមួយចំនួនមានភ័យខ្លាចក្នុងការធ្វើដំណើរតែម្នាក់ឯង ហើយបានជ្រើសរើសធ្វើដំណើរទៅណាមកណាជាលក្ខណៈក្រុមវិញ។ គួរកត់សម្គាល់ផងដែរថាស្ត្រីនិងក្មេងស្រីដែលមិនមែនជាជនជាតិដើមភាគតិចនៅក្នុងខេត្តក៏បានជួបប្រឈមជាមួយបញ្ហានេះដូចគ្នា។ មន្ត្រីបុគ្គលិកអង្គការជនជាតិដើមភាគតិចម្នាក់បានកត់សម្គាល់ថាពួកគេបានណែនាំដល់បុគ្គលិកភេទស្រី និងស្ត្រីនៅក្នុងសហគមន៍ដែលពួកគេកំពុងបំពេញការងារជាមួយកុំឲ្យធ្វើដំណើរតែម្នាក់ឯង។ យោងតាមការលើកឡើងរបស់អ្នកតបបទសម្ភាស មានន័យថាសេរីភាពនៃការដើរហើររបស់ស្ត្រីជនជាតិដើមភាគតិចត្រូវបានរឹតត្បិតនៅក្នុងចំណោមខេត្តទាំងបីនេះ។

អាជ្ញាធរមូលដ្ឋានហាក់ដឹងថាជនល្មើសក៏ត្រូវតែទទួលខុសចំពោះសកម្មភាពរបស់ពួកគេហើយប្រជាពលរដ្ឋគួរតែបានទទួលការអប់រំដើម្បីកុំឲ្យមានបទល្មើសបែបនេះកើតឡើង។ ប៉ុន្តែការអនុវត្តច្បាប់ហាក់នៅមានភាពខ្វះចន្លោះនៅឡើយ។ ច្បាប់បានហាមឃាត់អំពើរំលោភសេពសន្ថវៈ ប៉ុន្តែករណីបែបនេះនៅតែត្រូវបានសម្រុះសម្រួល និងដោះស្រាយក្រៅប្រព័ន្ធតុលាការដោយគ្មានការស្វែងរកយុត្តិធម៌នៅក្នុងប្រព័ន្ធច្បាប់។ មានកម្មវិធីផ្សព្វផ្សាយបង្កើនការយល់ដឹង បានធ្វើឡើងជាបន្តបន្ទាប់ដោយអង្គការអន្តរជាតិ ជាមួយក្រុមសហគមន៍ជនជាតិដើមភាគតិចដើម្បីឲ្យមានការយល់ដឹងកាន់តែច្បាស់អំពីអ្វីដែលច្បាប់ហាមឃាត់ និងទោសទណ្ឌចំពោះបទល្មើសទាំងនេះ។

ផ្ទុយស្រឡះពីទស្សនៈដែលបានឡើង ក្នុងន័យដាក់បន្ទុកនិងស្តីបន្ទោសទៅលើអាកប្បកិរិយាផ្ទាល់ខ្លួននោះឬសគល់នៃអំពើហិង្សាផ្អែកលើយេនឌ័រគឺចាក់ស្រេះនៅក្នុងរចនាសម្ព័នសង្គម។ មានការរកឃើញថាពលរដ្ឋដែលកំពុងរស់នៅក្នុងភាពក្រីក្របានប្រឈមខ្ពស់និងហានិភ័យនៃអំពើហិង្សាផ្អែកលើយេនឌ័រ។ ការសិក្សាសកលមួយធ្វើឡើងនៅក្នុងកំឡុងឆ្នាំ២០១៩ស្តីពីទំនាក់ទំនងរវាងសន្តិសុខផ្អែកសេដ្ឋកិច្ច និងអំពើហិង្សាផ្អែកលើយេនឌ័របានរកឃើញថា៖ "នៅក្នុងសកលលោក បុគ្គលដែលគ្មានស្ថេរភាពផ្អែកសេដ្ឋកិច្ច តែងតែរកនៅក្នុងតំបន់ដែលមានជម្លោះ មានសេវាគាំទ្រផ្នែកសង្គមតិចតួច និងមានប្រព័ន្ធច្បាប់ទន់ខ្សោយ។ ទន្ទឹមគ្នានេះភាពអសន្តិសុខផ្អែកសេដ្ឋកិច្ច ឬភាពក្រីក្រដែលរាំរ៉ៃ បានធ្វើឲ្យបុគ្គល និងក្រុមគ្រួសាររបស់ពួកគេជួបប្រទះនូវស្ថានភាពតឹងតែង និងតែងតែជ្រើសរើសមធ្យោបាយដោះស្រាយដែលមានប្រថុយប្រថានដែលអាចបង្កើនភាពងាយរងគ្រោះពីអំពើហិង្សាផ្អែកលើយេនឌ័រ"។ ចំណុចនេះក៏បានលើកឡើងផងដែរនៅក្នុងរបាយការណ៍"ការគោរពស្ត្រី៖ ក្របខ័ណ្ឌការពារអំពើហិង្សាប្រឆាំងនឹងស្ត្រី" ដែលបានផ្សព្វផ្សាយនៅក្នុងខែឧសភាឆ្នាំ២០១៩ ដោយអង្គការសុខភាពពិភពលោក អង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការស្ត្រី ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិនិងមូលនិធិប្រជាជនរបស់អង្គការសហប្រជាជាតិ បានផ្តួចផ្តើមបង្កើតនូវក្របខ័ណ្ឌស្តីការគោរពដែលផ្តោតសំខាន់ទៅលើអ្នកធ្វើគោលនយោបាយណែនាំយុទ្ធសាស្ត្រចំនួន៧ (គំនិតផ្តួចផ្តើមដំបូងស្តីពីការបង្កើតពាក្យគោរព) ដើម្បីប្រយុទ្ធប្រឆាំងអំពើហិង្សាប្រឆាំងនឹងស្ត្រី។ ក៏មានបញ្ចូលទាំងពាក្យក្រីក្រសម្រាប់ "ការកាត់បន្ថយភាពក្រីក្រ" ដែល

សំដៅទៅលើ "យុទ្ធសាស្រ្តដែលផ្តោតលើស្រ្តីឬគ្រួសារស្រ្តីដែលមានគោលបំណងចំបងគឺដើម្បីកាត់បន្ថយភាពក្រីក្រ។

ភាពក្រីក្របានក្លាយជាឧបសគ្គដ៏ចម្បងដែលរារាំងលទ្ធភាពទទួលបានយុត្តិធម៌នៅក្នុងករណីនៃ អំពើហិង្សាផ្អែកលើយេនឌ័រ។ មន្ត្រីនគបាលនៅក្នុងខេត្តរតនៈគីរីបានធ្វើការកត់សម្គាល់ ជាទូទៅស្ត្រីមិនសូវប្រើប្រាស់នីតិវិធីច្បាប់ មិនមែនដោយសារតែភាពអៀនខ្មាស់ទេ ប៉ុន្តែភាគច្រើនគឺបណ្តាលមកពីស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេ។ ជាក់ស្តែងគឺបុរសជាអ្នករកប្រាក់ចំណូល ប្រសិនបើបុរសជាប់ពន្ធនាគារ ក្រុមគ្រួសារនឹងបាត់បង់ប្រាក់ចំណូល។ ស្ថានភាពនេះក៏បានកើតឡើងក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិចដែរ ដែលមេដឹកនាំប្រពៃណីតែងតែដើរតួជាអ្នកសម្រុះសម្រួល។ ប្រជាពលរដ្ឋជនជាតិដើមភាគតិចនៅក្នុងតំបន់ដាច់ស្រយាលភាគច្រើនប្រកបរបរជាកម្មករធ្វើការក្នុងចំការ ឬកសិដ្ឋាន។ ប្រសិនបើប្តីត្រូវបានចាប់ខ្លួន គ្រួសារនឹងបាត់កម្លាំងពលកម្ម និងបាត់ប្រាក់ចំណូល។

ទស្សនៈយល់ឃើញរបស់អាជ្ញាធរមូលដ្ឋានចំពោះជនរងគ្រោះ /ជនរងគ្រោះរស់រានជីវិត និងជនល្មើសបានឆ្លុះបញ្ចាំងពីការយល់ឃើញទាក់ទងនិងតួនាទីយេនឌ័រ និងជំនឿសន្មត់យេនឌ័រអំពីអាកប្បកិរិយារបស់បុរស និងស្ត្រីនៅក្នុងសង្គមកម្ពុជា ដូចមានចែងនៅក្នុងច្បាប់ស្រី ដែលជាក្រមសីលធម៌បែបប្រពៃណីសម្រាប់ស្ត្រី និង បានកំណត់អំពីរបៀបដែលក្មេងស្រីនិងស្ត្រីកម្ពុជាត្រូវប្រតិបត្តិខ្លួនប្រសិនបើពួកគេចង់បានការទទួលស្គាល់/មានឈ្មោះជាស្ត្រី "គ្រប់លក្ខណ៍"។ ទោះបីជាច្បាប់ស្រីបានបង្កើតឡើងជាងមួយសតវត្សរ៍មកហើយ ហើយចំណុចខ្លះនៃក្រមនេះត្រូវបានដកចេញពីកម្មវិធីសិក្សាតាំងពីឆ្នាំ២០១៧មកនោះ ខ្លឹមសារចែងនៅក្នុងក្រមនេះនៅតែមានឥទ្ធិពលនៅក្នុងសង្គម និងត្រូវបង្រៀនបន្តពីមនុស្សមួយជំនាន់ទៅមួយជំនាន់ដោយស្ងៀមស្ងាត់នៅកម្រិតគ្រួសារ។

ទស្សនៈលើកឡើងដោយភាគីពាក់ព័ន្ធបានបង្ហាញថា ភាគីពាក់ព័ន្ធនៅមិនទាន់បានយល់ដឹងពេញលេញអំពីបុព្វហេតុពិតប្រាកដនៃអំពើហិង្សាផ្លូវភេទទេ ជាពិសេសករណីនៃអំពើរំលោភសេពសន្ថវៈ ហើយជំនឿសន្មត់នៃការរើសអើងយេនឌ័រនិងពូជសាសន៍ក៏នៅតែមាននៅក្នុងចំណោមភាគីពាក់ព័ន្ធ។ កត្តាដែលបង្កើនហានិភ័យនៃអំពើហិង្សា ដូចជាគ្រឿងញៀន និងគ្រឿងស្រវឹង ត្រូវបានកំណត់ថាជាបុព្វហេតុចម្បងទៅវិញ។ ខណៈដែលបុព្វហេតុចម្បងនៃអំពើហិង្សាផ្អែកលើយេនឌ័រ រួមទាំងអំពើហិង្សាផ្លូវភេទផងនោះបណ្តាលមកពីអតុល្យភាពនៃទំនាក់ទំនងអំណាចរវាងបុរសនិងស្ត្រី នៅក្នុងវិស័យសាធារណៈ និងឯកជនដែលបន្តកើតឡើងដោយសារតែបទដ្ឋានសង្គមដែលមានចរឹករើសអើង ភាពក្រីក្រ និងប្រព័ន្ធច្បាប់ដែលមាក់ងាយស្ត្រី និងកង្វះនីតិរដ្ឋ។ ទស្សនៈនេះបានបង្កើតឲ្យមានការអនុវត្តនូវទ្វេរស្តង់ដារអំពីអាកប្បកិរិយារបស់បុរស និងស្ត្រី និងជះឥទ្ធិពលទៅលើលទ្ធភាពរបស់ពួកគេក្នុងការធ្វើសេចក្តីសម្រេចចិត្តជាពិសេសបញ្ហាទាក់ទងការសម្រេចចិត្ត សេរីភាពក្នុងការដើរហើរ សិទ្ធិផ្លូវភេទ និងសុខភាពបន្តពូជ និងសិទ្ធិនានា។ លុះត្រាតែគ្រប់ភាគី

ពាក់ព័ន្ធបានយល់ច្បាប់អំពីបញ្ហានេះ ទើបការទប់ស្កាត់និងឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះអំពើហិង្សានៅតែជាបញ្ហាប្រឈម។[57]

## ៤.៤កុមារនិងការរៀបចំរៀបអាពាហ៍ពិពាហ៍កុមារនៅក្នុងសហគមន៍ជនជាតិដើមភាគតិច

មន្ត្រីនៅមន្ទីរកិច្ចការនារីខេត្តបានទទួលស្គាល់ថា ការរៀបអាពាហ៍ពិពាហ៍វ័យក្មេងគឺជាបញ្ហានៅក្នុងខេត្ត។ ក្រុមការងារមន្ទីរកិច្ចការនារីខេត្តក៏បានសង្កត់ថា សូម្បីតែក្នុងកំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ១៩ នៅចន្លោះខែមីនា និងខែសីហា ឆ្នាំ២០២០ ក៏មានករណីរៀបអាពាហ៍ពិពាហ៍កុមារដែលមានអាយុចន្លោះពី ១៣ ទៅ១៤ ឆ្នាំចំនួនពី៨ ទៅ៩ ករណីដែរ។ ករណីទាំងនោះគឺពាក់ព័ន្ធនឹងយុវជនជនជាតិដើមភាគតិច។ មន្ទីរកិច្ចការនារីខេត្តបានបន្ថែមថាជនជាតិដើមភាគតិចហាក់ដូចជាមិនសូវខ្វល់ខ្វាយ ឬមិនសូវបានដឹងអំពីច្បាប់នោះទេ ពីព្រោះពួកគេមិនសូវបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ ពួកគេគ្រាន់តែរៀបចំធ្វើពិធីសែនព្រេនតាមប្រពៃណីតែប៉ុណ្ណោះ។[58] គ្មានស្ថិតិបង្ហាញពីប្រេវ៉ាឡង់នៃអាពាហ៍ពិពាហ៍កុមារទេ។

អាពាហ៍ពិពាហ៍កុមារច្រើនតែកើតឡើងនៅតំបន់ទីជនបទនៃប្រទេសកម្ពុជា ហើយភាគរយខ្ពស់កើតឡើងនៅក្នុងខេត្តមណ្ឌលគិរី និងរតនគិរី។ ការសិក្សាស្រាវជ្រាវមួយធ្វើឡើងក្នុងឆ្នាំ២០១៨ នៅក្នុងខេត្តរតនគិរីបានរកឃើញថា ១១ភាគរយនៃក្មេងស្រីដែលមានអាយុចន្លោះពី១២ ទៅ ១៧ឆ្នាំបានរៀបការ ហើយ១៩ភាគរយនៃក្មេងស្រីទាំងនេះមានអាយុចន្លោះពី១៥ ទៅ ១៧ឆ្នាំ។[59]

អង្គការ PLAN International ប្រចាំនៅកម្ពុជា ដែលធ្វើការផ្តោតទៅលើការដោះស្រាយអាពាហ៍ពិពាហ៍កុមារ បានរកឃើញថាអាពាហ៍ពិពាហ៍កុមារកើតឡើងដោយសារមូលហេតុខាងក្រោម៖

- ទំនៀមទំលាប់ប្រពៃណីក្នុងស្រុកដែលមានភាពលំអៀងផ្នែកយេនឌ័រ និងផ្អែកលើជំនឿថាក្មេងស្រីគួរតែរៀបការមុនអាយុ២០ឆ្នាំ ពីព្រោះបុរសនឹងមិនរៀបការជាមួយ "ស្ត្រីចំណាស់" ទេ។
- ហេតុផលផ្នែកសេដ្ឋកិច្ច ស្ថានភាពហិរញ្ញវត្ថុរបស់ក្មេងស្រី គឺត្រូវពឹងផ្អែកទៅលើបុរស។[60]ម្យ៉ាងទៀតនេះក៏ជាមធ្យោបាយមួយដើម្បីទទួលបានកម្លាំងពលកម្មបន្ថែមសម្រាប់គ្រួសារផងដែរ។ ឪពុកម្តាយរបស់ក្មេងស្រីចង់ឲ្យកូនស្រីរៀបការ ដូច្នេះប្តីអាចជួយការងារស្រែចំការគ្រួសារបាន។[61]

---

[57] អនុសាសន៍រួមលេខ ៣៥នៃអនុសញ្ញា CEDAW ស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រលើស្ត្រី, CEDAW/C/GC/35 កថាខណ្ឌ ១៩ ទំព័រ ៦។

[58] បទសម្ភាសន៍ជាមួយតំណាងមកពីមន្ទីរកិច្ចការនារីខេត្តរតនគិរី នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ នៅក្រុងបានលុង ខេត្តរតនគិរី

[59] Taing R., ស្តីពី "ការដោះស្រាយអាពាហ៍ពិពាហ៍កុមារនៅកម្ពុជា" ។ កាសែតខ្មែរថាមស៍៖ បទសម្ភាសន៍ជាមួយលោក យេ គីមថាន នៃអង្គការ PLAN International នៅកម្ពុជា នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០។

[60] ដូចខាងលើ។

[61] នេះគឺជាការអនុវត្តទៅទៅក្នុងតំបន់ភាគឥសាន ដូចជាខេត្តក្រចេះ រតនគិរី មណ្ឌលគិរី និងស្ទឹងត្រែង។

- ការរួមភេទមុនរៀបការនិងការមានផ្ទៃពោះរបស់ក្មេងវ័យជំទង់។ ដើម្បីទប់ស្កាត់កុំឲ្យក្មេងជំទងប្រឡូកក្នុងការរួមភេទមុនរៀបការ និងមានផ្ទៃពោះ ឪពុកម្តាយមួយចំនួនបានរៀបចំអាពាហ៍ពិពាហ៍ឲ្យកូនៗ ទោះបីជាកូនៗនៅមានអាយុក្មេងក៏ដោយ។ ខណៈចំណេះដឹងអំពីការរួមភេទដោយសុវត្ថិភាពនិងមធ្យោបាយពន្យារកំណើតនៅមានកំរិតនៅឡើយក្នុងចំណោមកុមារកម្ពុជា ការរួមភេទមុនរៀបការនៅតែចាត់ទុកជាសកម្មភាពមិនសមរម្យ និងមិនអាចទទួលយកបាននៅក្នុងសង្គម ហើយយុវជនដែលត្រូវបានគេដឹងលឺថាបានប្រឡូកក្នុងរឿងនេះ នឹងត្រូវប្រឈមជាមួយការមាកងាយនៅក្នុងសង្គម និងត្រូវទទួលភាពអាម៉ាស់។

នៅក្នុងឆ្នាំ២០១៧ មូលនិធិរបស់អង្គការសហប្រជាជាតិសម្រាប់កុមារ(យូនីសេហ្វ) និងអង្គការ PLAN International ប្រចាំនៅកម្ពុជាបានផ្តល់ការគាំទ្រដល់ក្រសួងកិច្ចការនារី នៅក្នុងការបង្កើតផែនការសកម្មភាពថ្នាក់ខេត្ត ដើម្បីទប់ស្កាត់អាពាហ៍ពិពាហ៍កុមារ និងការមានផ្ទៃពោះរបស់ក្មេងវ័យជំទង់ ក្នុងខេត្តរតនគិរី។[62] អង្គការមិនមែនរដ្ឋាភិបាលមួយដែលធ្វើការខាងអនុផលព្រៃឈើនៅក្នុងខេត្តរតនគិរី ដែលទទួលបានការគាំទ្រពីអង្គការអូសហ្វាម (Oxfam) តាមរយៈសម្ព័ន្ធភាពសិទ្ធិកុមារ បាននឹងកំពុងតែអនុវត្តគំរោងមួយដែលមានឈ្មោះថា "សំលេងក្មេងស្រី" ក្នុងគោលបំណងដើម្បីទប់ស្កាត់អាពាហ៍ពិពាហ៍កុមារនៅក្នុងខេត្តរតនគិរី។[63] គម្រោងនេះផ្តោតលើស្រុកចំនួន៣ នៅក្នុងខេត្តរតនគិរី។ គំរោងនេះមានគោលដៅចំនួនបីសំខាន់ៗ ពាក់ព័ន្ធនិងភាគីផ្សេងៗគ្នានៅក្នុងសហគមន៍។ ទីមួយគឺធ្វើការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីពង្រឹងការអនុវត្ត តួនាទីរបស់ពួកគេក្នុងការទប់ស្កាត់អាពាហ៍ពិពាហ៍វ័យក្មេង ឬអាពាហ៍ពិពាហ៍កុមារនៅក្នុងសហគមន៍។ ទីពីរគឺធ្វើការជាមួយឪពុកម្តាយ /សមាជិកគ្រួសារដើម្បីបង្កើនការយល់ដឹងអំពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍កុមារ នឹងត្រូវធ្វើការផ្លាស់ប្តូរពីរបៀបចិញ្ចឹមកូន។ ទីបីគឺធ្វើការដោយផ្ទាល់ជាមួយកុមារ និងយុវជនដើម្បីបង្កើនការយល់ដឹងអំពីសិទ្ធិ និងផលប៉ះពាល់នៃអាពាហ៍ពិពាហ៍កុមារមកលើជីវិតរបស់ពួកគេ។

អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ និងអនុសញ្ញាស្តីពីសិទ្ធិកុមារបានចាត់ទុក "អាពាហ៍ពិពាហ៍កុមារ និងអាពាហ៍ពិពាហ៍ដោយបង្ខំ ជាការអនុវត្តដែលបង្កឲ្យគ្រោះថ្នាក់។[64]

[62] "ក្មេងស្រី មិនមែនជាកូនក្រមុំ-បញ្ចប់អាពាហ៍ពិពាហ៍កុមារនៅកម្ពុជា"។ ចាន់., ក. និង រាម រ., ថ្ងៃទី១០ ខែមិនាឆ្នាំ២០១៧រកបាននៅ https://unicefcambodia.blogspot.com/2017/03/by-chan-kanha-and-ream-rin-romas-is.html ដកស្រង់នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០។

[63] "ការផ្សព្វផ្សាយនៃក្លឹបកុមារ អំពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍អនីតិជន"។ បិន, ស., ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០ រកបាននៅ http://www.ntfp-cambodia.org/awareness-of-child-clubs-about-impacts-of-child-marriage/ ដកស្រង់ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០។

[64] អនុសាសន៍រួម /សេចក្តីពន្យល់រួមលេខ៣១ នៃគណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងស្ត្រី និងលេខ ១៨នៃគណៈកម្មាធិការស្តីពីសិទ្ធិកុមារស្តីពីការអនុវត្តប្រកបដោយគ្រោះសថ្នាក់ CEDAW/C/GC/31-CRC/C/GC/18 ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ផ្នែក៦.២ កថាខណ្ឌ ១៩-២១ អាចរកបាន https://tbinternet.ohchr.org/_layouts/15/treatybodyexternal/Download.aspx?symbolno=CEDAW%2fC%2fGC%2f31%2fCRC%2fC%2fGC%2f18&Lang=en ដកស្រង់ថ្ងៃទី១២ ខែមិនាឆ្នាំ២០២១ ។

អាពាហ៍ពិពាហ៍កុមារក៏ត្រូវបានគេចាត់ទុកថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំផងដែរ ពីព្រោះកុមារនៅមិនទាន់មាននីតិភាពស្របច្បាប់ដើម្បីផ្តល់ការព្រមព្រៀងបានទេ។[65] រដ្ឋភាគីមានទំនួលខុសត្រូវក្នុងការធានាថា ការអនុវត្តដែលបង្កគ្រោះថ្នាក់ទាំងអស់នេះត្រូវបានលុបបំបាត់ចោល។ គណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃអំពើរើសអើងប្រឆាំងនឹងស្ត្រីភេទ បានកត់សម្គាល់ជាពិសេសថា "រដ្ឋភាគីនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ត្រូវមានកាតព្វកិច្ចផងដែរក្នុងការចាត់វិធានការ សមស្របទាំងឡាយណា ដោយរួមបញ្ចូលទាំងវិធានការពិសេសបណ្តោះអាសន្ន (មាត្រា ៤ (កថាខណ្ឌទី១) ដល់មានមាត្រា១៤ ដើម្បីកែតម្រូវនូវរាល់ការអនុវត្តផ្នែកសង្គម និងវប្បធម៌ របស់បុរស និងស្ត្រីដើម្បីសម្រេចបាននូវការលុបបំបាត់ការរើសអើង និងទំនៀមទំលាប់ និងការអនុវត្តផ្សេងទៀតទាំងឡាយណាដែលចាត់ទុកថា ភេទណាមួយនៃភេទទាំងពីរមានឧត្តមភាពជាង ឬ ទាបជាង ឬ ស្តីពីផ្នត់គំនិតនៃតួនាទីរបស់បុរស និង ស្ត្រី"។[66]

## ៤.៥. ការមាក់ងាយ និងផាត់ជនរងគ្រោះរស់រានដ៏ជីវិតចេញពីអំពើហិង្សាផ្អែកលើយេនឌ័រ

អារម្មណ៍របស់ជនរងគ្រោះរស់រានជីវិត និងផ្នត់គំនិតសហគមន៍ដែលមើលមកលើពួកគេបន្ទាប់ពីពួកគេបានរងគ្រោះដោយសារអំពើហិង្សាបានបង្ហាញនូវការមាក់ងាយ។ ជនរងគ្រោះត្រូវបានគេវិនិច្ឆ័យ មាក់ងាយ ស្តីបន្ទោស ឬ អាណិតអាសូរ ដោយសារតែអ្វីដែលបានកើតឡើងចំពោះនាង។ តម្លៃរបស់នាងត្រូវបានគេមើលឃើញថាបានធ្លាក់ចុះ។ "ការមាក់ងាយដែលបង្កឡើងដោយអំពើហិង្សាផ្លូវភេទ មិនត្រឹមតែជាការបង្ហាញពីតម្លៃ ជំនឿ ឬឥរិយាបថបុគ្គលប៉ុណ្ណោះទេ ថែមទាំងបានបង្ហាញអំពីបទដ្ឋានសង្គមដែលស្តែងឡើងតាមរយៈ អាកប្បកិរិយា និងសកម្មភាពរបស់ក្រុមមនុស្ស ឬស្ថាប័ន។ ការមាក់ងាយកើតឡើងពីបទដ្ឋានសង្គមនិងវប្បធម៌ជុំវិញវិសមភាពយេនឌ័រ និងការរំពឹងទុក ឬការយល់ឃើញនៃតួនាទីយេនឌ័រ អាកប្បកិរិយានិងការទទួលខុសត្រូវតាមបែបប្រពៃណីនៃការបែងចែកនៅក្នុងសង្គមដែលថាស្ត្រី និងក្មេងស្រីគឺជាអ្នកដែលត្រូវប្រកាន់ខ្ជាប់នូវគុណធម៌និងកិត្តិយសសម្រាប់គ្រួសារជាដើម..."[67] គួរកត់សម្គាល់ផងដែរថាសហគមន៍ជនជាតិដើមភាគតិចទាំងនេះមានចំនួនប្រជាជនតិចតួច ហើយពួកគេស្គាល់គ្នាទៅវិញទៅមក។ ដោយសារទំហំតូចនៃសហគមន៍ទាំងនេះ ការមាក់ងាយដែលបង្កឡើងដោយអំពើហិង្សាផ្អែកលើយេនឌ័រហាក់ដូចជះឥទ្ធិពលខ្លាំងទៅលើជនរងគ្រោះ ជាពិសេសនៅពេលក្រុមគ្រួសាររបស់ជនល្មើសក៏ជាផ្នែកមួយនៃសហគមន៍តែមួយ។ ដូចបានកត់សម្គាល់ដោយគណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការ

---

[65] ដូចខាងលើ។

[66] ដូចខាងលើ កថាខណ្ឌ ៣០។

[67] មេធាវី និងបណ្ឌិតផ្នែកសិទ្ធិមនុស្ស " ការយល់ដឹងអំពីយេនឌ័រ អំពើហិង្សាផ្អែកលើយេនឌ័រ និងការមាក់ងាយផ្អែកលើយេនឌ័រនៅក្នុងសហគមន៍ជនជាតិសេរ៉ី" ខែតុលា ឆ្នាំ២០១៨, ទំព័រ ៨-៩។ អាចរកបាននៅ http://ldhrights.org/en/wp-content/uploads/2018/12/LDHR-Gender-gender-based violence-and-Stigma-Mapping-Report-FINAL.pdf ដកស្រង់ថ្ងៃទី០៦ ខែមករា ឆ្នាំ២០២១។ សម្រង់សម្តីគឺជាផ្នែកនៃនិយមន័យនៅក្នុង របាយការណ៍ ហើយសម្រង់សម្តីនេះអាចនឹងអនុវត្តនៅកម្ពុជា និងប្រទេសផ្សេងៗបាន មិនមែនសម្រាប់តែប្រទេសសេរ៉ីមួយទេ។

រើសអើងប្រឆាំងនឹងស្ត្រីភេទ នៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ឆ្នាំ២០១៩ ការមាក់ងាយផ្នែកសង្គមនិងវប្បធម៌ គឺជារនាំងឧបសគ្គក្នុងការទទួលបានយុត្តិធម៌ ពីព្រោះបានរារាំងស្ត្រីនិងក្មេងស្រីពីការដាក់ពាក្យបណ្តឹងអំពើហិង្សាផ្អែកលើយេនឌ័រ។

ជនរងគ្រោះរស់រានជីវិត៣នាក់បានពោលថា ពួកគេទទួលបានការយកចិត្តទុកដាក់ពីសំណាក់សហគមន៍ ក្នុងនោះមានជនរងគ្រោះម្នាក់បញ្ជាក់ថាភរិយារបស់ជនល្មើសបានខឹងសម្បារនឹងនាង។ ជនរងគ្រោះរស់រានមានជីវិតផ្សេងទៀត បានកត់សម្គាល់ថាសហគមន៍បានផ្លាស់ប្តូររបៀបទំនាក់ទំនងជាមួយពួកគេ។ ជនរងគ្រោះម្នាក់បាននិយាយថា ខណៈដែលនាងទទួលបានការអាណិត នាងក៏ទទួលបានការសើចចំអកពីអ្នកភូមិខ្លះ ផងដែរ។ ជនរងគ្រោះរស់រានជីវិតពីរនាក់ផ្សេងទៀតបានអះអាងថា សាច់ញាតិរបស់ជនល្មើសបានជេរប្រមាថ និងបាននិយាយអាក្រក់ពីពួកគេ ដូចជាថាជនរងគ្រោះម្នាក់នោះគឺជាមនុស្សដែលចូលចិត្តចេញទៅក្រៅពេលយប់ ហើយចូលចិត្តផឹកគ្រឿងស្រវឹង។ ជនរងគ្រោះម្នាក់ទៀតនិយាយថាមានក្មេងៗអាយុប្រហែលនាងបានចោទប្រកាន់នាងថា នាងយល់ព្រមរួមភេទជាមួយគេដោយសារតែនាងចង់បានលុយ។ ជនរងគ្រោះរស់រានជីវិត៣នាក់ផ្សេងទៀតបាននិយាយថា សមាជិកសហគមន៍និងមនុស្សដែលមានអាយុស្របាលៗពួកគេបានស្តីបន្ទោស និងមាក់ងាយពួកគេចំពោះករណីរំលោភសេពសន្ថវៈ។ ជនរងគ្រោះរស់រានជីវិតផ្សេងទៀតបានពោលថា សហគមន៍សើចចំអកដោយសារតែពួកគេដោះស្រាយករណីនេះតាមរយៈការព្រមទទួលសំណង។ ក្នុងករណីនេះ បញ្ហាមួយកើតឡើងនោះគឺចំនួនទឹកប្រាក់នៃសំណងក្រុមគ្រួសារជនល្មើសបានបដិសេធមិនបង់ប្រាក់តាមចំនួនដែលបានទាមទារ។

មេដឹកនាំប្រពៃណី/ ចាស់ព្រឹទ្ធាចារ្យ បានកត់សម្គាល់ថា ជនរងគ្រោះរស់រានជីវិតត្រូវបានគេមើលឃើញក្នុងផ្នត់គំនិតផ្សេងគ្នា បន្ទាប់ពីហេតុការណ៍កើតឡើង។ ចាស់ព្រឹទ្ធាចារ្យជនជាតិគ្រឹងម្នាក់មកពីស្រុកអូរជុំ ខេត្តរតនគិរី បាននិយាយថាជនរងគ្រោះអាចនឹងបាត់បង់កិត្តិយស និងមានអារម្មណ៍ខ្មាស់អៀន ពីព្រោះនាងត្រូវបានគេមើលងាយ និងតិះដៀល។ ចាស់ព្រឹទ្ធាចារ្យមកពីស្រុកអូរយ៉ាដាវ ខេត្តរតនគិរីបាននិយាយថា ជនរងគ្រោះរស់រានជីវិតជារឿយៗច្រើនតែខ្មាស់អៀន ភ័យខ្លាច ខ្វះទំនុកចិត្តនិងមានអារម្មណ៍ថាគ្មានសុវត្ថិភាព។ ចាស់ព្រឹទ្ធាចារ្យផ្សេងទៀតមកពីស្រុកតែមួយបានយល់ស្រប ដោយកត់សម្គាល់ថាជនរងគ្រោះរស់រានជីវិតទទួលបាន"ពាក្យអាក្រក់ជាច្រើនពីអ្នកជិតខាង"។ចាស់ព្រឹទ្ធាចារ្យជនជាតិគ្រឹងមកពីស្រុកកូនមុំបាននិយាយថាសហគមន៍អាណិតដល់ជនរងគ្រោះ ហើយផ្តល់ការគាំទ្រ និងដំបូន្មានដល់នាង។ ចាស់ព្រឹទ្ធាចារ្យជនជាតិទំពួន មកពីស្រុកលំផាត់ ខេត្តរតនគិរីបាននិយាយថា "សហគមន៍គួរតែលើកទឹកចិត្តដល់ជនរងគ្រោះ និង គាំទ្រពួកគេ"។

មន្ត្រីនគបាលមិនបានដឹងអំពីក្រុមគ្រួសារណាមួយដែលទទួលរងនូវការគំរាមកំហែង ឬការរើសអើងបន្ទាប់ពីពួកគេបានរាយការណ៍ពីករណីរំលោភសេពសន្ថវៈនោះទេ។ ពួកគេជឿជាក់ថាគ្មានការរើសអើងនៅក្នុង

សហគមន៍ច្រើនទេ ពីព្រោះអ្នកភូមិមានការអាណិតអាសូរដល់ជនរងគ្រោះរស់រានមានជីវិត។ នគបាលបានសហការជាមួយដៃគូតាមរយៈការបញ្ជូនជនរងគ្រោះរស់រានមានជីវិតទៅទទួលការប្រឹក្សាពិគ្រោះយោបល់ និងបង្កើតផែនការសមាហរណ៍កម្មទៅក្នុងសហគមន៍។ នៅពេលដែលជនរងគ្រោះរស់រានមានជីវិតត្រឡប់ទៅភូមិ ពួកគេទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅ។[68]

ផ្ទុយពីការលើកឡើងខាងលើ តំណាងមន្ទីរកិច្ចការនារីខេត្តបាននិយាយថាពួកគេបានដឹងអំពីការរើសអើងប្រឆាំងនឹងស្ត្រីរងគ្រោះ។ ពួកគេបានកត់សម្គាល់ឃើញថា ជនរងគ្រោះរស់រានមានជីវិតហាក់ដូចជាធុញថប់ និងទទួលរងនូវការបាក់ទឹកចិត្ត ពួកគេមានអារម្មណ៍ខ្មាស់អៀន ឬរងនូវភាពអាម៉ាស់។ អ្នកខ្លះមិនចង់ទៅសាលារៀន ឬមិនចង់ឃើញអ្នកជិតខាង ព្រោះពួកគេដឹងថាមនុស្សទាំងនោះបានដឹងអំពីអំពើរំលោភសេពសន្ថវៈនេះ។ តំណាងមន្ទីរកិច្ចការនារីបានបញ្ជាក់ថាពួកគេតែងតែលើកទឹកចិត្តដល់ក្រុមគ្រួសារឲ្យជួយដល់ជនរងគ្រោះ។ ពួកគេព្យាយាមណែនាំផ្តល់ដំបូន្មានដល់ជនរងគ្រោះឲ្យបន្តដំណើរទៅមុខទៀត។ ប្រធានមន្ទីរកិច្ចការនារីខេត្ត បាននិយាយថាការមាក់ងាយជះឥទ្ធិពលខ្លាំង សូម្បីតែនៅក្នុងសហគមន៍ដែលមិនមែនជាជនជាតិដើមក៏ដោយ។ ការកាត់សេចក្តីថា "នាងត្រូវបានគេរំលោភ" គឺមានបង្កប់អត្ថន័យអវិជ្ជមាន ពីព្រោះមានន័យថាស្ត្រីនោះអស់ភាពបរិសុទ្ធដែលជាការបំបាក់ទឹកចិត្តដល់ជនរងគ្រោះរស់រានមានជីវិតពីអំពើរំលោភសេពសន្ថវៈ។[69]

អាជ្ញាធរមូលដ្ឋាន ជនរងគ្រោះរស់រានមានជីវិត ក្រុមគ្រួសារជនរងគ្រោះ និងចាស់ព្រឹទ្ធាចារ្យប្រពៃណី មកពីខេត្តមណ្ឌលគិរី ខេត្តរតនគិរី និងខេត្តស្ទឹងត្រែង បានបញ្ជាក់នូវអ្វីដែលតំណាងមន្ទីរកិច្ចការនារីខេត្តបានលើកឡើង។ ពួកគេបានកត់សម្គាល់ពីភាពខុសប្លែកនៃរបៀបដែលជនរងគ្រោះរស់រានមានជីវិត និងគ្រួសារត្រូវបានគេយកចិត្តទុកដាក់បន្ទាប់ពីជនរងគ្រោះរស់រានមានជីវិត /ជនរងគ្រោះរងគ្រោះអំពើហិង្សាផ្អែកលើយេនឌ័រ។ ប្រតិកម្មរបស់សហគមន៍មានចាប់តាំងពី ការអាណិតអាសូរ រហូតដល់ការមាក់ងាយ និងស្តីបន្ទោសទៅលើជនរងគ្រោះរស់រានមានជីវិត។ ក្នុងករណីខ្លះសាច់ញាតិរបស់ជនល្មើសដែលរស់នៅក្នុងសហគមន៍តែមួយបានបង្កការសម្លុតគំហែង ឬយាយីជនរងគ្រោះរស់រានមានជីវិត។ ចាំបាច់ណាស់ត្រូវមានការផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយារបស់សហគមន៍ចំពោះជនរងគ្រោះរស់រានមានជីវិត។

គប្បីមានកិច្ចការងារជាច្រើនដែលត្រូវធ្វើបន្ថែមទាក់ទងនិងការធ្វើសមាហរណ៍កម្មជនរងគ្រោះរស់រានមានជីវិតត្រឡប់ចូលក្នុងសង្គមវិញ និងដើម្បីបង្កើនការយល់ដឹងអំពីស្ថានភាពនិងតម្រូវការរបស់ពួកគេ។ ត្រូវបន្ថែមជំនួយព្យាបាលរបួសផ្លូវចិត្តដល់ជនរងគ្រោះរស់រានមានជីវិត និងក្រុមគ្រួសារដើម្បីជួយពួកគេដោះស្រាយបញ្ហា

[68] បទសម្ភាសន៍ជាមួយ ក្រុមការងារប្រឆាំងការជួញដូរ និងអនីតិជននៃស្នងការប៉ូលីសខេត្តរតនគីរី នាថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០២០ នៅក្រុងបានឡុង ខេត្តរតនគិរី។

[69] បទសម្ភាសន៍ជាមួយតំណាងមកពីមន្ទីរកិច្ចការនារីខេត្តរតនគិរី នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ នៅក្រុងបានលុង ខេត្តរតនគិរី។

បាក់ស្បាត។ ជារឿងដែលមិនគួរឲ្យបារម្ភនៅពេលដែលមន្ត្រីនគបាលថ្នាក់ខេត្ត សម្តែងការជឿជាក់ថាគ្មានការរើងអើសប្រឆាំងនឹងជនរងគ្រោះនោះ។ ប៉ុន្តែការលើកឡើងនេះតម្រូវឲ្យមានការចោទសួរអំពីផែនការសមាហរណ៍កម្មដែលបានអនុវត្តកន្លងមក ប្រសិនបើរកឃើញថាសកម្មភាពប្រព្រឹត្តរបស់សហគមន៍មកលើជនរគ្រោះមានភាពខុសប្លែកនោះ។ មន្ត្រីអាជ្ញាធរនិងក្រុមគ្រួសាររបស់ជនរងគ្រោះរស់រានជីវិតមួយចំនួនហាក់សំដែងនូវការ "អាណិតអាសូរ" ដែលជាប្រតិកម្មវិជ្ជមាន ប៉ុន្តែពួកគេមិនបានដឹងថាទោះបីជាគ្មានការសម្លុត ឬស្តីបន្ទោសទៅលើជនរងគ្រោះក៏ដោយ ការអាណិតអាសូរ ក៏ជាទម្រង់មួយនៃការរើសអើងផងដែរ ពីព្រោះបានបង្ហាញថាការគិតរបស់សហគមន៍ទៅលើជនរងគ្រោះរស់រានជីវិត គឺមានលក្ខណៈខុសពីមុន បន្ទាប់ពីនាងត្រូវបានគេរំលោភបៀតបៀន ឬរំលោភសេពសន្ថវៈ។ របៀបដែលសហគមន៍ធ្វើមកកាន់ជនរងគ្រោះរស់រានជីវិត បន្ទាប់ពីពួកគេទទួលរងអំពើហិង្សាផ្អែកលើយេនឌ័រអាចជះឥទ្ធិពលទៅដល់ជនរងគ្រោះរស់រានជិវិតផ្សេងទៀត និងបន្ទុចបង្អាក់ពួកគេមិនឲ្យរាយការណ៍ពីអ្វីដែលបានកើតឡើងចំពោះពួកគេ។

## ៤.៦.ការទទួលបានយុត្តិធម៌របស់ជនរងគ្រោះ / ជនរងគ្រោះរស់រានជីវិត

ក្រុមស្រាវជ្រាវបានសាកសួរអំពីសកម្មភាពដែលបានធ្វើឡើងអនុលោមតាមច្បាប់ និងគោលការណ៍ណែនាំដែលមានស្រាប់ បន្ទាប់ពីមានសេចក្តីរាយការណ៍អំពីអំពើហិង្សាផ្អែកលើយេនឌ័រ។ ភាគច្រើននៃអ្នកផ្តល់បទសម្ភាសបានបញ្ជាក់ថាពួកគេបានធ្វើសកម្មភាពមួយចំនួនអាចជាយន្តការផ្លូវច្បាប់ និងវិធីសាស្ត្រដោះស្រាយវិវាទដោយប្រើយន្តការបែបប្រពៃណីរបស់ជនជាតិដើមភាគតិច ឬបានប្រើប្រាស់យន្តការទាំងពីរ។ ព័ត៌មានបញ្ជាក់នៅខាងក្រោម។

### ការដោះស្រាយតាមប្រព័ន្ធយុត្តិធម៌ផ្លូវការ

អាជ្ញាធរមូលដ្ឋានបានបញ្ជាក់ថាពួកគេបានបញ្ជូនសំណុំរឿងទាំងនេះទៅអាជ្ញាធរថ្នាក់លើ ជាទូទៅគឺបញ្ជូនទៅអាជ្ញាធរឃុំ និងនគរបាលយុត្តិធម៌។ ពួកគេក៏បានព្យាយាមស្វែងរកជនល្មើស។ អាជ្ញាធរមូលដ្ឋានក៏ត្រូវបានសាកសួរថាតើពួកគេធ្លាប់បានតាមដានសំណុំដែលបានបញ្ជូនទៅអាជ្ញាធរថ្នាក់លើដែរឬទេ។មន្ត្រីអាជ្ញាធរចំនួន៤រូប មិនបានឆ្លើយតបចំពោះសំណួរនេះទេ ដោយឡែកអាជ្ញាធរ៤រូបផ្សេងទៀតបញ្ជាក់ថាពួកគេមិនបានតាមដានសំណុំរឿងទេ។ អាជ្ញាធរមួយរូបបានពន្យល់ថាមានករណីជាច្រើនដែលត្រូវបានដោះស្រាយនៅប៉ុស្តិ៍នគរបាលឃុំតាមរយៈការសម្រុះសម្រួលនិងការចរចា ជាជាងដោះស្រាយតាមប្រព័ន្ធច្បាប់ផ្លូវការ។

អាជ្ញាធរមូលដ្ឋានបីរូបបានបញ្ជាក់ថាពួកគេបានតាមដានសំណុំរឿងដែរ ប៉ុន្តែអាជ្ញាធរថ្នាក់លើមិនបានចាត់វិធានការអ្វីដើម្បីដោះស្រាយសំណុំរឿងទេ។ អាជ្ញាធរមូលដ្ឋានម្នាក់ទៀតបានបញ្ជាក់ថា ខណៈមានករណីបៀតបៀនផ្លូវភេទចំនួន២ករណីបានបញ្ជូនទៅតុលាការនោះ គ្មានកោះហៅជនសង្ស័យទៅបំភ្លឺទេ។ អាជ្ញាធរ ម្នាក់ទៀតបានបញ្ជាក់ថា បុគ្គលដែលបានរាយការណ៍មកគាត់ក៏បានដាក់បណ្តឹងទៅអាជ្ញាធរថ្នាក់លើផងដែរ តែមានតែមេភូមិប៉ុណ្ណោះដែលបន្តការស៊ើបអង្កេត។

ការតាមដានសំណុំរឿងជាមួយអាជ្ញាធរថ្នាក់លើ ជាធម្មតាមានន័យថាអាជ្ញាធរមូលដ្ឋានបានពិនិត្យលើករណីនេះរហូតដល់មួយឆ្នាំ។ ពួកគេក៏បានប្រមូលព័ត៌មានថ្មីៗហើយបញ្ជូនបន្តទៅអាជ្ញាធរថ្នាក់លើ។ មានអាជ្ញាធរ មូលដ្ឋានមួយចំនួនបានព្យាយាមយ៉ាងសកម្មដើម្បីធ្វើការជាមួយអាជ្ញាធរថ្នាក់លើ ដើម្បីស៊ើបអង្កេត និងជួយដោះស្រាយករណីនេះ។

ការស្រាវជ្រាវរកឃើញថា អាជ្ញាធរថ្នាក់លើហាក់មិនបានតាមដាននិងធ្វើការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះករណីដែលអាជ្ញាធរមូលដ្ឋានបានបញ្ជូនទៅពួកគេទេ។ ការដែលមានករណីខ្លះត្រូវបានដោះស្រាយនៅត្រឹមតែប៉ុស្តិ៍នគរបាលឃុំ គឺជារឿងដែលគួរឲ្យព្រួយបារម្ភពីព្រោះនគបាលយុត្តិធម៌មានកាតព្វកិច្ចបញ្ជូនសំណុំរឿងក្តីទៅតុលាការ និងមិនគួរដោះស្រាយរឿងក្តីដោយខ្លួនឯងឡើយ។ ហេតុនេះនាំឲ្យលទ្ធភាពទទួលបានយុត្តិធម៌របស់ជនរងគ្រោះនិងក្រុមគ្រួសារនៅមានកំរិត។

## ការចាប់ខ្លួន និងផ្តន្ទាទោសជនជាប់សង្ស័យ

យោងតាមអាជ្ញាធរមូលដ្ឋាន មានការចាប់ខ្លួនជនល្មើសនៅក្នុង៧ករណី ខណៈដែល ១១ករណីទៀតពុំមានការចាប់ខ្លួនឡើយ។[70] ក្នុងករណីខ្លះអាជ្ញាធរមូលដ្ឋានមិនបានពន្យល់ពីមូលហេតុដែលនាំអោយគ្មានការចាប់ខ្លួនទេ។ ចំនុចខាងក្រោមនេះគឺជាហេតុផលផ្តល់ឲ្យសម្រាប់ការខកខានក្នុងការចាប់ខ្លួនៈ

- ក្រុមគ្រួសារជនរងគ្រោះជឿជាក់ថា ពួកគេមិនមានអំណាច ឬធនធានដើម្បីឲ្យមានចាប់ខ្លួនជនល្មើសបានឡើយ
- ជនរងគ្រោះមិនបានចង្អុលបង្ហាញថាតើជនល្មើសជានណា ដោយសារតែនាងមិនអាចនិយាយភាសាខ្មែរបាន
- ជនល្មើសមិនត្រូវបានចាប់ខ្លួនដោយសារតែពាក្យបណ្តឹងមិនមានឈ្មោះនិងអាស័យដ្ឋានរបស់ជនល្មើស ហើយជនល្មើសបានរត់គេចខ្លួន
- ជនល្មើសមិនត្រូវបានចាប់ខ្លួន ពីព្រោះគេបានផ្តល់សំណងដល់ក្រុមគ្រួសារជនរងគ្រោះ និងផ្តល់ប្រាក់ដល់អាជ្ញាធរ ចំនួន ៣.០០០ ដុល្លារ
- អាជ្ញាធរបានបញ្ជូនខ្លួនជនរងគ្រោះទៅប៉ុស្តិ៍នគរបាលដើម្បីពិនិត្យកោសល្យវិច្ច័យ ប៉ុន្តែពុំមានភស្តុតាងច្បាស់លាស់
- ជនល្មើស គឺជាពូរបស់ជនរងគ្រោះ ហើយក្រុមគ្រួសារមិនចង់ឲ្យមានការចាប់ខ្លួន និង

[70] រឿងក្តីតែមួយដែលមានចារីច្រើនអ្នក ក្នុងនោះមានម្នាក់ត្រូវចាប់ខ្លួន និងពីរនាក់ទៀតរត់គេចខ្លួន។

- បន្ទាប់ពីបានដាក់ពាក្យបណ្តឹងនៅក្នុងតុលាការ តុលាការ ជាអ្នកទទួលខុសត្រូវក្នុងការចាប់ខ្លួនជនល្មើស។

សាច់ញាតិជនរងគ្រោះរស់រានមានជីវិតចំនួន ៧នាក់ បានពោលថាជនល្មើសត្រូវបានចាប់ខ្លួន។ សាច់ញាតិជនរងគ្រោះម្នាក់បានកត់សម្គាល់ថា នៅក្នុងករណីសាច់ញាតិរបស់គាត់មានជនល្មើសច្រើននាក់ (បីនាក់ជាជនជាតិដើមភាគតិច និងម្នាក់ទៀតមិនមែនជាជនជាតិដើមភាគតិចទេ) ហើយមានជនល្មើសតែម្នាក់ប៉ុណ្ណោះដែលត្រូវបានចាប់ខ្លួន។ សាច់ញាតិជនរងគ្រោះបួននាក់ផ្សេងទៀតបានកត់សម្គាល់ថាជនល្មើសត្រូវបានចាប់ខ្លួន និងកំពុងជាប់ពន្ធនាគារ។ សាច់ញាតិជនរងគ្រោះម្នាក់ទៀតបាននិយាយថា ជនល្មើសត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ១៥ ឆ្នាំ។ សាច់ញាតិជនរងគ្រោះម្នាក់ផ្សេងទៀតបានពោលថាជនល្មើសត្រូវបានចាប់ខ្លួនប៉ុន្តែត្រូវបានដោះលែងវិញហើយ។ មួយភាគបីនៃសាច់ញាតិជនរងគ្រោះបានបញ្ជាក់ថាខណៈដែលជនល្មើសត្រូវបានចាប់ខ្លួន ពួកគេមិនប្រាកដថាតើជនល្មើសកំពុងជាប់ពន្ធនាគារឬទេ។

សាច់ញាតិជនរងគ្រោះចំនួន៥នាក់បានបញ្ជាក់ថា ជនល្មើសមិនត្រូវបានចាប់ខ្លួនទេ។ មានមួយករណីសាច់ញាតិជនរងគ្រោះបានបញ្ជាក់ថា ដោយសារតែជនរងគ្រោះបានសម្រេចចិត្តដោះស្រាយរឿងនេះតាមមធ្យោបាយបែបប្រពៃណី។ មានពីរករណីជនដៃដល់បានរត់គេចខ្លួនមុនពេលចាប់ខ្លួន។ ពីរករណីទៀតសាច់ញាតិជនរងគ្រោះ មិនបានផ្តល់ព័ត៌មានអំពីមូលហេតុដែលជនល្មើសមិនត្រូវបានចាប់ខ្លួន។ សាច់ញាតិជនរងគ្រោះពីរនាក់ទៀត មិនបានឆ្លើយតបទេ។

ការខកខានក្នុងការចាប់ខ្លួនជនល្មើស បង្ហាញពីភាពទន់ខ្សោយនៅក្នុងដំណើរការនៃការស៊ើបអង្កេតរបស់នគបាលយុត្តិធម៌ និងអាជ្ញាធរមូលដ្ឋានដែលមិនអាចកំណត់អត្តសញ្ញាណជនល្មើសបាន ហើយហាក់ដូចជាមិនបានខិតខំប្រឹងប្រែងដើម្បីស្វែងរកជនល្មើស នៅពេលពួកគេបានចាកចេញពីតំបន់នោះ។ កង្វះនូវកិច្ចសហការរវាងប៉ុស្តិ៍នគរបាលឃុំ និងនគរបាលថ្នាក់ខេត្ត ក្នុងការចែករំលែកព័ត៌មានអំពីជនល្មើស និងស្នើសុំឲ្យមានការចាប់ខ្លួន។ កង្វះការគាំទ្រដល់ជនរងគ្រោះនិងក្រុមគ្រួសារ ដែលគ្មានលទ្ធភាពបន្តរឿងក្តីព្រហ្មទណ្ឌ និងធ្វើដំណើរទៅតុលាការ ដោយសារតែគ្មានជំនួយពីខាងក្រៅទាំងផ្នែកហិរញ្ញវត្ថុ និងជំនួយផ្នែកច្បាប់ក៏បាន រកឃើញផងដែរ។ ការសហការរវាងមន្ត្រីនគរបាលយុត្តិធម៌ និងសាលាដំបូងខេត្ត ជាពិសេសការិយាល័យព្រះរាជអាជ្ញាគួរតែត្រូវបានកែលម្អ ឬធ្វើអោយប្រសើរជាងនេះ។ ការខកខានក្នុងការចាប់ខ្លួន និងបង្កើតការ ទទួលខុសត្រូវនៅក្នុងប្រព័ន្ធច្បាប់ រួមចំណែកធ្វើឲ្យមានការប្រើប្រាស់យន្តការដោះស្រាយតាមបែបប្រពៃណី ដែលផ្តោតទៅលើការចរចា និងសំណងហិរញ្ញវត្ថុ ជំនួសឲ្យការចាប់ខ្លួន ការកាត់ទោស និងការផ្តន្ទាទោស។

## ការដាក់ពាក្យបណ្តឹង

អនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ពាក្យបណ្ដឹងព្រហ្មទណ្ឌអាចត្រូវធ្វើឡើងដោយជនរងគ្រោះដោយផ្ទាល់ ឬ សាច់ញាតិជិតស្និទ្ធរបស់ជនរងគ្រោះ ឬដោយនគរបាលយុត្តិធម៌។ មន្ត្រីនគរបាលយុត្តិធម៌មានកាតព្វកិច្ចទទួលខុសត្រូវក្នុងការចាប់ខ្លួនជនសង្ស័យដែលត្រូវបានចោទប្រកាន់ និងនាំខ្លួនទៅកាន់តុលាការដើម្បីឲ្យព្រះរាជអាជ្ញាធ្វើសេចក្ដីសម្រេចថាតើគួរបើកសំណុំរឿងបទចោទឬអត់។ ព្រះរាជអាជ្ញាត្រួតពិនិត្យភ័ស្តុតាងដែលចងក្រងបានដោយមន្ត្រីនគរបាលយុត្តិធម៌ទាំងអស់ បន្ទាប់ធ្វើសេចក្ដីសម្រេចថាគួរឃុំខ្លួន ជនសង្ស័យនិងបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរ ឬក្នុងករណីដែលមានភ័ស្តុតាងមិនគ្រប់គ្រាន់ ដើម្បី ឃុំខ្លួនជនសង្ស័យ និង / ឬកសាងសំនុំរឿង។ បន្ទាប់មកចៅក្រមស៊ើបសួរ នឹងបើកការស៊ើបសួររួមទាំងការសាកសួរទៅសាក្សីពាក់ព័ន្ធ និងជនរងគ្រោះ និងធ្វើសេចក្ដីសម្រេចថាបើកសវនាការជំនុំជម្រះពេញអង្គសេចក្ដីដែរឬទេ។ ជនរងគ្រោះក៏អាចដាក់ពាក្យបណ្ដឹងរដ្ឋប្បវេណីនៅពេលដែលសំណុំរឿងមកដល់ដៃចៅក្រមស៊ើបសួរ។ ប្រសិនបើការជំនុំជម្រះអង្គសេចក្ដីត្រូវបានធ្វើឡើង ជនរងគ្រោះរស់រានជីវិតរួមជាមួយសាក្សីផ្សេងទៀត នឹងត្រូវបានកោះហៅមកផ្ដល់សក្ខីកម្ម។[71]

ជនរងគ្រោះរស់រានជីវិតចំនួន ៩នាក់ក្នុងចំណោម ១០នាក់បានបញ្ជាក់ថា ពួកគេបានដាក់ពាក្យបណ្ដឹងទៅមេភូមិ អាជ្ញាធរឃុំ និង/ឬប៉ុស្ដិ៍នគបាល និងតុលាការ។ មានមួយករណីដែលក្រុមគ្រួសារជនរងគ្រោះបានដាក់ពាក្យបណ្ដឹងទៅប៉ុស្ដិ៍នគរបាលមូលដ្ឋាន តែក្រោយមកបានសម្រេចដោះស្រាយវិវាទតាមបែបប្រពៃណីវិញដោយយល់ព្រមទទួលសំណងជាទឹកប្រាក់ចំនួន៣០០០ដុល្លារអាមេរិក។ ប៉ុន្តែរហូតមកដល់ពេលនេះពួកគេបានទទួលសំណងត្រឹមតែ១៥០០ដុល្លារប៉ុណ្ណោះ។ ជនរងគ្រោះរស់រានជីវិតម្នាក់ផ្សេងទៀតមិនបានដាក់ពាក្យបណ្ដឹងទេហើយបានសម្រេចចិត្តដោះស្រាយវិវាទតាមបែបប្រពៃណីដោយទាមទារសំណងដោយផ្ទាល់ពីជនល្មើស ប៉ុន្តែជនល្មើសមិនបានសារភាព ឬយល់ព្រមផ្ដល់សំណងឡើយ។

ជនរងគ្រោះរស់រានជីវិតពីរនាក់បានបញ្ជាក់ថា អាជ្ញាធរមិនបានចាត់វិធានការណាមួយចំពោះបណ្ដឹងរបស់ពួកគេទេ។ ដោយឡែកជនរងគ្រោះរស់រានជីវិតប្រាំបីនាក់ផ្សេងទៀត បានពោលថា អាជ្ញាធរបានចាត់វិធានការលើបណ្ដឹងរបស់ពួកគេ។ ជនរងគ្រោះរស់រានជីវិតម្នាក់បាននិយាយថា អាជ្ញាធរបានមកដល់ភូមិរបស់នាងហើយនៅពេលដែលជនល្មើសត្រូវបានចាប់ខ្លួន គាត់បានអះអាងថាជនល្មើសនឹងមិនជាប់ពន្ធនាគារយូរទេពីព្រោះជនល្មើសបានបង់ប្រាក់ចំនួន៦០០០ដុល្លារអាមេរិក។ គាត់បានអះអាងបន្ថែមទៀតថាមេភូមិនិងនគបាលហាក់ដូចជាបានចរចាជាមួយជនល្មើស ដោយគ្មានវត្តមានជនរងគ្រោះរស់រានជីវិតចូលរួមទេ។

ជនរងគ្រោះរស់រានជីវិតម្នាក់ទៀតបានត្អូញត្អែរថា ខណៈដែលអាជ្ញាធរមូលដ្ឋានបានចាត់វិធានការលើបណ្ដឹងរបស់នាងអាជ្ញាធរខេត្តមិនមានសកម្មអ្វីលើបណ្ដឹងរបស់នាងទេ និងពន្យារពេលជាហូរហែរ។

---

[71] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ៤-៦ និងសូមមើលមាត្រា ១៣-១៥ ស្ដីពីក្រមរដ្ឋប្បវេណីផងដែរ។

ជនរងគ្រោះរស់រានដ្ឋជីវិតចំនួន ៣នាក់ បានប្រាប់ហេតុផលដែលពួកគេមិនដាក់ពាក្យបណ្ដឹងថា៖ ពួកគេភ័យខ្លាចជនល្មើស ពួកគេភ័យខ្លាចថាអ្នកភូមិមើលមកពួកគេថាជាជនគួរឲ្យអាណិតដែលនឹងនាំមកនូវការឈឺចាប់ ពួកគេមិនដឹងថាតើត្រូវទៅសុំជំនួយពីអ្នកណា ពួកគេភ័យខ្លាចថាមិនឈ្នះក្នុងរឿងក្ដីពីព្រោះជនល្មើសមានលុយច្រើន និងដោយសារនាងមិនអាចនិយាយភាសាខ្មែរបានត្រឹមត្រូវ។

## ស្ថានភាពនានានៃករណីរំលោភសេពសន្ថវៈ

យោងតាមព័ត៌មានផ្ដល់ដោយជនរងគ្រោះរស់រានដ្ឋជីវិត មានជនល្មើសចំនួន៥នាក់ត្រូវបានចាប់ខ្លួន ហើយជនល្មើស ៥ នាក់ទៀតកំពុងតែរត់គេចខ្លួននៅឡើយ។ ពួកគេក៏បានកត់សម្គាល់ថា ខណៈជនល្មើសត្រូវបានចាប់ ខ្លួននោះ ពួកគេក៏មិនប្រាកដថាជនល្មើសទាំងនោះកំពុងតែជាប់ពន្ធនាគារឬអត់ទេ។




មានករណីមួយ ក្នុងចំណោមករណីជាច្រើននៅតុលាការ គឺកំពុងស្ថិតក្នុងដំណាក់កាលស៊ើបអង្កេត។ ករណីចំនួន៣ផ្សេងទៀត កំពុងស្ថិតក្នុង ដំណាកកាលរង់ចាំ ប៉ុន្ដែមិនដឹងច្បាស់ ថាស្ថិតក្នុងដំណាក់កាលណាមួយ។ មានករណីមួយក្នុងចំណោម ករណីទាំង៣នេះ ជនល្មើសត្រូវបានតុលាការផ្ដន្ទាទោសនិងរឿងក្ដីត្រូវបានបិទ។

ចំណែកករណីពីរទៀត នគបាលនៅប៉ុស្ដិ៍បានទទួលដោះស្រាយ ហើយនគបាលបានដោះស្រាយរឿងមួយករណីតាមរយៈការចរចាផ្ដល់ជាសំណង។ ចំណែកមួយករណីទៀតគឺត្រូវបានដោះស្រាយដោយចាស់ព្រឹទ្ធាចារ្យជនជាតិដើមភាគតិច តាមបែបប្រពៃណី (ការចរចា និងផ្ដល់ជាសំណង)។ ជនរងគ្រោះរស់រានដ្ឋជីវិតម្នាក់បានកត់សម្គាល់ថា មានមួយករណីត្រូវបានដោះស្រាយទាំងតាមប្រព័ន្ធតុលាការ និងតាមបែបប្រពៃណី។ ប្រព័ន្ធតុលាការបានផ្ដន្ទាទោសជនល្មើសឲ្យជាប់ពន្ធនាគារ ប៉ុន្ដែយន្ដការបែបប្រពៃណីជនជាតិដើមភាគតិចចារ៉ាយ គឺតម្រូវឲ្យជនល្មើសបូជាក្របីមួយក្បាលដល់អ្នកភូមិរបស់ជនរងគ្រោះរស់រានដ្ឋជីវិត។ ជនរងគ្រោះរស់រានដ្ឋជីវិតចំនួន៣នាក់បានពោលថា ពួកគេមានសាច់ញាតិដែលបានឃើញនូវហេតុការណ៍។ ជនរងគ្រោះរស់រានដ្ឋជីវិតចំនួន ២នាក់បានអះអាងថា ពួកគេមានសំណុំរឿងពាក្យបណ្ដឹង ប៉ុន្ដែម្នាក់ទៀតមិនដឹងថាពាក្យបណ្ដឹងកំពុងតែរក្សាទុកនៅកន្លែងណាទេ។ ជនរងគ្រោះរស់រានដ្ឋជីវិតចំនួន ៥នាក់ទៀតបាននិយាយថា ពួកគេគ្មានសាក្សី ឬភស្ដុតាងដើម្បីគាំទ្របណ្ដឹងរបស់ពួកគេទេ។

នៅពេលដែលសួរនាំអំពីចំណាប់អារម្មណ៍ទាក់ទងនិងលទ្ធផលនៃសំណុំរឿង ជនរងគ្រោះរស់រានក្តីជីវិតមួយចំនួនបានបង្ហាញការពេញចិត្តជាមួយនឹងលទ្ធផល ពីព្រោះជនល្មើសត្រូវបានសម្រេចឲ្យជាប់ពន្ធនាគារ។ ជនរងគ្រោះរស់រានក្តីជីវិតម្នាក់ពោលថានាងសប្បាយចិត្តដោយឃើញជនល្មើសជាប់ពន្ធនាគារ ប៉ុន្តែនាងតូចចិត្តពីព្រោះអ្នកភូមិដឹងថានាងត្រូវបានគេចាប់រំលោភ។ អ្នកនៅរស់រានក្តីជីវិតម្នាក់ទៀតបានបង្ហាញការភ័យខ្លាចថាជនល្មើសអាចនឹងជួលនរណាម្នាក់ធ្វើបាបនាងនៅពេលនាងនៅម្នាក់ឯង។

ជនរងគ្រោះរស់រានក្តីជីវិតចំនួន២នាក់ មិនសប្បាយចិត្តជាមួយនឹងលទ្ធផលនៃសំនុំរឿងក្តីរបស់ពួកគេទេ។ ជនរងគ្រោះរស់រានក្តីជីវិតម្នាក់ផ្សេងទៀត មិនយល់ស្របនឹងការកាត់ទោសឲ្យជនល្មើសជាប់ពន្ធនាគាររយៈពេល៨ឆ្នាំនោះទេ នាងយល់ថាជនល្មើសគួរតែទទួលបានការកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតចំពោះទង្វើដែលជនល្មើសបានធ្វើបាបរូបរាងកាយ និងផ្លូវចិត្តនាង។ ជនរងគ្រោះរស់រានក្តីជីវិតម្នាក់ទៀតបាននិយាយថា នាងមិនពេញចិត្តនិងលទ្ធផលនៃសំនុំរឿងក្តីនាងទេ ប៉ុន្តែនាងមិនបានពន្យល់ពីមូលហេតុទេ។

សាច់ញាតិជនរងគ្រោះរស់រានក្តីជីវិតបានអះអាងថា មានសំណុំរឿង៤ករណីត្រូវបានបញ្ជូន និងដោះស្រាយនៅតុលាការ។ សាច់ញាតិជនរងគ្រោះរស់រានក្តីជីវិតម្នាក់បានពន្យល់ថា មានមួយករណីបានបញ្ជូនទៅតុលាការ ដោយសារតែគ្រួសាររបស់ជនល្មើសមិនព្រមដោះស្រាយតាមយន្តការបែបប្រពៃណី។ ហើយករណីផ្សេងទៀត កំពុងរង់ចាំដោះស្រាយ។ សាច់ញាតិជនរងគ្រោះរស់រានក្តីជីវិតម្នាក់ផ្សេងទៀតបានកត់សម្គាល់ថាមានមួយករណីកំពុងរង់ចាំដោះស្រាយនៅតុលាការ ប៉ុន្តែបានដោះស្រាយតាមបែបប្រពៃណីរួចរាល់ហើយ។

សាច់ញាតិជនរងគ្រោះរស់រានក្តីជីវិតចំនួន៣នាក់បាននិយាយថា សំណុំងរបស់ពួកគេនៅមិនទាន់បានបិទបញ្ចប់នៅឡើយទេ។ សាច់ញាតិជនរងគ្រោះរស់រានក្តីជីវិតម្នាក់ជឿជាក់ថា ករណីនេះអាចជំរុញឲ្យទៅមុខបាន លុះត្រាតែមានការគាំទ្រពីអង្គការក្រៅរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត។ គាតថាខ្លួនគាត់ និងក្រុមគ្រួសារមានអារម្មណ៍ថាអស់សង្ឃឹមនិងមិនសប្បាយចិត្តទេ ពីព្រោះជនល្មើសមានដល់ទៅ៤នាក់ ប៉ុន្តែមានតែ ជនល្មើសម្នាក់ប៉ុណ្ណោះដែលត្រូវបានចាប់ខ្លួន។ គាត់បានបន្ថែមទៀតថា លុះត្រាតែជនល្មើស ៣នាក់ត្រូវបានចាប់ខ្លួនទើបពួកគេមានក្តីសង្ឃឹមច្រើន។

សាច់ញាតិជនរងគ្រោះរស់រានក្តីជីវិតចំនួន៣នាក់ បានសម្តែងការពេញចិត្តចំពោះលទ្ធផលនៃសំនុំរឿងក្តីនេះ។ សាច់ញាតិជនរងគ្រោះរស់រានក្តីជីវិតម្នាក់បានបញ្ជាក់ថា"ករណីនេះទទួលបានលទ្ធផលល្អជនរងគ្រោះសប្បាយចិត្តនឹងលទ្ធផលនេះ ហើយករណីនេះត្រូវបានអនុវត្តទៅតាមក្របខ័ណ្ឌច្បាប់"។ សាច់ញាតិជនរងគ្រោះរស់រានក្តីជីវិតម្នាក់ទៀតបាននិយាយថា "ជនរងគ្រោះទទួលបានយុត្តិធម៌ហើយសប្បាយចិត្ត និងពេញចិត្តចំពោះលទ្ធផលនេះ"។ ឪពុកជនរងគ្រោះរស់រានក្តីជីវិតម្នាក់បានពោលថា គាត់មិនចង់មានជម្លោះជាមួយ

ជនល្មើសទៀតទេ ព្រោះពួកគេជាសាច់ញាតិនឹងគ្នាហើយពួកគេមិនចង់មានការស្អប់ ចងកំហឹង ឬការអាក់អន់ចិត្តនឹងគ្នាទៀតទេ។

អ្នកសរសេររបាយការណ៍ស្រាវជ្រាវទាំងពីររូបបានជួបជាមួយចៅក្រមដែលជាប្រធាន និងព្រះរាជអាជ្ញាអមសាលាដំបូងខេត្តរតនគិរី។ អ្នកទាំងពីរបានបញ្ជាក់ថា ពួកគេទើបតែចូលកាន់កាប់តួនាទីរបស់ពួកគេនៅសាលាដំបូងខេត្តរតនគិរីនាពេលថ្មីៗនេះដូច្នេះពួកគេមិនទាន់ដឹងច្បាស់ពីករណីអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងនឹងស្ត្រីជនជាតិដើមភាគតិចទេ។ លោកប្រធានតុលាការបានពោលថា លោកបានដឹងថាមានករណីអំពើហិង្សាក្នុងគ្រួសារ។ លោកបន្តថា មានការពិបាកក្នុងការផ្តល់តួលេខជាក់លាក់ពីព្រោះសំណុំរឿងបញ្ជូនមកតុលាការមិនត្រូវបានធ្វើចំណាត់ថ្នាក់ថាជាករណីអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាលើស្ត្រី ឬអំពើរំលោភសេពសន្ថវៈ និងឃាតកម្មនោះទេ (សំណុំរឿងត្រូវបែងចែកជាអំពើហិង្សា ឃាតកម្ម ឬមនុស្សឃាត)។ លោកបញ្ជាក់ថាលោកមិនបានដឹងអំពីករណីជនជាតិដើមភាគតិចដែរ ដោយសារតែទិន្នន័យនៅតុលាការមិនត្រូវបានបែងចែកតាមជាតិពិន្ទុទេ។ លោកបន្តកត់សម្គាល់ថា ជនជាតិដើមភាគតិចភាគច្រើននៅតែស្មោះត្រង់ និងនិយាយបែបត្រង់ៗនៅពេលមានការសួរដេញដោលនៅក្នុងសវនាការ។ ដោយឡែកគូភាគីដែលមិនមែនជាជនជាតិដើមភាគតិចភាគច្រើន ចូលចិត្តនិយាយបង្វែងដាននិងមានល្បិចកលក្នុងការដោះស្រាយ។ លោកសន្និដ្ឋានថា ប្រហែលជាអាចមានករណីអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងនឹងស្ត្រីជនជាតិដើមភាគតិចជាច្រើនអាចបណ្តាលមកពីជនជាតិដើមភាគតិចមិនសូវមានចំណេះដឹងអំពីច្បាប់ ឬពួកគេមិនខ្វល់ខ្វាយអំពីច្បាប់។ លោកបានបញ្ជាក់ថាជនជាតិដើមភាគតិចមានទំនោរទៅរកការអនុវត្តតាមបែបប្រពៃណី ហើយការណ៍នេះបង្កភាពងាយស្រួលដល់ពួកគេក្នុងការប្រើអំពើហិង្សាដើម្បីដោះស្រាយបញ្ហា។ បន្ថែមថាលោកបង្ហាញការយល់ឃើញថា ជនជាតិដើមភាគតិចមិនសូវខ្លាចរអារមន្ត្រីនគបាលនោះទេ។ ប្រសិនបើពួកគេប្រព្រឹត្តបទល្មើសដូចជា ការកាប់ឈើខុសច្បាប់ ឬដឹកជញ្ជូនឈើខុសច្បាប់ ហើយនគបាលព្យាយាមបញ្ឈប់សកម្មភាពរបស់ពួកគេ ជនជាតិដើមភាគតិចមិនរត់គេចខ្លួនឡើយ។ ផ្ទុយទៅវិញពួកគេប្រឈមមុខជាមួយនឹងនគបាលដោយប្រើកាំបិត និងពូថៅ ដើម្បីប្រយុទ្ធតបត ខណៈដែលឧក្រិដ្ឋជនមិនមែនជនជាតិដើមភាគតិចរត់គេចខ្លួនបាត់។[72]

លោកព្រះរាជអាជ្ញាបានមានប្រសាសន៍ថា គាត់មិនអាចផ្តល់នូវទិន្នន័យអំពីករណីអំពើហិង្សាបានទេ ហើយស្នើឲ្យក្រុមស្រាវជ្រាវដាក់លិខិតស្នើសុំទិន្នន័យនេះទៅក្រសួងយុត្តិធម៌ដោយផ្ទាល់។ លោកបានធ្វើការកត់សម្គាល់ថា ការប្រើប្រាស់ភាសាខុសគ្នានៅតែជាឧបសគ្គ និង ជាបញ្ហាប្រឈមមួយសម្រាប់ជនជាតិដើមភាគតិចជាពិសេសនៅក្នុងខេត្តរតនគិរីដែលមានការប្រើប្រាស់ភាសាជនជាតិដើមភាចគតិចជាច្រើនផ្សេងៗ

[72] បទសម្ភាសន៍ជាមួយលោកប្រធានតុលាការ និងប្រធានអយ្យការនៃសាលាដំបូងខេត្តរតនគិរី ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ នៅក្រុងបានលុង ខេត្តរតនគិរី។ លោកប្រធានតុលាការ បានស្នើឲ្យក្រុមស្រាវជ្រាវដាក់សំណើរជាលាយលក្ខអក្សរសម្រាប់ស្នើសុំស្ថិតិនានា ហើយក្រុមអ្នកស្រាវជ្រាវក៏បានដាក់សំណើរផ្ញើជូនទៅផ្នែករដ្ឋបាលរបស់ស្ថាប័នតុលាការ។ ប៉ុន្តែក្រុមស្រាវជ្រាវមិនបានទទួលនូវស្ថិតិទាំងនោះទេ។

គ្នា។ ខាងតុលាការបានព្យាយាមឆ្លើយតបចំពោះតម្រូវការរបស់ពួកគេ រួមទាំងការជ្រើសរើសមន្ត្រីតុលាការដែលអាចនិយាយភាសាជនជាតិដើម ឬតាមរយៈការផ្តល់អ្នកបកប្រែភាសា ឬអញ្ជើញសាច់ញាតិរបស់ពួកឲ្យជួយក្នុង ការបកប្រែភាសា។ លោកបានលើកឡើងអំពីការអនុវត្តបែបប្រពៃណីដូចជា ការរួមភេទវ័យក្មេងមុននីតិភាព ថាជាសកម្មភាពខុសច្បាប់ ទោះបីជាការួមភេទនោះកើតឡើងដោយការព្រមព្រៀងក៏ដោយ។ លោកជឿជាក់ថានេះគឺជាការអនុវត្តបែបប្រពៃណី ដូច្នេះព្រះរាជអាជ្ញាមិនអាចចាត់វិធានការអ្វីទាំងអស់ ប្រសិនបើជនជាតិដើមភាគតិចមិនបានដាក់ពាក្យបណ្តឹង។ លោកក៏បានផ្សារភ្ជាប់បញ្ហានេះទៅនឹងភាពខ្សោយនៃការអប់រំ និង ផ្សព្វផ្សាយ។ លោកបញ្ជាក់ថានគរបាលយុត្តិធម៌មានតួនាទីអប់រំអំពីសកម្មភាពនានាដែលផ្ទុយនឹងច្បាប់។ ក្នុងនាមលោកជាព្រះរាជអាជ្ញា លោកគ្មានអាណត្តិការងារក្នុងការអប់រំសហគមន៍ដោយផ្ទាល់ទេ។ លោកបានកត់សម្គាល់ពីបញ្ហាប្រឈមនៅក្នុងការអនុវត្តច្បាប់ថា ដើម្បីធានាឲ្យបាននូវការអនុវត្តន៍បែបប្រពៃណី ដែលស្របជាមួយច្បាប់ជាតិ និងកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ។ លោកបញ្ជាក់អំពីការលំបាកដែលបានជួបប្រទះ នៅពេលដែលលោកព្យាយាមចូលទៅក្នុងសហគមន៍ជនជាតិដើមភាគតិចដោយមិនប្រើប្រាស់តួនាទីជា ព្រះរាជអាជ្ញា។ សហគមន៍ជនជាតិដើមភាគតិចបានទាមទារឲ្យលោកធ្វើពិធីសែនព្រេននិងស្នើរសុំការអនុញ្ញាតិជាមុន។[73]

ភាគច្រើននៃជនរងគ្រោះរស់រានក្តីជីវិត និងក្រុមគ្រួសារបានបញ្ជាក់ថាអាជ្ញាធរមូលដ្ឋានបានឆ្លើយតប និងបានចាត់វិធានការភ្លាមៗបន្ទាប់ពីពួកគេបានរាយការណ៍ពីហេតុការណ៍ដែលបានកើតឡើង។ ប៉ុន្តែពួកគេរួមទាំង អាជ្ញាធរមូលដ្ឋានមួយចំនួនផងដែរបានមើលឃើញនូវភាពអសកម្ម និងការពន្យារពេលដោះស្រាយពីសំណាក់អាជ្ញាធរថ្នាក់លើ ជាពិសេសអាជ្ញាធរថ្នាក់ខេត្ត។លើសពីនេះមានករណីចំនួនពីរដែលមន្ត្រីនគបាលស្រុកបានធ្វើការដោះស្រាយរឿងដោយខ្លួនឯង ដែលផ្ទុយនឹងនីតិវិធីដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ កង្វះការគាំទ្រទៅដល់ជនរងគ្រោះរស់រានក្តីជីវិត និងក្រុមគ្រួសារ ដែលមិនអាចដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌ និងធ្វើដំណើរទៅតុលាការបានដោយសារគ្មានជំនួយពីខាងក្រៅទាំងផ្នែកហិរញ្ញវត្ថុ និងជំនួយផ្នែកច្បាប់ក៏បានរកឃើញផងដែរ។ ការផ្តល់ជំនួយផ្លូវច្បាប់មិនសូវមាននោះទេ។ ស្នងការនគរបាលខេត្តបានកត់សម្គាល់ថា អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានផ្តល់ជំនួយផ្នែកច្បាប់ដល់ជនរងគ្រោះរស់រានក្តីជីវិត។[74]

ខណៈដែលជនរងគ្រោះរស់រានក្តីជីវិតគឺជាដើមបណ្តឹងក្នុងរឿងក្តីព្រហ្មទណ្ឌនោះ ព្រះរាជអាជ្ញា គឺជាតំណាងរបស់ពួកគេនៅក្នុងតុលាការ។ ហាក់ដូចជានៅមានកង្វះការសម្របសម្រួល រវាងជនរងគ្រោះរស់រានក្តីជីវិតជាមួយនិងមន្ត្រីតុលាការ ដោយសារតែជនរងគ្រោះរស់រានក្តីជីវិត ក្រុមគ្រួសារ និងអាជ្ញាធរមូលដ្ឋានមួយចំនួន

---

[73] ដូចខាងលើ។

[74] បទសម្ភាសន៍ជាមួយ ក្រុមការងារប្រឆាំងការជួញដូរ និងអនីតិជននៃស្នងការនគបាល ខេត្តរតនគីរី នាថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០២០ នៅក្រុងបានលុង ខេត្តរតនគិរី។

បានកត់សម្គាល់ថា ពួកគេមិនបានដឹងថាតើសំណុំរឿងរបស់ពួកគេនៅតុលាការកំពុងតែស្ថិតក្នុងដំណាក់កាលណាមួយ ហើយអ្នកខ្លះបានត្អូញត្អែរអំពីភាពយឺតយ៉ាវនៃរឿងក្តី។ កង្វះចំណេះដឹងអំពីស្ថានភាពដែលកើតឡើងទៅលើពួកគេ រួមជាមួយនឹងកង្វះជំនួយផ្នែកច្បាប់ ជាពិសេស "ការកំរិតការទទួលបានព័ត៌មានពីយន្តការ និងនីតិវិធីក្នុងការស្វែងរកដំណោះស្រាយចំពោះការរំលោភលើសិទ្ធិស្ត្រី និងក្មេងស្រីនៅតាមតំបន់ជនបទ" គឺបង្ហាញពីឧបសគ្គក្នុងការទទួលបាននូវយុត្តិធម៌ ដែលបានកំណត់ដោយគណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ។[75]

ជំនឿសន្មត់ទាក់ទងនិងពូជសាសន៍ក៏ត្រូវបានលើកឡើងដោយមន្ត្រីតុលាការ ដែលគិតថាជនជាតិដើមភាគតិចល្ងង់និងគ្មានចំណេះដឹង និងគ្មានឆន្ទៈក្នុងការគោរពច្បាប់ ដោយសារតែជំនឿប្រពៃណីនិងវប្បធម៌។ ជំនឿសន្មត់នៃការបែងចែកនេះ បង្ហាញពីភាពលំអៀងនិងការរើសអើងប្រឆាំងនឹងជនជាតិដើមភាគតិចដែលបង្ហាញពីការខ្វះការយល់ដឹងអំពីប្រពៃណីនិងវប្បធម៌របស់ជនជាតិដើមភាគតិច។ ការរើសអើងប្រឆាំងនឹងជនជាតិដើមភាគតិច គឺត្រូវបានហាមឃាត់តាមមាត្រា ២ នៃសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច ដែលចែងថា "ជនជាតិដើមភាគតិច និងបុគ្គលដែលជាជនជាតិដើមភាគតិចមានសេរីភាព និងសមភាព ដូចប្រជាពលរដ្ឋ និងបុគ្គលដទៃទៀត ព្រមទាំងមានសិទ្ធិរួចផុតពីការរើសអើងគ្រប់រូបភាពក្នុងការអនុវត្តសិទ្ធិ ជាពិសេសដោយផ្អែកលើមូលហេតុនៃដើមកំណើត ឬអត្តសញ្ញាណរបស់ខ្លួនជាជនជាតិដើមភាគតិច"។ ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏ហាមឃាត់ការរើសអើងនេះដែរ។

## យន្តការដោះស្រាយវិវាទតាមបែបប្រពៃណី

អាជ្ញាធរមូលដ្ឋានអះអាងថា ជួនកាលពួកគេបានប្រើប្រាស់យន្តការដោះស្រាយវិវាទតាមបែបប្រពៃណី។ ពួកគេបានណែនាំជនល្មើសឲ្យឈប់ប្រព្រឹត្តអំពើហិង្សាផ្អែកលើយេនឌ័រ ពីព្រោះទង្វើទាំងនោះមិនបានផ្តល់គំរូល្អសម្រាប់មនុស្សជំនាន់ក្រោយនិងបានណែនាំឲ្យគូភាគីចូលរួមកិច្ចប្រជុំផ្សព្វផ្សាយបង្កើនការយល់ដឹង។ អាជ្ញាធរមូលដ្ឋានមួយរូបបានពោលថាគាត់បានពិន័យប្រាក់ជនល្មើស ហើយបានបញ្ជូនជនល្មើសមួយចំនួនទៅប៉ុស្តិ៍នគរបាលដើម្បីដោះស្រាយរឿងក្តី។ អាជ្ញាធរមូលដ្ឋានខ្លះទៀតបានពន្យល់ថាពួកគេព្យាយាមដោះស្រាយករណីតូចតាចនៅក្នុងសហគមន៍ដោយណែនាំឲ្យធ្វើការបូជាសត្វជ្រូកឬសត្វមាន់។ ប្រសិនបើមានករណីណាមួយដែលមិនអាចដោះស្រាយបាននៅកម្រឹតសហគមន៍នោះ ពួកគេក៏ត្រូវបញ្ជូនទៅប៉ុស្តិ៍នគរបាល អាជ្ញាធរជាន់ខ្ពស់ និងសាលាដំបូងខេត្ត។ អាជ្ញាធរម្នាក់បានពន្យល់ថា មានមួយករណីត្រូវបានដោះស្រាយតាមវិធីសាស្ត្របែបប្រពៃណី (កោះហៅព្រលឹងតាមរយៈការធ្វើពិធីសែនព្រេន) ដោយមានការព្រមព្រៀងពីសំណាកជនរងគ្រោះនៅពេលដែលភាគីគ្មានប្រាក់ក្នុងការបន្តរឿងក្តី។

[75] អនុសាសន៍រួមលេខ ៣៥នៃ CEDAW ស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងស្ត្រី, CEDAW/C/GC/35 កថាខណ្ឌ ១០ (b)។

គួរកត់សម្គាល់ថា គោលការណែនាំស្តីពីការកំណត់ការប្រើប្រាស់នីតិវិធីសម្រុះសម្រួលដើម្បីឆ្លើយតបចំពោះករណីអំពើហិង្សាលើស្ត្រីដែលកំពុងតែស្ថិតនៅក្នុងតំណាក់កាលបង្កើតឡើង និងទទួលខុសត្រូវដោយក្រសួងកិច្ចការនារី តាមរយៈការគាំទ្រជំនួយ បច្ចេកទេសពី UN Women ទីភ្នាក់ងារជំនួយអូស្ត្រាលី និងអង្គការនារីដើម្បីសន្តិភាព។ ខ្លឹមសារដែលមានចែងនៅក្នុងសេចក្តីព្រាងដែលក្រុមស្រាវជ្រាវបានទទួលបញ្ជាក់ថាមានតែករណី បទលហុ និងវិវាទរដ្ឋប្បវេណីប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតិឲ្យប្រើប្រាស់យន្តការសម្រុះសម្រួល ចំពោះករណីទាំងឡាយណាដែលជាប់ពាក់ព័ន្ធនឹងអំពើហិង្សាលើរាងកាយត្រូវតែបញ្ជូនទៅដោះស្រាយនៅតុលាការ។

ចាស់ព្រឹទ្ធាចារ្យត្រូវបានស្នើសុំឱ្យរៀបរាប់អំពីរបៀបនៃដំណើរការដោះស្រាយតាមបែបប្រពៃណី ដែលបានធ្វើឡើងក្នុងករណីជាក់លាក់មួយចំនួន។ ចាស់ព្រឹទ្ធាចារ្យបានរៀបរាប់អំពីដំណើរការស្រដៀងគ្នាដែលពាក់ព័ន្ធនឹងភាគីទាំងពីរ ធ្វើការចរចា ឬការសម្រុះសម្រួល និងសងសំណងសម្រាប់ "ការប្រព្រឹត្តខុស" តាមរយៈការផាកពិន័យបន្តិចបន្តួច ដោយរួមមាន (ទាំងសាច់ប្រាក់ឬជាវត្ថុ) និង /ឬពិធីហៅព្រលឹង ដែលអាចរួមបញ្ចូលទាំងការបូជាសត្វ (សាច់មាន់ ឬជ្រូក) និងជង្ហាយស្រា។

ក្នុងករណីដែលភាគីទាំងពីរគឺជាជនជាតិដើមភាគតិច វិធីសាស្ត្រដែលតែងតែប្រើប្រាស់ជាទូទៅនោះគឺការចរចាររវាងគូភាគី ដើម្បីឈានទៅរកការឯកភាពគ្នាអំពីប្រភេទនៃសំណងនិងចំនួនទឹកប្រាក់ដែលត្រូវសង។ ការដោះស្រាយមិនមែនងាយស្រួលទេដោយសារតែ ត្រូវការពេលវេលាច្រើន អាចមានការលំបាកក្នុងការសម្របសម្រួល និងអាចមានការលំបាកក្នុងការឈានទៅរកការឯកភាពគ្នា ហើយជួនកាលជនល្មើសគ្មានលទ្ធភាពក្នុងការសងសំណងទេ។ ចាស់ទុំម្នាក់បានបញ្ជាក់ថាដំណោះស្រាយប្រភេទនេះ តែងតែមិនត្រូវបានចងក្រងជាឯកសារទេ ប៉ុន្តែជនល្មើស "បានសន្យាឈប់ប្រព្រឹត្តសកម្មភាពបែបនេះទៀតនៅពេលអនាគត។" សំណងអាចមានជា សត្វជ្រូក ស្រាអង្ករ ប្រាក់សម្រាប់ជនរងគ្រោះនិងគ្រួសារ និងពិធីសាសនាដែលសហគមន៍ទាំងមូលចូលរួមបន់ស្រន់ឲ្យស្ថានភាពបានល្អប្រសើរ។

ក្នុងករណីដែលជនល្មើសមិនមែនជាសមាជិកនៅក្នុងសហគមន៍តែមួយ ចាស់ទុំបញ្ជាក់ថាអាជ្ញាធរមូលដ្ឋានបានដើរតួរជាអ្នកសម្រុះសម្រួល ឬត្រូវដាក់ពាក្យបណ្តឹងទៅអាជ្ញាធរមូលដ្ឋាន ពីព្រោះពួកគេមិនបានដឹងអំពីអត្តសញ្ញាណរបស់ជនល្មើស និងមិនដឹងថាត្រូវទៅតាមរកជនល្មើសនៅឯណា។ ចាស់ទុំម្នាក់បានបញ្ជាក់ថាមានការលំបាក់នៅពេលដែលត្រូវប្រើប្រាស់ភាសាផ្សេងគ្នា ក្នុងយន្តការដោះស្រាយវិវាទបែបប្រពៃណី។ ចាស់ទុំម្នាក់ទៀតបញ្ជាក់ថាជួនកាលមានការលំបាកដោយសារតែជនល្មើសមិនព្រមចូលខ្លួនមកដោះស្រាយ និង ផ្តល់សំណង។

ចាស់ព្រឹទ្ធាចារ្យពីររូបមកពីខេត្តរតនគិរីបាននិយាយថា ករណីអំពើហិង្សាក្នុងគ្រួសារ ជាធម្មតាត្រូវបានដោះស្រាយតាមបែបប្រពៃណី ទោះជាយ៉ាងណាចាស់ព្រឹទ្ធាចារ្យម្នាក់ទៀតបានកត់សម្គាល់ថាពួកគេមិនអាច

"ជ្រៀតជ្រែក" នៅក្នុងករណីអំពើហិង្សាក្នុងគ្រួសារបានទេពីព្រោះនេះជា "រឿងកិច្ចការផ្ទៃក្នុងគ្រួសារ" រវាងប្តីប្រពន្ធរបស់គេ។ ចាស់ព្រឹទ្ធាចារ្យម្នាក់បាននិយាយថា គ្រប់ករណីទាំងអស់ត្រូវបានដោះស្រាយតាមនីតិវិធីច្បាប់ផ្លូវការ។ ចាស់ព្រឹទ្ធាចារ្យម្នាក់ផ្សេងទៀតបាននិយាយថាគាត់មិនមានព័ត៌មានទេ។

នៅពេលដែលសាកសួរថា តើជនរងគ្រោះរស់រានជីវិតចូលរួមនៅក្នុងដំណើរការដោះស្រាយបែបប្រពៃណីដោយរបៀបណាចាស់ព្រឹទ្ធាចារ្យម្នាក់បានពោលថា គាត់គ្មានព័ត៌មាននេះទេពីព្រោះករណីទាំងនេះមិនត្រូវបានដោះស្រាយតាមមធ្យោបាយប្រពៃណីទេ។ចាស់ព្រឹទ្ធាចារ្យពីររូបបានបញ្ជាក់ថាជនរងគ្រោះរស់រានជីវិតបានដាក់ពាក្យបណ្តឹងទៅអាជ្ញាធរមូលដ្ឋាន ដូច្នេះមិនមានដំណើរការដោះស្រាយតាមបែបប្រពៃណីទេ។

ក្នុងចំណោមចាស់ព្រឹទ្ធាចារ្យបួននាក់ទៀត ពួកគាត់មានលើកឡើងថាករណីទាំងនេះត្រូវបានដោះស្រាយតាមបែបប្រពៃណី ហើយចាស់ព្រឹទ្ធាចារ្យពីរនាក់បានបញ្ជាក់ថាជនរងគ្រោះរស់រានជីវិតបានចូលរួមក្នុងដំណើរការនេះ។ ចាស់ព្រឹទ្ធាចារ្យម្នាក់បានអះអាងថានៅក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ចាស់ព្រឹទ្ធាចារ្យបានសម្របសម្រួល រវាងប្តីប្រពន្ធ និងផ្តល់ការអប់រំតាមបែបប្រពៃណី។ បន្ទាប់មកជនរងគ្រោះរស់រានជីវិតបានយល់ព្រមទទួលសំណងជាប្រាក់។ ចាស់ព្រឹទ្ធាចារ្យម្នាក់ទៀតបាននិយាយថា ជនរងគ្រោះរស់រានជីវិតបានចូលរួមពិធីនៅក្នុងភូមិ (បូជាសត្វក្របីដើម្បីបួងសួងសុំឲ្យស្ថានភាពល្អប្រសើរសម្រាប់សហគមន៍) និងបានទទួលជំនួយបន្ថែមពីអង្គការមិនមែនរដ្ឋាភិបាល។

ចាស់ព្រឹទ្ធាចារ្យពីរនាក់ទៀតបាននិយាយថា មានមួយករណីដែលជនល្មើសបានបង់ប្រាក់ចំនួន២០០០ដុល្លារ ហើយករណីនេះគឺក្រុមគ្រួសារជនរងគ្រោះ / ជនរងគ្រោះរស់រានជីវិតបានទទួលការអនុញ្ញាតិឲ្យចូលរួមនៅក្នុងដំណើរការសម្រុះសម្រួលដែរ។ ចាស់ព្រឹទ្ធាចារ្យម្នាក់បានបញ្ជាក់ថាពួកគេបានធ្វើការហាមឃាត់បែបប្រពៃណីនិងប្រាប់គូភាគីកុំឲ្យបន្តទំនាក់ ទំនងរាប់អានគ្នាទៀត។ ចាស់ព្រឹទ្ធាចារ្យមកពីស្រុកអូយ៉ាដាវម្នាក់ បញ្ជាក់ថាពួកគេនៅតែមានលទ្ធភាពក្នុងការទាមទារឲ្យជនល្មើសដែលមិនមែនជាជនជាតិដើមភាគតិចបង់សំណង ប៉ុន្តែគេនៅតែបញ្ជូនសំណុំរឿងទៅអាជ្ញាធរមូលដ្ឋានដែរ។ ចាស់ព្រឹទ្ធាចារ្យផ្សេងទៀតបញ្ជាក់ថាពួកគេត្រូវធ្វើពិធីប្រពៃណី ហើយជនល្មើសដែលមិនមែនជាជនជាតិដើមភាគតិចត្រូវផ្តល់សត្វជ្រូកឬសត្វមាន់ និងប្រាក់សម្រាប់ចំណាយរៀបចំពិធី។ ចាស់ព្រឹទ្ធាចារ្យមួយចំនួនត្រូវបានសាកសួរថា តើជនរងគ្រោះរស់រានជីវិត ឬក្រុមគ្រួសារ អាចប្រើប្រាស់ទាំងនីតិវិធីតាមបែបប្រពៃណី និងនីតិវិធីតាមផ្លូវច្បាប់ដើម្បីដោះស្រាយរឿងក្តីបានទេ។ ចាស់ព្រឹទ្ធាចារ្យម្នាក់បានពោលថា គាត់មិនបានដឹងអំពីរឿងនេះទេ។ ចាស់ព្រឹទ្ធាចារ្យពីររូបបានអះអាងថា នៅពេលដែលជនរងគ្រោះរស់រានជីវិតមិនពេញចិត្តនឹងលទ្ធផលនៃដំណើរការដោះស្រាយបែបប្រពៃណី ឬប្រសិនបើគូភាគីមិនយល់ព្រមលើសំណងដែលត្រូវបង់នោះ ជនរងគ្រោះរស់រានជីវិតអាចបន្តដាក់ពាក្យបណ្តឹងទៅតុលាការបាន។

ចាស់ព្រឹទ្ធាចារ្យផ្សេងទៀតបានបង្ហាញថាជនរងគ្រោះរស់រានដ៏ជីវិត ឬគ្រួសារ ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់នីតិវិធីច្បាប់ខ្មែរ ហើយពួកគេបានប្រើប្រាស់នីតិវិធីច្បាប់ខ្មែរទាំងនោះ ជាជាងដំណើរការដោះស្រាយបែបប្រពៃណី។ ក្នុងករណីខ្លះនីតិវិធីច្បាប់មិនត្រូវបានប្រើទេ ពីព្រោះជនល្មើសមិនទាន់រកឃើញនៅឡើយ។ ចាស់ព្រឹទ្ធាចារ្យជនជាតិទំពួនម្នាក់បានពោលថា នៅក្នុងករណីអំពើហិង្សាផ្អែកលើយេនឌ័រមិនអាចដោះស្រាយបែបប្រពៃណីទេ គឺត្រូវបញ្ជូនសំណុំរឿងទៅអាជ្ញាធរមូលដ្ឋាន។

ដូចបានកត់សម្គាល់ខាងលើ ការមិនស៊ីសង្វាក់គ្នារវាងយន្តការដំណោះស្រាយបែបប្រពៃណី និងសិទ្ធិបុគ្គលរបស់ស្ត្រីត្រូវតែដោះស្រាយ។ វិធីសាស្ត្រដោះស្រាយដែលផ្តោតលើអត្ថប្រយោជន៍ជនរងគ្រោះរស់រានដ៏ជីវិតគ្មានភាពស្របគ្នាជាមួយនឹងយន្តការដោះស្រាយបែបប្រពៃណី ដែលផ្តោតសំខាន់ទៅលើអត្ថប្រយោជន៍រួមនៅក្នុងសហគមន៍។ ការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិស្ត្រី និងការយល់ដឹងត្រឹមត្រូវអំពីយេនឌ័រជាពិសេសការដោះស្រាយបទដ្ឋានសង្គមដែលរើសអើង គឺមានភាពចាំបាច់បំផុត។ កិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយអតុល្យភាពនេះ គួរតែត្រូវបានដឹកនាំដោយសហគមន៍ជនជាតិដើមភាគតិចដោយខ្លួនឯងដោយរាប់បញ្ចូល ទាំងក្រុមការងារ CIWWG ដែលមានតួនាទីជាក់លាក់ក្នុងការតស៊ូមតិដើម្បីសិទ្ធិស្ត្រី និងគៀងគរជំនួយផ្នែកច្បាប់ដើម្បីផ្តល់ការគាំទ្រដល់ស្ត្រី។

## ៤.៧. លទ្ធភាពទទួលបាន និងការឆ្លើយតបនៃយន្តការគាំទ្រដើម្បីការពារជនរងគ្រោះរស់រានជីវិត

### សេវាសុខាភិបាល រួមទាំងការប្រឹក្សាយោបល់ផ្នែកចិត្តសង្គម

អាជ្ញាធរមូលដ្ឋានចំនួនពីររូបបានអះអាងថា ពួកគេបានខិតខំខ្នះខ្នែងដើម្បីធានាថាជនរងគ្រោះ / ជនរងគ្រោះរស់រានដ៏ជីវិតបានទទួលការព្យាបាល ឬពិនិត្យកោសល្យវិច្ច័យក្នុងករណីដែលជនរងគ្រោះបានស្លាប់។

ជនរងគ្រោះរស់រានដ៏ជីវិតចំនួន៣នាក់ បានបញ្ជាក់ថាពួកគេមិនបានទទួលការព្យាបាល ឬការពិនិត្យសុខភាពបន្ទាប់ពីហេតុការណ៍បានកើតឡើងទេ។ ជនរងគ្រោះរស់រានដ៏ជីវិតម្នាក់បានពន្យល់ថា ដោយសារតែករណីរបស់គឺជាករណីនៃអំពើប៉ុនប៉ងរំលោភ ដូចនេះនាងមិនត្រូវបានគេពិនិត្យទេ។ បញ្ហានេះបង្ហាញពីភាពខ្វះការយល់ដឹងពីសំណាក់អាជ្ញាធរ និងជនរងគ្រោះរស់រានដ៏ជីវិត អំពីដំណើរការស៊ើបអង្កេត។ ជនរងគ្រោះរស់រាន ដ៏ជីវិតចំនួន៣នាក់ទៀតមិនបានឆ្លើយតបចំពោះសំណួរនេះទេ។ ជនរងគ្រោះរស់រានដ៏ជីវិតចំនួន៤នាក់ផ្សេងទៀតបានអះអាងថា ពួកគេត្រូវបានគេនាំទៅកាន់មន្ទីរពេទ្យដើម្បីទទួលការព្យាបាល និងត្រូវបានគេផ្តល់ជូននូវរបាយការណ៍វេជ្ជសាស្ត្រផងដែរ។

ជនរងគ្រោះរស់រានដ៏ជីវិតចំនួន៥នាក់បានបញ្ជាក់ថា ពួកគេមិនបានទទួលជំនួយណាមួយទេរួមទាំងការប្រឹក្សាយោបល់ ជំនួយផ្នែកវេជ្ជសាស្ត្រ ជំនួយជាសម្ភារៈ ទីជម្រក ឬការអប់រំជាដើម។ ជនរងគ្រោះរស់រាន

ជីវិតម្នាក់ មិនបានឆ្លើយតបនឹងសំណួរនេះទេ។ ជនរងគ្រោះរស់រានគ្គជីវិតម្នាក់ បញ្ជាក់អំពីការបានទទួលការព្យាបាលផ្លូវចិត្តរយៈពេលមួយឆ្នាំដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល និងម្នាក់ទៀតបានពោលថា នាងបានទទួលការគាំទ្រខាងផ្លូវចិត្ត។

សាច់ញាតិជនរងគ្រោះ/ជនរងគ្រោះរស់រានគ្គជីវិតចំនួន៩នាក់ បានបញ្ជាក់ថាការពិនិត្យសុខភាព ឬការធ្វើកោសល្យវិច្ច័យបានធ្វើឡើង។ សាច់ញាតិជនរងគ្រោះម្នាក់បានពន្យល់ថា ការពិនិត្យនេះបានកើតឡើងតាមរយៈជំនួយរបស់អង្គការមិនមែនរដ្ឋាភិបាល។ សាច់ញាតិជនរងគ្រោះចំនួនពីរនាក់ ក្នុងចំណោមសាច់ញាតិប្រាំបួននាក់បានអះអាងថា ពួកគេមិនបានទទួលសំណៅចម្លងនៃការលទ្ធផលពិនិត្យនេះទេ ហើយម្នាក់ទៀតបានពន្យល់ថាព័ត៌មាននេះត្រូវបានបញ្ជូនដោយផ្ទាល់ទៅតុលាការ និងនគបាល។ សាច់ញាតិជនរងគ្រោះចំនួន ៣នាក់បានពោលថា មិនមានការពិនិត្យសុខភាពឬការធ្វើកោសល្យវិច្ច័យទេ ហើយសាច់ញាតិជនរងគ្រោះបីនាក់ផ្សេងទៀតមិនបានឆ្លើយតបសំណួរនេះទេ។ សាច់ញាតិជនរងគ្រោះម្នាក់បានពន្យល់ថា មិនមានការពិនិត្យណាមួយទេ ពីព្រោះវាជាករណីនៃការបៀតបៀនផ្លូវភេទដែលជនល្មើសបានថតរូប ប៉ុន្តែមិនបានប៉ះពាល់លើជនរងគ្រោះរស់រានគ្គជីវិតទេ។

ទាក់ទងនិងការផ្តល់សេវាថែទាំសុខាភិបាលដល់ជនរងគ្រោះរស់រានគ្គជីវិត មន្ត្រីនគបាលបានបញ្ជាក់ថាពួកគេមានទំនួលខុសត្រូវក្នុងការបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ និងបញ្ជូនឲ្យមានសេវាពិនិត្យសុខភាព ប៉ុន្តែពួកគេមិនមានថវិកាសម្រាប់ទ្រទ្រង់ជនរងគ្រោះទេ។ ពួកគេសហការជាមួយមន្ទីរពេទ្យទាំង៦នៅក្នុងខេត្តរតនៈគិរី ដើម្បីឧបត្ថម្ភដល់ជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈ ទាំងអនីតិជននិងមនុស្សពេញវ័យ។ ការពិនិត្យរាងកាយ គឺផ្តល់ឲ្យដោយឥតគិតថ្លៃហើយប្រសិនបើមានរបួសមន្ទីរពេទ្យផ្តល់សេវាព្យាបាលជូន។ មន្ត្រីនគបាល ធ្វើការសម្របសម្រួលជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជួយជនររងគ្រោះរស់រានគ្គជីវិតឲ្យទទួលបានជំនួយផ្នែកសុខាភិបាល។[76] តំណាងមន្ទីរកិច្ចការនារីខេត្តបានអះអាងថានៅពេលដែលមានករណីរាយការណ៍ មកពួកគេ ពួកគេជួយជនរងគ្រោះឲ្យបានទទួលសេវាវេជ្ជសាស្ត្រ។[77]

មន្ត្រីនគបាលបានអះអាងថាមន្ទីរពេទ្យនៅក្នុងខេត្តរតនៈគិរីបានផ្តល់ការប្រឹក្សាយោបល់ និងបានលើកឡើងថាមន្ទីរសង្គមកិច្ចខេត្តមានគំរោងផ្តល់ការប្រឹក្សាយោបល់ជាចម្បងសម្រាប់កុមារ។ ពួកគេក៏បានសម្របសម្រួលជាមួយអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងខេត្ត ដើម្បីជួបជាមួយជនរងគ្រោះរស់រានគ្គជីវិត និងបញ្ជូនពួកគេទៅទទួលការព្យាបាលផងដែរ។[78]

---

[76] បទសម្ភាសន៍ជាមួយ ក្រុមការងារប្រឆាំងការជួញដូរ និងអនីតិជននៃស្នងការប៉ូលីសខេត្តរតនគីរី នាថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០២០ នៅក្រុងបានឡុង ខេត្តរតនគិរី។

[77] បទសម្ភាសន៍ជាមួយតំណាងមកពីមន្ទីរកិច្ចការនារីខេត្តរតនគិរី នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ នៅក្រុងបានលុង ខេត្តរតនគិរី។

[78] បទសម្ភាសន៍ជាមួយ ក្រុមការងារប្រឆាំងការជួញដូរ និងអនីតិជននៃស្នងការប៉ូលីសខេត្តរតនគីរី នាថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០២០ នៅក្រុងបានឡុង ខេត្តរតនគិរី។

មន្ត្រីបុគ្គលិកម្នាក់នៃមន្ទីរកិច្ចការនារីខេត្តបានបញ្ជាក់ថា គាត់បានព្យាយាមផ្តល់ការប្រឹក្សាយោបល់ដល់ជនរងគ្រោះរស់រានមានជីវិត ប៉ុន្តែរូបគាត់ផ្ទាល់មិនដែលបានទទួលការបណ្តុះបណ្តាលជាផ្លូវការណាមួយនៅក្នុងករណីនេះទេ។ មន្ទីរកិច្ចការនារីខេត្តមិនមានអ្នកប្រឹក្សាជំនាញទេ ដូច្នេះគាត់បានទៅជួបជនរងគ្រោះរស់រានជីវិត ដោយផ្ទាល់ដើម្បីពិភាក្សាជាមួយក្រុមគ្រួសារ និងជនរងគ្រោះរស់រានជីវិត និងផ្តល់យោបល់ឲ្យពួកគេផ្លាស់ទី លំនៅនិងបំភ្លេចនូវអ្វីដែលបានកើតឡើង។ គាតបានលើកឧទាហរណ៍ពីក្មេងស្រីអាយុ ៧ ឆ្នាំម្នាក់ដែលត្រូវអ្នកជិតខាងចាប់រំលោភ។ ក្មេងស្រីនោះមានអារម្មណ៍តក់ស្លុត និងស្អប់ឪពុកម្តាយនាងដែលខកខានមិនបានការពារនាង ហើយនាងមិនចង់រស់នៅជាមួយពួកគេទៀតទេ។ នាងបានផ្លាស់លំនៅទៅរស់នៅជាមួយជីដូនជីតារបស់នាង។ ករណីនេះទាមទារឲ្យមានការពិគ្រោះយោបល់ច្រើនពីព្រោះក្មេងមិនចង់ទំនាក់ទំនងជាមួយអ្នកណាទាំងអស់។ គាត់បានបញ្ជាក់ថាឪពុកម្តាយនៅតែមានកាតព្វកិច្ចចំពោះកូន។ មន្ត្រីបុគ្គលិកនៃមន្ទីរកិច្ចការនារីខេត្ត បានទទួលស្គាល់ពីតម្រូវការនៃការគាំទ្រសម្រាប់ការកសាងសមត្ថភាពទាក់ទងនឹងជំនាញប្រឹក្សានិងបច្ចេកទេស។ បច្ចុប្បន្ននេះអង្គការឃែរ (CARE) កំពុងតែធ្វើការនៅក្នុងស្រុកចំនួន៣ប៉ុណ្ណោះ ក្នុងចំណោមស្រុកទាំង៨ ហើយមន្ទីរកិច្ចការនារីចង់ឲ្យមានការពង្រីកទីតាំងគោលដៅរបស់ខ្លួនទៅដល់៦ស្រុកទៀត ដូចដែល អង្គការផ្លេន (PLAN) កំពុងតែធ្វើ ដែរ។[79]

អង្គការផ្លេន (PLAN) មានសកម្មភាពខ្លាំងនៅក្នុងខេត្តរតនៈគិរី ជុំវិញបញ្ហាអាពាហ៍ពិពាហ៍កុមារ និងអំពើហិង្សាផ្អែកលើយេនឌ័រ។ ពួកគេផ្តល់នូវសេវាកម្ម និងជំនួយ ដូចជាជំនួយផ្នែកវេជ្ជសាស្ត្រ និងការប្រឹក្សាផ្នែកចិត្តសាស្ត្រ។ ពួកគេក៏កំពុងបង្កើតបុគ្គលិកសង្គមកិច្ចសហគមន៍ ដោយមានជំនួយពីសេវាកម្មសង្គមកម្ពុជាដែលនឹងផ្តល់ការប្រឹក្សាផងដែរ។ ពួកគេបានបង្កើតសេវាកម្មសុខភាពជាពិសេសសម្រាប់កុមារ ដូច្នេះពួកគេអាចពិភាក្សាជាមួយអ្នកផ្តល់សេវាសុខភាពជាលក្ខណៈឯកជនអំពីបញ្ហាសុខភាព (ឧទាហរណ៍ការពារការឆ្លងជំងឺកាមរោគ)។[80] ខណៈអាជ្ញាធរមូលដ្ឋានបានបញ្ជាក់ថា ជនរងគ្រោះរស់រានជីវិត និងគ្រួសារមួយចំនួនបានរាយការណ៍ថា ពួកគេអាចទទួលបានជំនួយផ្នែកសុខាភិបាលបន្ទាប់ពីការរំលោភសេពសន្ថវៈនោះជនរងគ្រោះរស់រានជីវិតមួយចំនួនទៀតបានរាយការណ៍ថាពួកគេមិនបានទទួលជំនួយផ្នែកសុខាភិបាលទេ។ ជនរងគ្រោះរស់រានជីវិតមួយចំនួនបានបញ្ជាក់ថា នៅពេលដែលពួកគេឆ្លងកាត់ការពិនិត្យសុខភាពពួកគេមិនត្រូវបានផ្តល់នូវច្បាប់ចម្លងនៃរបាយការណ៍វេជ្ជសាស្ត្រទេ ផ្ទុយទៅវិញឯកសារទាំងនោះត្រូវបានផ្តល់ដោយផ្ទាល់ទៅឲ្យអាជ្ញាធរ ឬអ្នកអនុវត្តច្បាប់។ ដូចគ្នាដែរសេវាប្រឹក្សាយោបល់ផ្នែកចិត្តសង្គមក៏មិនងាយរកបានដែរ។ អាជ្ញាធរហាក់ពឹងផ្អែកទៅលើ អង្គការសង្គមស៊ីវិលក្នុងការផ្តល់សេវាទាំងនេះ។ ជនរងគ្រោះរស់រានជីវិតនិងក្រុមគ្រួសារខ្លះ បានកត់សម្គាល់ថាពួកគេមិនបានទទួលការប្រឹក្សាយោបល់ ឬជំនួយណាមួយពីរបួសស្នាមនោះទេ។ មន្ត្រីបុគ្គលិកមន្ទីរកិច្ចការនារីខេត្តបានបញ្ជាក់ថា ពួកគេជាអ្នកផ្តល់ការប្រឹក្សាដោយខ្លួន

[79] បទសម្ភាសន៍ជាមួយតំណាងមកពីមន្ទីរកិច្ចការនារីខេត្តរតនគិរី នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ នៅក្រុងបានលុង ខេត្តរតនគិរី។

[80] បទសម្ភាសន៍ជាមួយគណៈគ្រប់គ្រងនៃអង្គការអន្តរជាតិ PLANប្រចាំនៅកម្ពុជា ថ្ងៃទី១៣ តុលា ឆ្នាំ២០២០ ក្នុងរាជធានីភ្នំពេញ ប្រទេសកម្ពុជា។

ឯងទោះបីជាមិនបានទទួលការបណ្តុះបណ្តាលជាផ្លូវការផ្នែកចិត្តសាស្ត្រ និងការដោះស្រាយជាមួយនឹងការប៉ះទង្គិចផ្លូវចិត្តក៏ដោយ។

ការធ្វើឲ្យប្រសើរឡើងនូវសេវាកម្មសុខាភិបាល និងចិត្តសាស្ត្រ គឺជាការចាំបាច់ ដើម្បីអនុវត្តតាមអនុសាសន៍របស់អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនិងស្ត្រីភេទ (CEDAW) កតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ និងមាត្រា២៤ (កឋាខ័ណ្ឌទី២) នៃសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិចដែលបានចែងថា "ជនជាតិដើមភាគតិចគ្រប់រូប មានសិទ្ធិស្មើគ្នាចំពោះបទដ្ឋានសុខភាពខាងរាងកាយ និងផ្លូវចិត្តកំរិតខ្ពស់បំផុត។ រដ្ឋត្រូវចាត់វិធានការចាំបាច់ក្នុងគោលបំណងសម្រេចឲ្យបាននូវការអនុវត្តដោពេញលេញនូវសិទ្ធិទាំងនេះ"។[81]

## ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងសម្ភារៈ

ជនរងគ្រោះរស់រានជីវិតមួយចំនួនបានរាយការណ៍ថាពួកគេបានទទួលជំនួយ ការលើកទឹកចិត្តពីសហគមន៍មានដូចជា កន្ទេល ភួយ មុង សម្លៀកបំពាក់ ស្បៀងអាហារ និងថវិកាមួយចំនួន។

ជីតាជនរងគ្រោះរស់រានជីវិតម្នាក់បានពោលថាគាត់មិនបានទទួលជំនួយទេ ចំណោកបុរសដែលជាសាច់ញាតិ ជនរងគ្រោះរស់រានជីវិតផ្សេងទៀតបាននិយាយថាគ្មានស្ថាប័នណាមកជួយពួកគេទេ។ លោកបន្ថែមទៀតថា មានតម្រូវការជំនួយសម្រាប់ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស ដល់ជនរងគ្រោះរស់រានជីវិត។ ម្តាយរបស់ជនរងគ្រោះរស់រានជីវិតម្នាក់មិនបានឆ្លើយសំណួរទេ។

សាច់ញាតិជនរងគ្រោះផ្សេងទៀតបានពោលថា ជនរងគ្រោះរស់រានជីវិតបានទទួលជំនួយពីអង្គការមិនមែនរដ្ឋាភិបាល ជំនួយជាលក្ខណៈឯកជន និងសហគមន៍។ អង្គការមិនមែនរដ្ឋាភិបាលបានផ្តល់នូវអាហារ របស់របរមួយចំនួន (ដូចជាកន្ទេល គ្រឿងទេស និងប្រដាប់ប្រដាក្មេងលេង) និងថវិកាមួយចំនួនតូចផងដែរ។ ម្ចាស់ជំនួយជាលក្ខណៈឯកជនមួយចំនួន បានបរិច្ចាគប្រាក់ក្នុងបរិមាណផ្សេងៗគ្នា។ ចុងក្រោយសហគមន៍បាន ផ្តល់ការគាំទ្រលើកទឹកចិត្តមួយចំនួន។ សាច់ញាតិជនរងគ្រោះបានកត់សម្គាល់ថាការគាំទ្រត្រូវបានស្វាគមន៍ ប៉ុន្តែត្រូវការជាចាំបាច់បន្ថែមទៀត ដូចជាក្នុងករណីមួយ ដែលគ្រួសារកុមាររងគ្រោះរស់រានជីវិតមិនមានប្រាក់ដើម្បីបញ្ជូននាងទៅសាលារៀនទេ។ ក្នុងករណីមួយផ្សេងទៀត ជនរងគ្រោះរស់រានជីវិតមានផ្ទៃពោះ ដោយសារទេអំពើរំលោភសេពសន្ថវៈ ហើយត្រូវការការគាំទ្រផ្នែកហិរញ្ញវត្ថុ និងសង្គម។

ក្នុងករណីដែលរដ្ឋខកខានមិនបានផ្តល់ជំនួយគាំទ្រ អង្គការមិនមែនរដ្ឋាភិបាលបានទទួលខុសត្រូវក្នុងការ

---

[81] អនុសាសន៍រួមលេខ ៣៥នៃ CEDAW ស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រលើស្ត្រី, CEDAW/C/GC/35 កថាខណ្ឌ ៤៦។

ជួយជនរងគ្រោះ។ ស្នងការនគរបាលខេត្ត មន្ទីរកិច្ចការនារីខេត្ត អាជ្ញាធរមូលដ្ឋាន ជនរងគ្រោះរស់រានជីវិត និងក្រុមគ្រួសារ បានលើកឡើងដូចគ្នាថា អង្គការមិនមែនរដ្ឋាភិបាលបានផ្តល់ទាំងជំនួយមនុស្សធម៌ និងការប្រឹក្សាយោបល់ដល់ជនរងគ្រោះ។ ភ្នាក់ងាររដ្ឋាភិបាលជាច្រើន (ថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន) បានធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលដើម្បីផ្តល់ការគាំទ្រដល់ជនរងគ្រោះរស់រានជីវិត ។

មន្ត្រីនគបាលបានរាយការណ៍ពីផលលំបាកក្នុងការសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងមន្ទីរសង្គមកិច្ច ស្តីពីជំនួយផ្នែកសម្ភារៈ។ ខាងនគបាលធ្វើការបន្ថែមលើនីតិវិធីច្បាប់ ខណៈដែលមន្ទីរកិច្ចការនារីផ្តល់ការបណ្តុះ បណ្តាលជំនាញដល់ជនរងគ្រោះរស់រានជីវិតដើម្បីជួយពួកគេក្នុងការរកប្រាក់ចិញ្ចឹមជីវិត។ មន្ត្រីនគបាលបានបន្ថែមថា ទោះបីជាក្រុមខ្លួនបានផ្តល់នូវឱកាសដល់ជនរងគ្រោះរស់រានជីវិត ដើម្បីចាកចេញពីសហគមន៍ និងទទួលបាននូវការបណ្តុះបណ្តាល (សម្រាប់ជំនាញផ្សេងៗ និងជីវភាពរស់នៅ) ឪពុកម្តាយរបស់ជនរងគ្រោះរស់រានជីវិតតែងតែមិនអនុញ្ញាត។[82]

ជំនួយគាំទ្របន្ទាន់ភ្លាមៗត្រូវបានផ្តល់ជូនដល់ជនរងគ្រោះរស់រានជីវិតភាគច្រើនមានដូចជា៖ ម្ហូបអាហារ ថវិកាបន្តិចបន្តួច និងការបណ្តុះបណ្តាលជំនាញនានា។ ការគាំទ្រគួរតែពិចារណាលើតម្រូវការសម្រាប់រយៈពេលវែងរបស់ជនរងគ្រោះរស់រានជីវិត ដូចជាការប្រឹក្សាយោបល់ផ្លូវចិត្ត។ អាជ្ញាធរខេត្ត និងអង្គការមិនមែនរដ្ឋាភិបាលបានកត់សម្គាល់ថាជាទូទៅស្ត្រីពឹងផ្អែកផ្នែកហិរញ្ញវត្ថុលើស្វាមី ដូច្នេះពួកគេមានការស្ទាក់ស្ទើរក្នុងការដាក់ពាក្យបណ្តឹងដោយខ្លាចថាគ្រួសាររបស់ពួកគេនឹងបាត់បង់ប្រាក់ចំណូល។ តម្រូវការនៃប្រាក់ចំណូលបន្ថែមតាមរយៈពលកម្មបន្ថែម ត្រូវបានគេកំណត់ថាជាហេតុផលសម្រាប់អាពាហ៍ពិពាហ៍កុមារ។ ការគាំទ្រជីវភាពរស់នៅឲ្យកាន់តែច្រើនសម្រាប់ស្ត្រី គឺជាត្រូវតម្រូវការចាំបាច់ដើម្បីជួយពួកគេទទួលបាននូវសុវត្ថិភាពផ្នែកហិរញ្ញវត្ថុ និងមិនចាំបាច់ពឹងផ្អែកលើមនុស្សដែលបានរំលោភបំពានលើពួកគេ។ ទោះយ៉ាងណាការយល់ដឹងកាន់តែច្បាស់អំពីវប្បធម៌ជនជាតិដើមភាគតិច និងសក្តានុពលគ្រួសារនៅក្នុងវប្បធម៌មួយ គឺជាការចាំបាច់ដើម្បីរៀបចំឲ្យបានសមរម្យ និងការគាំទ្ររយៈពេលវែងដែលទទួលបាន ជាពិសេសជំនាញ និងការបណ្តុះបណ្តាលលើផ្នែកជីវភាព។

## ៤.៨. កិច្ចខិតខំប្រឹងប្រែងការពារ និងកត្តារាំងដល់កិច្ចខិតខំប្រឹងប្រែងទាំងនេះ

កិច្ចខិតខំប្រឹងប្រែងដើម្បីទប់ស្កាត់អំពើហិង្សាផ្អែកលើយេនឌ័រជាច្រើន មានភ្ជាប់នូវជំនឿសន្មត់ដែលរើសអើងយេនឌ័រ និងហាក់ដាក់បន្ទុក និងស្តីបន្ទោសទៅលើជនរងគ្រោះ /ជនរងគ្រោះរស់រានជីវិត ជាជាងដាក់បន្ទុកទៅលើជនល្មើស។ ជំនួសឲ្យការទាមទារឲ្យជនល្មើសទទួលខុសត្រូវសកម្មភាពឧក្រិដ្ឋរបស់ពួកគេ ឬទាមទារឲ្យមានការអនុវត្តច្បាប់ដែលមានប្រសិទ្ធភាពជាងមុន មនុស្សជាច្រើនបានជ្រើសរើសវិធីសាស្ត្រ

82 បទសម្ភាសន៍ជាមួយ ក្រុមការងារប្រឆាំងការជួញដូរ និងអនីតិជននៃស្នងការប៉ូលីសខេត្តរតនគីរី នាថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០២០ នៅក្រុងបានលុង ខេត្តរតនគិរី។

បែបការពារនិយមដើម្បីដោះស្រាយស្ថានការណ៍។ ការប្រើប្រាស់វិធីសាស្ត្របែបនេះបង្កប់នូវការរើសអើងដោយប្រយោលប្រឆាំងនឹងស្ត្រីនិងក្មេងស្រី ដោយសារតែការដាក់រឹតត្បឹតទៅលើស្វ័យភាព និងសេរីភាពក្នុងការដើរហើរ របស់ស្ត្រីនិងក្មេងស្រី និងដាក់ការទទួលខុសត្រូវក្នុងការទប់ស្កាត់អំពើរំលោភសេពសន្ថវៈ និងទម្រង់ដទៃទៀតនៃអំពើហិង្សាផ្អែកលើយេនឌ័រ ធ្វើឲ្យវប្បធម៌ស្តីបន្ទោសជនរងគ្រោះនៅក្នុងសហគមន៍នៅតែបន្តកើតឡើង។ សង្គមកម្ពុជាគឺជាសង្គមបិតាធិបតេយ្យ ដែលបានបញ្ជ្រាបប្រពៃណីវប្បធម៌ទៅក្នុងបទដ្ឋានសង្គមដែលកំណត់អំពីតួនាទីរបស់ស្ត្រី ដូចបង្ហាញនៅក្នុង "ច្បាប់ស្រី"។ អាចមានការពិបាកក្នុងការពន្យល់ពីផលប៉ះពាល់អវិជ្ជមានដែលកើតឡើងដោយសារតែការប្រសព្វរវាងវប្បធម៌ និងបទដ្ឋានសង្គមដែលមានចរឹករើសអើង និងផ្តល់បុព្វសិទ្ធិដល់ក្រុមបុរស។ ផ្នត់គំនិតបិតាធិបតេយ្យតែងតែចាត់ទុកស្ត្រីថាមានឋានៈទាបជាបុរស។ ភាពក្រីក្រ ក៏អាចបង្កឲ្យមានអតុល្យភាពនៃទំនាក់ទំនងអំណាចដែលនាំឲ្យមានអំពើហិង្សាប្រឆាំងស្ត្រី និងក្មេងស្រីកើតឡើងផងដែរ។ លុះត្រាតែភាគីពាក់ព័ន្ធទាំងអស់មានការយល់ដឹងច្បាស់លាស់អំពីរចនាសម្ព័នឫសគល់នៃបញ្ហានេះ និងរួមគ្នាផ្លាស់ប្តូរបទដ្ឋានសង្គមនិងជំនឿសន្មត់ដែលរើសអើងយេនឌ័រទើបវិធានការទប់ស្កាត់ករណីអំពើហិង្សាផ្អែកលើយេនឌ័រមានប្រសិទ្ធិភាព។

អាជ្ញាធរមូលដ្ឋានចំនួន១២នាក់ បានផ្តល់យោបល់អំពីការលើកកម្ពស់ការយល់ដឹង/ការអប់រំសហគមន៏។ អាជ្ញាធរមួយចំនួនបានពោលថា ការបណ្តុះបណ្តាលគួរតែត្រូវបានផ្តល់ជូនដោយតំណាងមន្ទីរកិច្ចការនារីខេត្ត និងនគបាល ឬអង្គការមិនមែនរដ្ឋាភិបាល។ ការលើកកម្ពស់ការយល់ដឹងគួរតែផ្តោតលើ៖ ច្បាប់ពាក់ព័ន្ធប្រឆាំងនឹងអំពើហិង្សាផ្អែកលើយេនឌ័រ ច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរផ្លូវភេទ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ និងច្បាប់ស្តីពីការបង្ក្រាបនិងទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹង។ អាជ្ញាធរមូលដ្ឋានម្នាក់បានពោលថា ប្រជាពលរដ្ឋគួរតែត្រូវបានអប់រំកុំឲ្យធ្វើដូចជនល្មើស។ អាជ្ញាធរចំនួន ៥នាក់ បានណែនាំថាស្ត្រីគួរតែដំណឹងដល់ក្រុមគ្រួសារ នៅពេលដែលពួកគេធ្វើដំណើរទៅក្រៅផ្ទះ និងមិនត្រូវធ្វើដំណើរតែម្នាក់ឯង។ អាជ្ញាធរមូលដ្ឋានចំនួន២នាក់បញ្ជាក់ថា ស្ត្រីគួរតែត្រូវបានអប់រំកុំឲ្យទុកចិត្តលើជនចម្លែកមុខ។ អាជ្ញាធរចំនួន៤នាក់បាននិយាយថា អ្នកភូមិត្រូវតែរាយការណ៍អំពីអំពើហិង្សាផ្អែកលើយេនឌ័រទៅអាជ្ញាធរមូលដ្ឋាន។ អាជ្ញាធរចំនួន ២នាក់ផ្សេងទៀតបានបន្ថែមថា អ្នកភូមិគួរតែសហការជាមួយអាជ្ញាធរ។ ការផ្តល់យោបល់ផ្សេងទៀតគឺ៖ ស្ត្រីគួរតែចូលរួមនៅពេលមានការប្រជុំឃុំសង្កាត់ និងគួរតែមានការចាប់ខ្លួនជនល្មើស ជនជាតិដើមភាគតិចខ្លួនឯងគួរតែមានការប្រមូលផ្តុំដើម្បីឲ្យកាន់តែមានសាមគ្គីភាព និងអាចជួយគ្នាទៅវិញទៅមក និងគួរតែមានការបង្កើតក្រុមយុវជន និងការផ្តល់ប្រឹក្សាយោបល់ឲ្យបានត្រឹមត្រូវគួរផ្តល់ឲ្យជនរងគ្រោះរស់រានជីវិត និងការអប់រំផ្អែកតាមធម៌វិន័យបែបព្រះពុទ្ធសាសនា ដែលហាមឃាត់អំពើរំលោភសេពសន្ថវៈគួរតែត្រូវបានអនុវត្ត។[83] មានអាជ្ញាធរមូលដ្ឋានតែ

[83] សិក្ខាបទទាំង៥នៅក្នុងព្រះពុទ្ធសាសនាដែលមានគុណតម្លៃ និងមានសារៈសំខាន់ស្មើគ្នាគឺ៖
១-វៀរចាកការសម្លាប់ជីវិតសត្វដទៃ/បដិបត្តមេត្តា
២-វៀរចាកការប្រកាន់យកទ្រព្យសម្បត្តិរបស់អ្នកដទៃ/បដិបត្តករុណា

ម្នាក់ប៉ុណ្ណោះដែលមិនបានឆ្លើយតបសំណួរនេះ។

មតិយោបល់ដែលផ្ដល់ដោយជនរងគ្រោះរស់រានគ្គជីវិត គឺផ្ដោតជាទូទៅលើ វិធីសាស្ត្រទប់ស្កាត់អំពើហិង្សាផ្អែកលើយេនឌ័រ ដូចជាការកែប្រែអាកប្បកិរិយារបស់ស្ត្រីតាមរយៈការមិនធ្វើដំណើរតែឯងតាមផ្លូវស្ងាត់ ត្រូវមានការប្រុងប្រយ័ត្ន និងមិនត្រូវទុកចិត្តបុរស រួមទាំងដៃគូស្និទ្ធស្នាល ឬឪពុកចុង និងត្រូវប្រយ័ត្ននិងចាក់សោរទ្វារផ្ទះ។ ចាស់ទុំព្រឹទ្ធាចារ្យ និងអាជ្ញាធរត្រូវតែអប់រំស្ត្រី និងយុវជនអំពីឧក្រិដ្ឋកម្មទាំងនេះ និងវិធីសាស្ត្រការពារខ្លួន និងកិច្ចការការពារផ្សេងៗ។ ចាស់ទុំព្រឹទ្ធាចារ្យគួរលើកទឹកចិត្តក្មេងស្រីឲ្យស្តាប់ឪពុកម្តាយ។ អ្នកភូមិគួរការពារកូនៗនិងមិនគួរអនុញ្ញាតឲ្យពួកគេធ្វើដំណើរឆ្ងាយ។ ជនរងគ្រោះរស់រានគ្គជីវិតចំនួន៣នាក់ មិនបានផ្តល់យោបល់អ្វីទេ។ ជនរងគ្រោះរស់រានគ្គជីវិតចំនួន៤នាក់គ្មានដំបូន្មានអ្វីដើម្បីចែករំលែកជាមួយជនរងគ្រោះរស់ រានគ្គជីវិតពីអំពើហិង្សាផ្អែកលើយេនឌ័រផ្សេងទៀតទេ។ ជនរងគ្រោះរស់រានគ្គជីវិតចំនួន២នាក់បាន ពោលថា ស្ត្រីមិនគួរធ្វើដំណើរតែម្នាក់ឯងតាមផ្លូវស្ងាត់។ ជនរងគ្រោះរស់រានគ្គជីវិតចំនួន៣នាក់ បាននិយាយថា មិនគួរទុកចិត្តមនុស្សចម្លែក ឬមនុស្សទូទៅ។ ជនរងគ្រោះរស់រានគ្គជីវិតផ្សេងទៀតបានលើកទឹកចិត្តជនរងគ្រោះរស់រានគ្គជីវិតទាំងអស់ឲ្យរឹងមាំ និងបំភ្លេចចោលនូវអតីតកាល និងគិតតែរឿងល្អៗ និងបន្តការរៀនសូត្រ ដើម្បីជៀសវាងការប្រមាថមាក់ងាយនាពេលអនាគត។

គ្រួសារជនរងគ្រោះរស់រានគ្គជីវិត បានផ្តល់ដំបូន្មានសម្រាប់ជនរងគ្រោះរស់រានគ្គជីវិតផ្សេងទៀត និងគ្រួសារ។ ផ្តោតរួមលើ អាកប្បកិរិយារបស់ស្ត្រី ដូចជាមិនត្រូវទុកចិត្តមនុស្ស ត្រូវស្វែងយល់ពីវិធីការពារខ្លួន និងបង្រៀន កូនៗកុំឲ្យចេញទៅក្រៅតែម្នាក់ឯង និងលើកទឹកចិត្តឲ្យមានភាពរឹងមាំ កុំខ្មាស់អៀន ឬកើតទុក្ខ និងបន្តការរៀនសូត្រ។ សាច់ញាតិជនរងគ្រោះចំនួន ៤នាក់មិនបានផ្តល់ចម្លើយទេ។

មាត្រា២២ (២) នៃសេចក្តីប្រកាសស្តីពីសិទ្ធិជនជាតិដើមភាគតិចរបស់អង្គការសហប្រជាជាតិ បានចែងថា រដ្ឋភាគីត្រូវចាត់វិធានការដោយសហការជាមួយជនជាតិដើមភាគតិច ដើម្បីធានាថា ស្ត្រីនិងកុមារជនជាតិដើមភាគតិច ទទួលបានការការពារនិងការធានាបានទាំងស្រុងប្រឆាំងនឹងអំពើហិង្សានិងការរើសអើងគ្រប់រូបភាព។ នៅក្នុងវិសាលភាពជាក់លាក់មួយ បទប្បញ្ញត្តិនេះគួរតែត្រូវបានយកមកអនុវត្តនៅក្នុងខេត្តរតនៈគិរី។ ឧទាហរណ៍ស្នងការនគរបាលខេត្តរតនគិរីបានលើកឡើងថា ថ្នាក់ដឹកនាំខេត្តកំពុងយកចិត្តទុកដាក់លើការលើកកម្ពស់ចំណេះដឹងផ្នែកច្បាប់ ជាពិសេសក្នុងចំណោមសហគមន៍ជនជាតិដើមភាគតិចឲ្យពួក

---

៣-វៀរចាកការរួមប្រវេណីគឺប្រព្រឹត្តផ្លូវភេទជាមួយប្រពន្ធកូនរបស់ជនដទៃ/បដិបត្តមុទិតា

៤-វៀរចាកការនិយាយពាក្យមិនពិត/បដិបត្តឧបេក្ខា

៥- វៀរចាកការផឹកទឹកស្រវឹង ដែលជាហេតុឲ្យកើតសេចក្តីប្រមាទផ្សេងៗ។/បដិបត្តការចម្រើនសតិ

គួរកត់សម្គាល់ថា សហគមន៍ជនជាតិដើមភាគតិចភាគច្រើនមានសាសនាដើមរបស់ពួកគេ ដែលមិនមែនជាព្រះពុទ្ធសាសនាទេ។ មើលរបាយការណ៍ “ ទឹក និងប្រេង? ការសិក្សាអំពីទ្រឹស្តីស្ត្រីនិយម និងពុទ្ធសាសនាក្នុងប្រទេសកម្ពុជា” របស់អង្គការភ្លាហាន ខែធ្នូ ឆ្នាំ២០២០ នៅទំព័រ ៣៧។

គាត់ដឹងថាអំពើរំលោភសេពសន្ថវៈ គឺជាបទឧក្រិដ្ឋ ហើយគួរតែត្រូវបានផ្តន្ទាទោស។[84]

តំណាងការិយាល័យប្រឆាំងការជួញដូរមនុស្សនិងកិច្ចការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តរតនគិរីបានបញ្ជាក់ថាចាប់ពីឆ្នាំ២០១៩ នគបាលបានបង្កើនវត្តមានរបស់ខ្លួននៅតាមភូមិ។ កាលពីមុនចម្ងាយទីតាំងភូមិសាស្ត្រ បង្កការលំបាកដល់នគបាលក្នុងការដោះស្រាយករណីអំពើហិង្សាផ្អែកលើយេនឌ័រ។ ពួកគេមិនបានទទួលព័ត៌មានទាន់ពេល ដោយសារតែសហគមន៍ជនជាតិដើមភាគតិចរស់នៅក្នុងតំបន់ឆ្ងាយ និងដាច់ស្រយាល និងមិនអាចផ្តល់សេចក្តីរាយការណ៍ពីករណីដែលបានកើតឡើង។ ពេលនេះនគបាលប្រចាំនៅថ្នាក់ភូមិអាចទទួលបានព័ត៌មាន និងពិនិត្យមើលករណីទាំងនេះ។ កាលពីមុននៅពេលអំពើរំលោភសេពសន្ថវៈកើតឡើង សហគមន៍ជនជាតិដើមភាគតិចបានប្រើវិធីដោះស្រាយបែបប្រពៃណីការដោយបង្ខំឲ្យរៀបការនិងសងជាសំណងដើម្បីដោះស្រាយបទឧក្រិដ្ឋនេះ។ បច្ចុប្បន្ននេះសហគមន៍ជនជាតិដើមភាគតិចបានចាប់ផ្តើមរាយការណ៍ករណីទាំងនេះទៅអាជ្ញាធរ ហើយជនរងគ្រោះរស់រានជីវិតកំពុងទទួលបានជំនួយ។[85]

បច្ចុប្បន្ននេះ បណ្តាញទូរស័ព្ទទាន់ហេតុការណ៍សម្រាប់ប្រជាពលរដ្ឋរាយការណ៍អំពីករណីអំពើហិង្សាផ្អែកលើយេនឌ័រមានពីរកម្រិត៖ ថ្នាក់ខេត្ត និងស្រុកដែលដឹកនាំដោយអធិការនគរបាលស្រុក។ ប្រជាពលរដ្ឋកាន់តែច្រើនបានកំពុងនឹងប្រើប្រាស់បណ្តាញទូរស័ព្ទទាន់ហេតុការណ៍ នេះបើប្រៀបធៀបទៅនឹងយន្តការដាក់ពាក្យបណ្តឹងអនាមិកនៅក្នុងប្រអប់សំបុត្រ។ ក្រុមការងារប្រឆាំងការជួញដូរមនុស្ស និងអនីតិជន មាន ៤ក្រុមតូចៗ ដែលប្រចាំការ និងបានឆ្លាស់វេនគ្នាដើម្បីគ្រប់គ្រងបណ្តាញទូរស័ព្ទទាន់ហេតុការណ៍នេះ។ អធិការរងនគរបាលស្រុកចំនួន២នាក់ ត្រូវត្រៀមកម្លាំងដើម្បីអន្តរាគមន៍ភ្លាមៗបន្ទាប់ពីទទួលបានការរាយការណ៍តាមទូរស័ព្ទ។[86] ខណៈដែលវត្តមានបណ្តាញទូរស័ព្ទទាន់ហេតុការណ៍កំពុងត្រូវបានលើកទឹកចិត្ត អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយបានកត់សម្គាល់ថាបណ្តាញទូរស័ព្ទទាន់ហេតុការណ៍នេះ មិនទាន់ដាក់បញ្ចូលភាសាជនជាតិដើមភាគតិចនៅឡើយទេ ហើយចាំបាច់ត្រូវដាក់បញ្ចូលដើម្បីសម្រួលឲ្យសហគមន៍ជនជាតិដើមភាគតិចអាចចូលរួមរាយការណ៍បាន។

បុគ្គលិកមន្ទីរកិច្ចការនារីខេត្តបានអះអាងថា បណ្តាញយេនឌ័រថ្នាក់ខេត្តត្រូវបានបង្កើតឡើងនៅខេត្តរតនៈគិរី សមាសភាពក្នុងនោះមានតំណាងមន្ទីរពាក់ព័ន្ធនិងអង្គការមិនមែនរដ្ឋាភិបាល ដែលបានជួបប្រជុំគ្នាបីដងក្នុងមួយឆ្នាំដើម្បីពិភាក្សាអំពីបញ្ហាយេនឌ័រ។ នៅក្នុងកិច្ចប្រជុំនេះ ពួកគេចែករំលែកព័ត៌មានអំពីការងាររបស់ពួកគេនិងពិភាក្សាអំពីតំបន់ដែលអាចពង្រឹងកិច្ចសហការបាន។ បុគ្គលិកមន្ទីរកិច្ចការនារីខេត្តបានកត់

[84] បទសម្ភាសន៍ជាមួយ ក្រុមការងារប្រឆាំងការជួញដូរ និងអនីតិជននៃស្នងការប៉ូលីសខេត្តរតនគីរី នាថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០២០ នៅក្រុងបានឡុង ខេត្តរតនគិរី។

[85] ដូចខាងលើ។

[86] ដូចខាងលើ។

សម្គាល់ថាខណៈដែលពួកគេបានដឹងអំពីការបណ្តុះបណ្តាលស្តីពីអំពើរំលោភសេពសន្ថវៈ ដែលធ្វើឡើងដោយមន្ត្រីនគបាលសម្រាប់សហគមន៍ជនជាតិដើមភាគតិច ពួកគេមិនបានចូលរួមនៅក្នុងការបណ្តុះបណ្តាលក្នុងនាមជាគ្រូបង្វឹក ឬអ្នកសម្របសម្រួលឡើយ។ ពួកគេក៏បានកត់សម្គាល់អំពីតួលេខខុសគ្នានៃអំពើហិង្សាផ្អែកលើយេនឌ័រ ដោយសារតែនគបាលពឹងផ្អែកលើតែចំនួនមនុស្សដែលធ្វើរបាយការណ៍ចំណែកមន្ទីរកិច្ចការនារីខេត្តគឺបានធ្វើការដោយផ្ទាល់ជាមួយសហគមន៍ និងបានព័ត៌មានពីសហគមន៍ផ្ទាល់។[87]

នៅក្នុងខេត្តរតនគិរី ការសម្របសម្រួលនិងសហការរវាងភ្នាក់ងាររដ្ឋាភិបាលដែលទទួលខុសត្រូវក្នុងការដោះស្រាយអំពើហិង្សាផ្អែកលើយេនឌ័រគួរតែមានការកែលម្អបន្ថែមទៀត។ ភ្នាក់ងាររដ្ឋាភិបាលមួយបានលើកឡើងពីការលំបាកក្នុងការសហការជាមួយស្ថាប័នមួយផ្សេងទៀត និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីទទួលបានជំនួយជាសម្ភារៈសម្រាប់ជនរងគ្រោះរស់រានជីវិត។ ការបណ្តុះបណ្តាលអំពីអំពើហិង្សាផ្អែកលើយេនឌ័រ សម្រាប់សហគមន៍ជនជាតិដើមភាគតិច បានធ្វើឡើងដោយមន្ត្រីនគបាលតែប៉ុណ្ណោះ និងគ្មានការចូលរួមពីតំណាងមន្ទីរកិច្ចការនារីខេត្តឡើយ។ បន្ថែមលើនេះនៅមិនទាន់មានការបង្កើតយន្តការប្រមូល និងរក្សាទិន្នន័យអំពើហិង្សាផ្អែកលើយេនឌ័ររួមមួយទេ ការណ៍នេះបណ្តាលឲ្យមានស្ថិតិខុសគ្នារវាងភ្នាក់ងារផ្សេងៗគ្នា។

នគបាលបានទទួលការបណ្តុះបណ្តាលមួយចំនួន ស្តីពីយេនឌ័រប៉ុន្តែពួកគេនៅតែស្វែងរកដៃគូដើម្បីគាំទ្រដើម្បីទទួលបានការបណ្តុះបណ្តាលបន្ថែមទៀត។ មានប៉ុស្តិ៍នគបាលចំនួន៥០នៅក្នុងខេត្តរតនគិរី ហើយពួកគេ បានទទួលការបណ្តុះបណ្តាលខ្លះៗអំពី ការការពារកុមារ យេនឌ័រ អំពើហិង្សាក្នុងគ្រួសារ និងអំពើរំលោភសេពសន្ថវៈ។ ការបញ្ជ្រាបយេនឌ័រនៅគ្រប់វិស័យគឺជាចក្ខុវិស័យរបស់ស្នងការដ្ឋានខេត្ត។[88]

អង្គកា PLAN International កំពុងព្យាយាមធ្វើការជាមួយសហគមន៍ដើម្បីកំណត់ទីតាំងដែលមានហានិភ័យខ្ពស់បំផុត ដូច្នេះសហគមន៍អាចបង្កើតផែនការសកម្មភាពដើម្បីកាត់បន្ថយគ្រោះថ្នាក់ទាំងនេះ។ មានអ្នកតំណាងកុមារនៅតាមភូមិនីមួយៗ គ្រូបង្រៀនសាលាមតេយ្យ និងក្រុមឳពុកម្តាយដែលបានទទួលការបណ្តុះ បណ្តាលពីអង្គការផ្លេន។ នៅក្នុងខេត្តរតនគិរី អង្គការផ្លេន កំពុងពង្រឹងបណ្តាញការពារកុមារដែលមានមូលដ្ឋាននៅតាមសហគមន៍ ក៏ដូចជាក្លឹបកុមារផងដែរ។ ពួកគេសង្កត់ធ្ងន់លើសារៈសំខាន់នៃការរាយការណ៍ករណីអំពើហិង្សាទៅអាជ្ញាធរដើម្បីឲ្យពួកគេចាត់វិធានការ។ អង្គការផ្លេនក៏ផ្តល់ជម្រកសុវត្ថិភាពផងដែរប្រសិនបើកុមារមិនចង់ត្រឡប់ទៅផ្ទះ និងផ្តល់ជំនាញ / ការបណ្តុះបណ្តាលផ្នែកជីវភាពផងដែរ។ ពួកគេដាក់ផ្ទាំងរូបភាពនិងផ្ទាំងប៉ាណូនៅថ្នាក់ស្រុក និងខេត្តអំពីការរាយការណ៍អំពីអ្នករំលោភបំពាន និងបញ្ជូន

[87] បទសម្ភាសន៍ជាមួយតំណាងមកពីមន្ទីរកិច្ចការនារីខេត្តរតនគិរី នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ នៅក្រុងបានលុង ខេត្តរតនគិរី។

[88] បទសម្ភាសន៍ជាមួយ ក្រុមការងារប្រឆាំងការជួញដូរ និងអនីតិជននៃស្នងការប៉ូលីសខេត្តរតនគីរី នាថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០២០ នៅក្រុងបានឡុង ខេត្តរតនគិរី។

ពួកគេទៅពន្ធនាគារ។ ពួកគេសង្កត់ធ្ងន់ថាអំពើរំលោភសេពសន្ថវៈលើកុមារ មិនអាចជាកម្មវត្ថុនៃសំណង ឬដោះស្រាយក្រៅប្រព័ន្ធតុលាការបានឡើយ។[89]

## ៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ការសន្និដ្ឋានទាំងនេះធ្វើឡើងដោយផ្អែកលើបទសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធចំនួន៥៤នាក់ និង២៣ ករណីនៃអំពើហិង្សាលើយេនឌ័រនៅក្នុងខេត្តចំនួន ៣ នៃប្រទេសកម្ពុជា។

## ៥.១ សេចក្តីសន្និដ្ឋាន

### ៥.១.១. ទំនោរ និងស្ថានភាពនៃអំពើហិង្សាផ្អែកលើយេនឌ័រចំពោះស្ត្រីជនជាតិដើម

ខណៈដែលនៅមិនទាន់អាចបញ្ជាក់ពីទំនោរ និងស្ថានភាពនៃអំពើហិង្សាផ្អែកលើយេនឌ័រ ដោយសារតែកង្វះទិន្នន័យដែលស៊ីចង្វាក់គ្នា គ្រប់ជ្រុងជ្រោយ និងបែងចែកត្រឹមត្រូវអំពើហិង្សាផ្អែកលើយេនឌ័រនោះផ្អែកលើព័ត៌មានដែលប្រមូលបានពីវាល ការស្រាវជ្រាវរកឃើញថាហាក់ដូចជាមានការកើនឡើងនៃករណីអំពើហិង្សាផ្អែកលើយេនឌ័រចំពោះស្ត្រីជនជាតិដើមភាគតិចបើប្រៀបធៀបទៅនឹងឆ្នាំ២០១៥។ អំពើហិង្សាក្នុងគ្រួសារគឺ បញ្ហាដែលរាយការណ៍ដោយអាជ្ញាធរមូលដ្ឋានថាបានកើតឡើងជាច្រើននៅក្នុងភូមិ។ ករណីហិង្សាផ្លូវភេទ រួមមានការអំពើរំលោភសេពសន្ថវៈ ការប៉ុនប៉ងរំលោភសេពសន្ថវៈ ការរំលោភនិងសំលាប់ និងការបៀតបៀនផ្លូវភេទ ត្រូវបានរាយការណ៍ទៅអាជ្ញាធរមូលដ្ឋានដោយជនរងគ្រោះរស់រានជីវិតនិងក្រុមគ្រួសារ។ ប៉ុន្តែគ្មានទិន្នន័យជាក់លាក់ណាមួយបញ្ជាក់ពីចំនួនករណីនោះទេ ពីព្រោះភ្នាក់ងាររដ្ឋាភិបាលផ្សេងៗគ្នា មានប្រភពព័ត៌មានផ្សេងៗគ្នា ហើយទិន្នន័យមិនត្រូវបានគេចងក្រង និងបែងចែកតាមជាតិពិន្ទុ ឬរក្សាទុកនៅកន្លែងតែមួយឡើយ។ ហាក់ដូចជាមានកង្វះនូវចំណេះដឹង ជំនាញ និងធនធានដើម្បីចងក្រងព័ត៌មាននេះផងដែរ។

ព័ត៌មានបឋមដែលផ្តល់ដោយក្រុមការងារ CIWWG និង អង្គការមិនមែនរដ្ឋាភិបាលជនជាតិដើមភាគតិច និងមិនមែនជនជាតិដើមផ្សេងទៀត ដែលកំពុងធ្វើការងារជាមួយសហគមន៍ជនជាតិដើមភាគតិចបានអះអាងថាថាជនល្មើសនៃអំពើហិង្សាផ្អែកលើយេនឌ័រភាគច្រើនជា "អ្នកខាងក្រៅ" ឬបុគ្គលដែលមិនមែនជនជាតិដើមភាគតិចនិងមិនមែនជាសមាជិកសហគមន៍។ តាមយៈបទសម្ភាសដែលធ្វើឡើងការស្រាវជ្រាវបានរកឃើញថា ជនល្មើសភាគច្រើនគឺជាបុរសជនជាតិដើមភាគតិចដែលរស់នៅក្នុងសហគមន៍ជាមួយជនរងគ្រោះ និងជាសាច់ញាតិរបស់ជនរងគ្រោះរស់រានជីវិត។ មានជនល្មើសប្រហែលបីនាក់ប៉ុណ្ណោះដែលមិនមែនជាជនជាតិដើមភាគតិច។

---

[89] បទសម្ភាសន៍ជាមួយគណៈគ្រប់គ្រងនៃអង្គការអន្តរជាតិ PLANប្រចាំនៅកម្ពុជា ថ្ងៃទី១៣ តុលា ឆ្នាំ២០២០ ក្នុងរាជធានីភ្នំពេញ កម្ពុជា។

អាពាហ៍ពិពាហ៍កុមារនៅតែជាក្តីកង្វល់មួយនៅក្នុងខេត្តរតនគិរី និងមណ្ឌលគិរី ដោយសារតែអត្រានៃអាពាហ៍ពិពាហ៍ កុមាមានកម្រិតខ្ពស់បំផុតនៅកម្ពុជា។ ក្រសួងកិច្ចការនារីកំពុងតែធ្វើកិច្ចការនេះជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិនានា។

អាជ្ញាធរថ្នាក់ខេត្តដែលផ្តល់បទសម្ភាសគ្មានទិន្នន័យនៃអំពើហិង្សាផ្អែកលើយេនឌ័រ ដែលបែងចែករវាងជនជាតិដើមភាគតិច និងមិនមែនជនជាតិដើមភាគតិចនោះទេ។ យោងលើទិដ្ឋភាពដែល ខេត្តរតនគិរីមានចំនួនជនជាតិដើមភាគតិចច្រើននោះការបែងចែកទិន្នន័យគួរតែត្រូវបានធ្វើឡើង ដើម្បីអនុញ្ញាតធានាការអភិវឌ្ឍដែល មានប្រសិទ្ធភាពនិងសមស្របជាងមុនដើម្បីជួយដល់សហគមន៍ជនជាតិដើមក្នុងការដោះស្រាយអំពើហិង្សាផ្អែកលើយេនឌ័រ តាមរយៈការអនុវត្តវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សនិងការបែងចែកទិន្នន័យ។[90] ការអនុវត្តនេះក៏គួរធ្វើឡើងនៅតាមបណ្តាខេត្តផ្សេងទៀតដែលមានជនជាតិដើមភាគតិចរស់នៅផងដែរ។ ជាក់ស្តែងជនជាតិដើមភាគតិចនៅប្រទេសកម្ពុជាមានចំនួនតិចតួចប៉ុណ្ណោះបើប្រៀបធៀបនឹងស្ថិតិសរុបនៃប្រជាពលរដ្ឋកម្ពុជា ហើយស្ថានភាពស្ត្រីជនជាតិដើមភាគតិចអាចនឹងត្រូវមើលរំលង ប្រសិនបើគ្មានការបែងចែកទិន្នន័យជាក់លាក់។

## ៥.១.២.ជំនឿសន្មត់ខុសឆ្គងអំពីឫសគល់នៃអំពើហិង្សាផ្អែកលើយេនឌ័រ ប្រឆាំងស្ត្រីជនជាតិដើមភាគតិច

អ្នកឆ្លើយតបបទសម្ភាសន៍ទាំងអស់ បានលើកឡើងពីការយល់ឃើញប្រហាក់ប្រហែលគ្នាទាក់ទងនឹងបុព្វហេតុចម្បងនៃអំពើហិង្សាផ្អែកលើយេនឌ័រ គឺដោយសារតែជនល្មើសបានប្រើប្រាស់គ្រឿងញៀន និងឬគ្រឿងស្រវឹង។ កត្តាបន្ទាប់បន្សំផ្សេងទៀតគឺភាពអត់ការងារធ្វើ ឬជីវភាពក្រីក្រ កង្វះការអប់រំ ជនចំណូលថ្មីការប្រច័ណ្ឌការបង្ខំ កង្វះការចូលរួមក្នុងកម្មវិធីប្រជុំអប់រំ ជនល្មើសមិនស្តាប់អាជ្ញាធរ និងចំណង់ផ្លូវភេទរបស់ជនល្មើស។កត្តាទាំងនេះដាក់ការស្តីបន្ទោសទៅលើជនល្មើស។ប៉ុន្តែមានកត្តាមួយចំនួនផ្សេងទៀតហាក់ស្តីបន្ទោសជនរងគ្រោះ។ កត្តាទាំងនេះរួមមាន ស្ត្រីដែលចេញក្រៅតែម្នាក់ឯង ស្ត្រីបង្កើតមិត្តភក្តិជាមួយមនុស្សចម្លែក ឬ"មនុស្សអាក្រក់" ស្ត្រីដែលប្រឆាំងតបនឹងជនល្មើស ស្ត្រីដែលស្លៀកសម្លៀកបំពាក់លេចលើលេចក្រោម ស្ត្រីធ្វើដំណើរផ្លូវឆ្ងាយនិងផ្លូវស្ងាត់ និងស្ត្រីជនជាតិដើមភាគតិចល្ងង់និងមានចិត្តល្អ។ ការយល់ឃើញទាំងនេះបង្ហាញពីភាពរើសអើងយេនឌ័រនិងជំនឿសន្មត់ដែលភាគីពាក់ព័ន្ធប្រកាន់ខ្ជាប់។

ភាពក្រីក្រ គឺជាបុព្វហេតុមួយនៃបុព្វហេតុនានានៃអំពើហិង្សាផ្អែកលើយេនឌ័រនៅកម្ពុជា និងបន្តធ្វើឲ្យអំពើហិង្សានៅតែកើតឡើង។ ស្ត្រីជាទូទៅជ្រើសរើសមិនប្រើប្រាស់នីតិវិធីច្បាប់ ឬរាយការណ៍អំពីអំពើហិង្សាផ្អែកលើយេនឌ័រទេ ដោយសារតែពួកគេត្រូវពឹងផ្អែកផ្អែកសេដ្ឋកិច្ចទៅលើបុរស។ បុរសជាទូទៅគឺជាអ្នករកប្រាក់ចំណូល ប្រសិនបើបុរសជាប់ពន្ធនាគារគ្រួសារនឹងបាត់បង់ប្រាក់ចំណូល។ បញ្ហានេះកើតឡើងនៅក្នុង

[90] https://www.ohchr.org/EN/Issues/Indicators/Pages/documents.aspx.

សហគមន៍ជនជាតិដើមភាគតិចដែលសមាជិកសហគមន៍ភាគច្រើនជាអ្នកធ្វើស្រែនិងចម្ការ។ ប្រសិនបើប្តីត្រូវបានចាប់ខ្លួនគ្រួសារនឹងបាត់បង់កម្លាំងពលកម្មនិងប្រាក់ចំណូល។

ទស្សនៈយល់ឃើញដែលបង្ហាញដោយភាគីពាក់ព័ន្ធជាច្រើន បង្ហាញពីកង្វះការយល់ដឹងអំពីបុព្វហេតុពិតនៃអំពើហិង្សាផ្អែកលើយេនឌ័រ ជាពិសេសអំពើរំលោភសេពសន្ថវៈនិងផ្ទត់គំនិតរើសអើងយេនឌ័រ និងជំនឿសន្មត់ទាក់ទងនឹងពូជសាសន៍ដែលនៅតែកើតមាន។ កត្តាដែលបង្កើនហានិភ័យនៃអំពើហិង្សាដូចជាគ្រឿងញៀននិងស្រាត្រូវបានគេកំណត់ថាជាបុព្វហេតុចម្បង។ អតុល្យភាពនៃទំនាក់ទំនងអំណាចរវាងបុរសនិងស្ត្រីក្នុងវិស័យសាធារណៈនិងឯកជនដែលបង្កើតឡើងដោយបទដ្ឋានសង្គមដែលមានភាពរើសអើង ភាពក្រីក្រ និងប្រព័ន្ធអភិបាលកិច្ចដែលមាក់ងាយស្ត្រី និងខ្វះនីតិរដ្ឋ គឺជាបុព្វហេតុដែលបង្កឲ្យមានអំពើហិង្សាផ្អែកលើយេនឌ័រ រួមទាំងអំពើហិង្សាផ្លូវភេទផងដែរ។ នេះបានបង្កើតឲ្យមានការអនុវត្តទ្វេស្តង់ដារ ចំពោះអាកប្បកិរិយារបស់បុរសនិងស្ត្រីនៅក្នុងសង្គម និងជះឥទ្ធិពលទៅលើលទ្ធភាពក្នុងការសម្រេចចិត្ត ជាពិសេសទាក់ទងការកំណត់អត្តសញ្ញាណខ្លួន សេរីភាពក្នុងការដើរហើរនិងសិទ្ធិផ្លូវភេទ និងសុខភាពបន្តពូជនិង សិទ្ធិនានា។ លុះត្រាតែភាគីពាក់ព័ន្ធទាំងអស់មានការយល់ដឹងច្បាស់លាស់អំពីបញ្ហានេះក្នុងទប់ស្កាត់ និងឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះអំពើហិង្សាបែបនេះនៅតែជាបញ្ហាប្រឈម។

អាជ្ញាធរមូលដ្ឋានមានការយល់ដឹងថាជនល្មើសក៏ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងប្រជាពលរដ្ឋទូទៅគួរតែទទួលបានការអប់រំកុំឲ្យប្រព្រឹត្តអំពើទាំងនេះ។ ការលើកកម្ពស់ការយល់ដឹងដែលបានធ្វើឡើងគឺមានគោលបំណងផ្តោតទៅលើទាំងស្ត្រីនិងបុរសនៅក្នុងសហគមន៍ ដើម្បីឲ្យពួកគេយល់ដឹងកាន់តែច្បាស់អំពីអ្វីដែលច្បាប់ហាមឃាត់ និងទោសទណ្ឌចំពោះបទល្មើសទាំងនេះ។

### ៥.១.៣. ការមាក់ងាយនិងការផាត់ជនរងគ្រោះរស់រានមានជីវិតនៃអំពើហិង្សាផ្អែកលើយេនឌ័រចេញ

ជារឿងល្អដែលមន្ត្រីនគបាលខេត្តរតនគិរីជឿថាគ្មានការរើសអើងប្រឆាំងនឹងជនរងគ្រោះរស់រានជីវិត។ គប្បីមានការចោទសួរអំពីផែនការសមាហរណ៍កម្មជនរងគ្រោះ នៅក្នុងករណីដែលមានការប្រព្រឹត្តទៅលើជនរងគ្រោះខុសពីមុន។ អាជ្ញាធរនិងក្រុមគ្រួសារជនរងគ្រោះរស់រានជីវិតខ្លះហាក់ដូចជាសម្តែង "ការអាណិតអាសូរ" ថាជាប្រតិកម្មវិជ្ជមានដោយពួកគេមិនយល់ថា ទោះបីសកម្មភាពនេះមិនមែនជាការសម្លុត ឬស្តីបន្ទោសជនរងគ្រោះក្តី ការអាណិតអាសូរក៏ជាទម្រង់មួយនៃការរើសអើង ព្រោះបានបង្ហាញថាសហគមន៍មានទស្សនៈចំពោះជនរងគ្រោះរស់រានជីវិតខុសពីមុនបន្ទាប់ពីនាងត្រូវបានគេរំលោភសេពសន្ថវៈ ឬរំលោភបំពាន។

ជនរងគ្រោះរស់រានជីវិតនៃអំពើហិង្សាផ្អែកលើយេនឌ័រ តែងតែប្រឈមនឹងការរើសអើងពីសមាជិកក្នុង

សហគមន៍។ ពួកគេប្រឈមនឹងការអាណិតអាសូរ ការស្តីបន្ទោស និងប្រមាថមាក់ងាយ និងមិនបានទទួលការការពារពីការឃាយីពីសំណាក់សាច់ញាតិជនល្មើស។ ក្រុមគ្រួសារជនរងគ្រោះនិងអាជ្ញាធរមូលដ្ឋានកត់សម្គាល់ថាបន្ទាប់ពីមានហេតុការណ៍កើតឡើងជនរងគ្រោះរស់រានជីវិតផ្លាស់ប្តូរអាកប្បកិរិយាប្លែកៗ ក្លាយទៅជាមនុស្សដែលមានការអៀនខ្មាស និងស្ងៀមស្ងាត់។ អារម្មណ៍របស់ជនរងគ្រោះរស់រានជីវិត និងរបៀបដែលសហគមន៍មើលមកពួកគេបន្ទាប់ពីឧប្បត្តិហេតុគឺស្តែងឲ្យឃើញពីការមាក់ងាយ។ ភាគច្រើននៃសហគមន៍ជនជាតិដើមភាគតិចគឺមានសមាជិកសហគមន៍តិចតួច ហើយប្រជាពលរដ្ឋនៅក្នុងសហគមន៍សុទ្ធតែស្គាល់គ្នាទៅវិញទៅមក។ ដោយសារតែទំហំតូចនៃសហគមន៍នោះ ស្ថានភាពនៃការមាក់ងាយក្រោយពេលដែលមានអំពើហិង្សាផ្អែកលើយេនឌ័រកើតឡើងហាក់មានឥទ្ធិពលខ្លាំង ជាពិសេសនៅក្នុងករណីដែលក្រុមគ្រួសារជនល្មើសក៏ជាអ្នកដែលរស់នៅក្នុងសហគមន៍តែមួយ។ ជាការកត់សម្គាល់ដោយគណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្រ្តីភេទធ្វើឡើងនៅក្នុងការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ឆ្នាំ២០១៩ ការមាក់ងាយសង្គម និងវប្បធម៌គឺជាឧបសគ្គក្នុងការទទួលបានយុត្តិធម៌ ពីព្រោះកត្តានេះបានរារាំងស្ត្រីនិងក្មេងស្រី ពីការដាក់ពាក្យបណ្តឹងទាក់ទងនិងអំពើហិង្សាផ្អែកលើយេនឌ័រ។ ព័ត៌មានដែលប្រមូលបាននៅក្នុងបទសម្ភាសន៍ទាំងអស់ក៏បានបង្ហាញផងដែរថាការមាក់ងាយបានជះផលប៉ះពាល់អវិជ្ជមានដល់សុខភាពផ្លូវចិត្តរបស់ជនរងគ្រោះរស់រានជីវិត និងបានក្លាយទៅជាឧបសគ្គរាំងការទទួលបានការអប់រំនិងជីវិតសង្គម។

## ៥.១.៤ ការអនុវត្តច្បាប់ពាក់ព័ន្ធ និងភាពខ្វះចន្លោះ

នៅមានភាពខ្វះចន្លោះនៅក្នុងខ្លឹមសារក្របខ័ណ្ឌច្បាប់និងគោលនយោបាយពាក់ព័ន្ធដែលមានស្រាប់ ដែលបានតាក់តែងឡើងដើម្បីដោះស្រាយអំពើហិង្សាផ្អែកលើយេនឌ័រ។ នៅក្រោមច្បាប់កម្ពុជាការផ្តល់និយមន័យនៃអំពើបៀតបៀនផ្លូវភេទ នៅមានលក្ខណៈចង្អៀត និង អនុវត្តចំពោះតែស្ថានភាពដែលកើតឡើងនៅកន្លែងការងារតែប៉ុណ្ណោះ។ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឆ្នាំ ២០០៥ មិនបានផ្តល់និយមន័យពេញលេញទាក់ទងនិងអំពើហិង្សាក្នុងគ្រួសារទេ ពីព្រោះមិនបានដាក់បញ្ចូលនូវសកម្មភាពជាក់លាក់មួយចំនួន និងការគំរាមគំហែងនានា ដែលអាចបង្កហានិភ័យដល់ផ្លូវកាយ ផ្លូវចិត្ត ផ្លូវសេដ្ឋកិច្ច ឬផ្លូវភេទ និង មិនបានដាក់បញ្ចូលសកម្មភាពលួចតាមដានសកម្មភាព។ ច្បាប់នេះក៏មិនបានផ្តល់ និយមន័យជាក់លាក់កំណត់អំពី បុគ្គលដែលអាចរងផលប៉ះពាល់ដោយអំពើហិង្សាក្នុងគ្រួសារ និងមិនបានដាក់បញ្ចូលដៃគូស្និទ្ធស្នាល និង សមាជិកគ្រួសារដែលមិនបានរស់នៅក្រោមដំបូលផ្ទះតែមួយ ព្រមទាំងមិនបានដាក់បញ្ចូលនូវអំពើហិង្សាដែលបង្កឡើងលើអ្នកស្រលាញ់ភេទដូចគ្នា និងកុមារ។ ច្បាប់នេះក៏បានអនុញ្ញាតឲ្យមានការ "ដាក់វិន័យ" ទៅលើប្តីប្រពន្ធនិងកូនៗ។ ច្បាប់នេះគួរតែមានបញ្ចូលបទប្បញ្ញត្តិជាក់លាក់ ទាក់ទងនិងស្ត្រីជនជាតិដើមភាគតិចផងដែរ ដោយសារតែកម្ពុជានៅមិនទាន់មានច្បាប់ជាក់លាក់ស្តីពីស្ត្រីជនជាតិភាគតិចនោះទេ។

ដូចដែលបានណែនាំដោយគណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ នៅក្នុងការធ្វើ

សេចក្តីសន្និដ្ឋានបញ្ចប់ឆ្នាំ២០១៩ រដ្ឋាភិបាលគួរតែពិនិត្យខ្លឹមសារច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះនិងគួរធ្វើវិសោធនកម្មបទប្បញ្ញត្តិពាក់ព័ន្ធឡើងវិញ "កំណត់ការហាមឃាត់និងដាក់ទណ្ឌកម្មលើទម្រង់អំពើហិង្សាផ្អែកលើយេនឌ័រ រួមទាំងអំពើហិង្សាក្នុងគ្រួសារ រួមទាំងដាក់បញ្ចូលអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ផងដែរ ដើម្បីសម្រួលដល់ដំណើរការនៃការទទួលបានដីការការពារ និងដើម្បីធានាថាជនរងគ្រោះ/ ជនរងគ្រោះរស់រានជីវិតពីអំពើហិង្សាក្នុងគ្រួសារអាចទទួលបានដោះស្រាយប្រកបដោយប្រសិទ្ធភាព ហើយជនល្មើសត្រូវទទួលខុសត្រូវចំពោះអំពើដែលបានប្រព្រឹត្ត[ ]"។ [91]

គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទបានកត់សម្គាល់ថា "គ្មានការចែងជាក់លាក់នៅក្នុងរដ្ឋធម្មនុញ្ញដែលកំណត់អំពីការរើសអើងដោយផ្ទាល់និងការរើងអើងដោយប្រយោលលើស្ត្រីទេ ហើយការហាមឃាត់ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ផ្តោតទៅលើតែទម្រង់នៃការរើសអើងដោយផ្ទាល់ដូចជាការបដិសេធការទទួលបានទំនិញ សេវាកម្ម ឬការងារ។ គណៈកម្មាធិការក៏បានកត់សម្គាល់ផងដែរថាច្បាប់ដែល បានធ្វើវិសោធនកម្មថ្មីៗនេះ មិនបានដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវវិសមភាពរវាងបុរសនិងស្ត្រី និងបានសំដែងការសោកស្តាយចំពោះកង្វះនូវនៃការវាយតម្លៃផលប៉ះពាល់យេនឌ័រ នៅមុនពេលអនុម័ត ឬធ្វើវិសោធន៍កម្មច្បាប់ទាំងនោះ"។[92]

### ៥.១.៥. ការទទួលបានយុត្តិធម៌របស់ជនរងគ្រោះរស់រានជីវិត

ការស្រាវជ្រាវបានរកឃើញពីកង្វះការតាមដាននិងឆ្លើយតបប្រកបដោយប្រសិទ្ធភាពរបស់អាជ្ញាធរថ្នាក់ខ្ពស់ចំពោះសំណុំរឿងដែលអាជ្ញាធរមូលដ្ឋានបញ្ជូន។ ការណ៍ដែលករណីមួយចំនួនត្រូវបានដោះស្រាយនៅប៉ុស្តិ៍នគរបាលឃុំ ឬស្រុក គឺជាបញ្ហាដែលគួរឲ្យព្រួយបារម្ភផងដែរ។ នគបាលយុត្តិធម៌មានកាតព្វកិច្ចបញ្ជូនសំណុំរឿងទៅតុលាការ និងមិនគួរដោះស្រាយរឿងក្តីដោយខ្លួនឯងឡើយ។ ករណីនេះបានកំហិតដល់លទ្ធភាពទទួលបានយុត្តិធម៌របស់ជនរងគ្រោះ / និងជនរងគ្រោះរស់រានជីវិត និង / ឬគ្រួសាររបស់ពួកគេ។

ការខកខានក្នុងការចាប់ខ្លួនជនល្មើស បង្ហាញពីភាពទន់ខ្សោយនៅក្នុងដំណើរការស៊ើបអង្កេតរបស់នគបាលយុត្តិធម៌ និងអាជ្ញាធរមូលដ្ឋាន ដែលមិនអាចកំណត់អត្តសញ្ញាណជនល្មើសបាន និងហាក់ដូចជាមិនបានប្រឹងប្រែងដើម្បីស្វែងរកជនល្មើសដែលបានរត់គេចខ្លួនចេញពីតំបន់នោះ។ ខ្វះការសម្របសម្រួលរវាងប៉ុស្តិ៍នគរបាលឃុំ និងនគរបាលខេត្ត ក្នុងការចែករំលែកព័ត៌មានអំពីជនល្មើសនិងការស្នើសុំចាប់ខ្លួន។ បន្ថែមលើនេះ ការសម្របសម្រួលរវាងនគរបាលយុត្តិធម៌ និងមន្ត្រីសាលាដំបូងខេត្ត ជាពិសេសការិយាល័យ

---

[91] CEDAW, សេចក្តីសន្និដ្ឋានស្តីពីរបាយការណ៍របស់ប្រទេសកម្ពុជាតាមកាលកំណត់លើកទី៦ នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៩, CEDAW/C/KHM/CO/6, កថាខណ្ឌ២៥(b)។

[92] ដូចខាងលើ។ កថាខណ្ឌ ៨

ព្រះរាជអាជ្ញាគួរតែមានភាពល្អប្រសើរជាងនេះ។

ការស្រាវជ្រាវក៏បានរកឃើញពី កង្វះនូវការគាំទ្រដល់ជនរងគ្រោះនិងក្រុមគ្រួសារ / ជនរងគ្រោះដែលមិនអាចបន្តរឿងក្តីព្រហ្មទណ្ឌ និងធ្វើដំណើរទៅតុលាការក្នុងករណីដែលគ្មានជំនួយពីខាងក្រៅទាំងផ្នែកហិរញ្ញវត្ថុនិងជំនួយផ្លូវច្បាប់។ ហាក់បីដូចជានៅមានកង្វះការសម្របសម្រួលរវាងជនរងគ្រោះរស់រានជីវិត និងតុលាការដោយសារតែជនរងគ្រោះរស់រានជីវិត ក្រុមគ្រួសារ និងអាជ្ញាធរមូលដ្ឋានមួយចំនួនបានអះអាងថាពួកគេមិនដឹងថាសំណុំរឿងរបស់ពួកគេត្រូវបានមន្ត្រីតុលាការចាត់នីតិវិធីនៅក្នុងដំណាក់កាលណាទេ។ បន្ថែមលើនេះអ្នកខ្លះបានត្អូញត្អែរអំពីការខ្វះការរីកចម្រើននៃករណីជាក់ស្តែង។ ករណីទាំងនេះគឺជាឧបសគ្គមួយចំនួនដែល រារាំងដល់ការទទួលបាននូវយុត្តិធម៌ដែលកត់សម្គាល់ដោយគណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ "ការទទួលបានព័ត៌មានតិចតួចនិងមិនជាក់លាក់អំពីយន្តការ និងនីតិវិធីនៅក្នុងការស្វែងរកដំណោះស្រាយនៅក្នុងករណីនៃអំពើរំលោភលើសិទ្ធិស្ត្រីនិងក្មេងស្រី ជាពិសេសតំបន់ជនបទ"។ ដើម្បីលុបបំបាត់ឧបសគ្គនេះនិងដើម្បីទទួលបានយុត្តិធម៌ គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទបានផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលឲ្យ "បង្ហាញនូវព័ត៌មានស្តីពីយន្តការនិងនីតិវិធីដែលមានស្រាប់"។[93]

មានករណីមួយចំនួនដែលបង្ហាញអំពីទំនាស់រវាងសិទ្ធិរស់រានជីវិត និងសិទ្ធិផ្នែកវប្បធម៌របស់ជនជាតិដើមភាគតិច ដូចបង្ហាញនៅក្នុងករណីដែលបានដោះស្រាយដោយប្រើប្រាស់យន្តការបែបប្រពៃណី ដែលជនល្មើសបានទូទាត់សំណងជាប្រាក់ដើម្បីបញ្ចប់រឿងក្តី និងមិនបានទទួលខុសត្រូវចំពោះមុខច្បាប់ចំពោះសកម្មភាពហិង្សារបស់ពួកគេ។ យន្តការដោះស្រាយបែបប្រពៃណីមិនបានប្រើវិធីសាស្ត្រផ្តោតលើផលប្រយោជន៍ជនរងគ្រោះរស់រានជីវិត ប៉ុន្តែបែជាផ្តោតទៅលើអ្វីដែលគេជឿថាល្អសម្រាប់សហគមន៍ទៅវិញ។ ជនល្មើសអាចស្ថិតនៅក្នុងភូមិដែលជនរងគ្រោះរស់នៅ។ បន្ថែមលើនេះជួនកាលដំណោះស្រាយប្រពៃណីបានរំលោភលើសិទ្ធិជនរងគ្រោះរស់រានជីវិត និងបង្កគ្រោះថ្នាក់ដល់នាងបន្ថែមទៀត។ ជាក់ស្តែងគឺការស្នើសុំឲ្យជនរងគ្រោះ រស់រានជីវិតចាកចេញពីភូមិ ដើម្បីកុំឲ្យសហគមន៍ទាំងមូលជួបប្រទះនឹងសំណាងអាក្រក់ដែលបណ្តាលមកពីគ្រោះថ្នាក់ធ្ងន់ធ្ងរដែលបានកើតឡើងចំពោះជនរងគ្រោះ។

មន្ត្រីតុលាការមួយចំនួនបានលើកឡើងពីជំនឿសន្មត់ដែលប្រកាន់ពូជសាសន៍ និងបង្ហាញថាជនជាតិដើមភាគតិចល្ងង់ គ្មានចំណេះដឹង និងមិនចង់អនុវត្តច្បាប់ដោយសារតែជំនឿប្រពៃណីនិងវប្បធម៌។ ជំនឿសន្មត់ទាំងនេះបង្ហាញពីភាពលំអៀង និងការរើសអើងប្រឆាំងនឹងជនជាតិដើមភាគតិចផ្អែកលើការអារម្មណ៍បុគ្គល

[93] អនុសញ្ញាCEDAW, សេចក្តីសន្និដ្ឋានស្តីពីរបាយការណ៍របស់ប្រទេសកម្ពុជាតាមកាលកំណត់លើកទី៦ នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៩, CEDAW/C/KHM/CO/6, កថាខណ្ឌ១០ (b) និង១១ (c)។

ដែលជា លទ្ធផលបង្ហាញពីកង្វះការយល់ដឹងអំពីប្រពៃណីនិងវប្បធម៌ជនជាតិដើមភាគតិច។ រដ្ឋធម្មនុញ្ញកម្ពុជានិងមាត្រា ២ នៃសេចក្តីប្រកាសស្តីពីសិទ្ធិជនជាតិដើមភាគតិចរបស់អង្គការសហប្រជាជាតិបានហាមប្រាមការរើសអើងជនជាតិដើមភាគតិច។ ខណៈដែលចេតនារបស់អាជ្ញាធរដែលមិនមែនជាជនជាតិដើមភាគតិចអាចមិនបង្កគ្រោះថ្នាក់នោះ ការយល់ដឹងបន្ថែមអំពីវប្បធម៌និងប្រពៃណីរបស់សហគមន៍ជនជាតិដើមភាគតិច នឹងជួយពួកគេក្នុងការបង្កើនលទ្ធភាពជួយជ្រោមជ្រែងសហគមន៍ទាំងនេះឲ្យកាន់តែប្រសើរឡើង។ ការធ្វើដូច្នេះនឹងអនុលោមតាមមាត្រា១៥ (២) នៃសេចក្តីប្រកាសស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិចរបស់អង្គការសហប្រជាជាតិ ស្តីពីការទទួលខុសត្រូវរដ្ឋភាគីក្នុងការប្រយុទ្ធប្រឆាំងនឹងជំនឿសន្មត់ទុកជាមុន ការលុបបំបាត់អំពើរើសអើង និងលើកកម្ពស់ការអត់អោន ការយោគយល់ និងទំនាក់ទំនងល្អក្នុងចំណោមជនជាតិដើមភាគតិចនិងផ្នែកផ្សេងទៀតនៃសង្គម។

## ៥.១.៦. លទ្ធភាពទទួលបាននិងការឆ្លើយតបចំពោះការគាំទ្រដល់និងកិច្ចការពារជនរងគ្រោះ

ការពិនិត្យសុខភាពនិងការប្រឹក្សាយោបល់ផ្នែកចិត្តសាស្ត្រ មិនត្រូវបានផ្តល់ឲ្យជាប្រចាំដល់អ្នករងគ្រោះរស់រានជីវិត ឬគ្រួសារទេ បន្ថែមលើពួកគេមិនបានទទួលលទ្ធផលនៃពិនិត្យសុខភាពទៀតផង។ អង្គការមិនមែនរដ្ឋាភិបាលច្រើនតែនាំមុខក្នុងការផ្តល់ការគាំទ្រផ្នែកចិត្តសាស្ត្រ។ មន្ត្រីបុគ្គលិកមន្ទីរកិច្ចការនារីខេត្តរតនៈគិរីបានថ្លែងថាពួកគេបានផ្តល់ការប្រឹក្សាផ្លូវចិត្តដល់ជនរងគ្រោះ ទោះបីពួកគេមិនបានទទួលការបណ្តុះបណ្តាលជាផ្លូវការទាក់ទងនិងផ្នែកចិត្តសាស្ត្រនិងការដោះស្រាយការប៉ះទង្គិចផ្លូវចិត្តក៏ដោយ។

ការកែលម្អសេវាសុខាភិបាល និងសេវាប្រឹក្សាផ្លូវចិត្តគឺចាំបាច់ណាស់ ដើម្បីអនុវត្តតាមអនុសាសន៍របស់គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី និងមាត្រា ២៤ (២) នៃសេចក្តីប្រកាសស្តីពីសិទ្ធិជនជាតិដើមរបស់អង្គការសហប្រជាជាតិដែលចែងថា "ជនជាតិដើមភាគតិចមានសិទ្ធិស្មើគ្នាក្នុងការទទួលបានសេវាថែទាំសុខភាពដែលមានស្តង់ដារ និងគួរទទួលនូវសេវាសុខភាពថែទាំផ្លូវកាយនិងផ្លូវចិត្ត។ រដ្ឋភាគីត្រូវចាត់វិធានការចាំបាច់នានាដើម្បីសម្រេចឲ្យនូវការអនុវត្តដោយពេញលេញនូវសិទ្ធិនេះ"។

ការឧបត្ថម្ភគាំទ្រដែលបានផ្តល់ដល់ជនរងគ្រោះរស់រានជីវិតភាគច្រើន ជាជំនួយរយៈពេលខ្លីដូចជាម្ហូបអាហារប្រាក់តិចតួច និងការបណ្តុះបណ្តាលជំនាញមួយចំនួន។ ការគាំទ្រហាក់ដូចជាមិនបានគិតគូរពីតម្រូវការរយៈពេលវែងរបស់ជនរងគ្រោះដូចជាការប្រឹក្សាយោបល់ផ្លូវចិត្ត។ អាជ្ញាធរខេត្តនិងអង្គការក្រៅរដ្ឋាភិបាលបានកត់សម្គាល់ថាជាទូទៅស្ត្រីត្រូវពឹងផ្អែកសេដ្ឋកិច្ចលើស្វាមី ដូច្នេះពួកគេមានភាពស្ទាក់ស្ទើរក្នុងការដាក់ពាក្យបណ្តឹងដោយខ្លាចគ្រួសារបាត់បង់ប្រាក់ចំណូល។ តម្រូវការប្រាក់ចំណូលបន្ថែមតាមរយៈការបង្កើតកម្លាំងពលកម្មបន្ថែម ក៏ត្រូវបានគេកំណត់ថាជាហេតុផលជម្រុញឲ្យមានអាពាហ៍ពិពាហ៍កុមារ។ ការផ្តល់ការគាំទ្រផ្នែកជីវភាពសម្រាប់ស្ត្រីគឺជាតម្រូវការចាំបាច់ ដើម្បីជួយឲ្យពួកគេទទួលបានសន្តិសុខផ្នែក

សេដ្ឋកិច្ច និងមិនចាំបាច់ពឹងផ្អែកលើបុគ្គលដែលអាចរំលោភបំពានពួកគេ។ ការយល់ដឹងកាន់តែច្បាស់អំពីវប្បធម៌ជនជាតិដើមភាគតិច និងទំនាក់ទំនងអំណាចនៅក្នុងគ្រួសារនៅក្នុងវប្បធម៌នេះ គឺមានភាពចាំបាច់ក្នុងការរៀបចំ ផែនការគាំទ្រដែលសមស្រប និងមានរយៈពេលវែងដែលអាចទទួលយកបាន ជាពិសេសការគាំទ្រផ្នែកជំនាញនិងកម្មវិធីបណ្តុះបណ្តាលពង្រឹងផ្នែកជីវភាព។

ការដាក់បន្ថែមវត្តមានប៉ុស្តិ៍នគបាលនៅតាមភូមិគឺជាចំណាត់ការដែលគួរលើកទឹកចិត្ត ការនេះនឹងផ្តល់ភាពងាយស្រួលដល់ជនរងគ្រោះរស់រានដ្ឋជីវិត ឬក្រុមគ្រួសារ ក្នុងការរាយការណ៍អំពីករណីអំពើហិង្សាផ្អែកលើយេនឌ័រ។ ការដែលមន្ត្រីនគបាលបានស្នើសុំឲ្យមានកការបណ្តុះបណ្តាលសម្រាប់ពួកគេបន្ថែមទៀតនោះ ក៏គួរទទួលបានការលើកទឹកចិត្តផងដែរ ពីព្រោះនឹងជួយពួកគេឲ្យយល់កាន់តែច្បាស់ជំនឿសន្មត់អំពីយេនឌ័រ និងជួយសហគមន៍បន្ថែមទៀត។

មានការផ្តល់យោបល់ជាច្រើនថា ដើម្បីទប់ស្កាត់អំពើហិង្សាផ្អែកលើយេនឌ័រដែលបង្កឡើងដោយជំនឿសន្មត់យេនឌ័រដែលមានលក្ខណៈរើសអើង និងដាក់បន្ទុកទៅលើជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈលើជនរងគ្រោះ /ជនរងគ្រោះរស់រានដ្ឋជីវិត ជាជាងជនល្មើសនោះ ជំនួសឲ្យការចាប់ជនល្មើសឲ្យទទួលខុសត្រូវចំពោះអំពើឧក្រិដ្ឋរបស់ពួកគេ ឬទាមទារឲ្យអនុវត្តច្បាប់ប្រកបប្រសិទ្ធភាពជាងមុននោះ ប្រជាពលរដ្ឋជាច្រើនបានប្រើប្រាស់វិធីសាស្ត្របែបការពារនិយមផ្អែកលើផ្នត់គំនិតយេនឌ័រដែលរើសអើង។ សកម្មភាពនេះគឺជាការរើសអើងដោយប្រយោលទៅស្ត្រីនិងក្មេងស្រី ដោយបានដាក់កំហិតទៅលើសិទ្ធិស្វ័យភាពរបស់ស្ត្រីរួមទាំងសេរីភាពនៃការដើរហើរ និងបង្ខំឲ្យស្ត្រីជាអ្នកទទួលខុសត្រូវក្នុងការទប់ស្កាត់អំពើរំលោភសេពសន្ថវៈ និងទម្រង់ដទៃទៀតនៃអំពើហិង្សាផ្អែកលើយេនឌ័រ ដែលទង្វើនេះឆ្លុះបញ្ចាំងអំពីវប្បធម៌ស្តីបន្ទោសជនរងគ្រោះនៅក្នុងសហគមន៍។ ដោយសារតែរបបបិតាធិបតេយ្យបានចាក់ស្រេះនៅក្នុងរបបដឹកនាំសង្គម និងវប្បធម៌នៅកម្ពុជានិងបានកំណត់អំពីតួនាទីស្ត្រីនៅក្នុងសង្គមនោះ អាចពិបាកផ្តល់ការពន្យល់ពីផលប៉ះពាល់អវិជ្ជមាននៃការប្រសព្វរវាងវប្បធម៌និងបទដ្ឋានសង្គមដែលរើសអើង និងអាកប្បកិរិយាដែលផ្តល់បុព្វសិទ្ធិទៅបុរសនោះ ដូចមានចែងនៅក្នុងក្រមច្បាប់ស្រី។ ភាពក្រីក្រក៏អាចនាំឲ្យមានអតុល្យភាពអំណាចដែលបង្កឲ្យមានអំពើហិង្សាប្រឆាំងនឹងស្ត្រីនិងក្មេងស្រី។ លុះត្រាតែគ្រប់ភាគីពាក់ព័ន្ធទាំងអស់បានយល់ច្បាស់អំពីឫសគល់នេះ ការទប់ស្កាត់និងឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះអំពើហិង្សាផ្អែកលើយេនឌ័រនៅតែជាបញ្ហាប្រឈម។

ការកើនឡើងនៃការប្រើប្រាស់បណ្តាញទូរស័ព្ទទាន់ហេតុការណ៍សម្រាប់ប្រជាពលរដ្ឋដើម្បីរាយការណ៍ អំពីករណីអំពើហិង្សាផ្អែកលើយេនឌ័រគឺជាការលើកទឹកចិត្ត ប៉ុន្តែសេវានេះគួរតែអាចរកបាន និងប្រើប្រាស់បានដោយសហគមន៍ជនជាតិដើមភាគតិចផងដែរ ដូច្នេះការដាក់បញ្ចូលភាសាជនជាតិដើមគឺជាការចាំបាច់។

ការសម្របសម្រួលរវាងភ្នាក់ងាររដ្ឋាភិបាលដែលទទួលបន្ទុកក្នុងការដោះស្រាយអំពើហិង្សាផ្អែកលើយេនឌ័រគួរតែមានកែលម្អ។ នៅខេត្តរតនៈគីរី ភ្នាក់ងាររដ្ឋាភិបាលមួយបានលើកឡើងអំពីការលំបាកក្នុងការសហការជាមួយភ្នាក់ងាររដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលមួយផ្សេងទៀត នៅពេលដែលស្វែងរកជំនួយគាំទ្រផ្នែកសម្ភារៈសម្រាប់ជនរងគ្រោះរស់រានជីវិត។ ការបណ្តុះបណ្តាលស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រសម្រាប់សហគមន៍ជនជាតិដើមភាគតិចដែលធ្វើឡើងដោយមន្ត្រីនគបាលគ្មានការចូលរួមពីមន្ទីរកិច្ចការនារី។ ចុងក្រោយមិនមានយន្តការតែមួយក្នុងការប្រមូលនិងរក្សាទុកទិន្នន័យស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រដែលនាំឲ្យមានស្ថិតិខុសៗគ្នា នៅតាមស្ថាប័ននីមួយៗ។

## ៥.២. អនុសាសន៍

### ៥.២.១ .សកម្មភាពដើម្បីដោះស្រាយឬសគល់/ទប់ស្កាត់អំពើហិង្សាផ្អែកលើយេនឌ័រ

<u>*អនុសាសន៍សម្រាប់រាជរដ្ឋាភិបាលកម្ពុជា*</u>

១.គួរធ្វើការសិក្សាស្រាវជ្រាវបន្ថែមជុំវិញករណីអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងស្ត្រីជនជាតិដើមភាគតិច និងធ្វើការវិភាគដោយហ្មត់ចត់ ដោយផ្តោតការយកចិត្តទុកដាក់លើបុព្វហេតុនានាដែលជម្រុញឲ្យមានការកើនឡើងនៃអំពើហិង្សាទាំងនេះ និងការចូលរួមរបស់សមាជិកផ្សេងៗទៀតក្នុងគ្រួសារក្នុងករណីជាច្រើន។

២. អាជ្ញាធរថ្នាក់ខេត្ត និងអាជ្ញាធរមូលដ្ឋាន រួមទាំងមន្ត្រីនគបាលយុត្តិធម៌ តុលាការ និងសហគមន៍ ជនជាតិដើមភាគតិចគួរបង្កើនការយល់ដឹងបន្ថែម និងទទួលបានការបណ្តុះបណ្តាលអំពីឫសគល់នៃអំពើហិង្សាផ្អែកលើយេនឌ័រ។ រាជរដ្ឋាភិបាលគួរធ្វើការជាមួយអង្គការសិទ្ធិស្ត្រី អង្គការសិទ្ធិមនុស្ស អង្គការជនជាតិដើមភាគតិច និងទីភ្នាក់ងារនានានៃអង្គការសហប្រជាជាតិ ដើម្បីៈ

ក. រៀបចំវាយតម្លៃអំពីតម្រូវការកម្មវិធីបណ្តុះបណ្តាលក្នុងចំណោមភាគីពាក់ព័ន្ធ ដើម្បីកំណត់អំពីកម្រិតនៃការយល់ដឹងទាក់ទងនិងបញ្ហា

ខ. រៀបចំតាក់តែងមេរៀនមូលដ្ឋានស្តីពីៈ

- ក្របខណ្ឌច្បាប់ និងយន្តការការពារទាក់ទងនិងអំពើហិង្សាផ្អែកលើយេនឌ័រ
- ទទួលស្គាល់អតុល្យភាពនៃទំនាក់ទំនងអំណាចយេនឌ័រ និងដោះស្រាយបញ្ហានេះ
- កំណត់និងដោះស្រាយបទដ្ឋានសង្គមដែលរើសអើងយេនឌ័រ និងជំនឿ សន្ទត់យេនឌ័រ
- កំណត់និងដោះស្រាយកត្តាពាក់ព័ន្ធដែលជម្រុញឲ្យមានអំពើហិង្សាផ្អែកលើយេនឌ័រ រួមទាំងរចនាសម្ព័នឬសគល់នៃបញ្ហាដូចជាភាពក្រីក្រ ការមិនទទួលបានការអប់រំ ការមិនទទួលបានសិទ្ធិផ្លូវភេទនិងសុខភាពបន្តពូជពេញលេញ ការរើសអើងពូជសាសន៍ ។ល។
- លុបបំបាត់ជំនឿសន្ទត់យេនឌ័រនៅក្នុងប្រព័ន្ធតុលាការ

គ. រៀបចំវគ្គបណ្តុះបណ្តាលសម្រាប់គ្រូបង្គោល ដែលអាចទៅបន្តបង្រៀននៅតាមឃុំតំបន់ជនបទ

ឃ. ការរៀបចំមេរៀន និងវិធីសាស្ត្របង្រៀនមិនគួរប្រើប្រាស់អក្សរច្រើនពេក។ ការប្រើប្រាស់ វិធី

សាស្ត្របែបចូលរួមនិងសកម្មគឺមានការចាំបាច់ណាស់។

ង. ការបណ្តុះបណ្តាលស្តីពីសិទ្ធិផ្លូវភេទនិងសុខភាពបន្តពូជគឺចាំបាច់ណាស់សម្រាប់សហគមន៍ជនជាតិដើមភាគតិច

ច. ផ្តល់វគ្គបណ្តុះបណ្តាលបន្ថែមទាក់ទងនិងសិទ្ធិផ្លូវភេទ និងសុខភាពបន្តពូជ និងបូរណភាពរាងកាយ

ឆ. ឃ្លាំមើលយ៉ាងទៀតទាត់អំពីប្រសិទ្ធភាពនៃវគ្គបណ្តុះបណ្តាល

នៅពេលដែលមានការយល់ដឹងត្រឹមត្រូវអំពិទស្សនទានទាំងអស់នេះ នឹងមានភាពងាយស្រួលដល់ភ្នាក់ងាររដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ ក្នុងការរៀបចំតាក់តែងបទអន្តរាគមន៍ដែលសមស្រប ដើម្បីទប់ស្កាត់អំពើហិង្សាផ្អែកលើយេនឌ័រ។ ហើយក៏នឹងមានភាពងាយស្រួលក្នុងការទទួលបានការគាំទ្រពីសហគមន៍ជនជាតិដើមភាគតិចនៅក្នុងបទអន្តារគមន៍ទាំងអស់នោះ។

៣.គួរដាក់ចេញនូវកម្មវិធីលើកកម្ពស់ការយល់ដឹងចំពោះបញ្ហាទាំងអស់នេះ ដើម្បីធានាថាមន្ត្រីសាធារណៈ និង អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងអង្គការមហាជននានាមានការយល់ដឹង ត្រឹមត្រូវអំពីយេនឌ័រ រួមទាំងអង្គការស្ត្រីជនជាតិដើមភាគតិច និងគួរសហការឲ្យបានពេញលេញជាមួយពួកគេដើម្បីធានាថាការបណ្តុះបណ្តាលត្រូវបានធ្វើឡើងក្នុងលក្ខណៈទ្រង់ទ្រាយធំ ជាពិសេសនៅក្នុងតំបន់ភូមិសាស្ត្រដែលរដ្ឋាភិបាលមិនមានធនធានគ្រប់គ្រាន់ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលនោះ ។

៤.គួរបង្កើតនូវយន្តការគ្រប់គ្រងទិន្នន័យ ដែលធ្វើការបំបែកទិន្នន័យតាម អាយុ ភេទ និងជាតិពន្ធ ជាពិសេសនៅក្នុងខេត្តនានាដែលមានសហគមន៍ជនជាតិដើមភាគតិចនិងបង្កើតផែនការដើម្បីសម្រេចបាននូវទិន្នន័យបំបែកពេញលេញមួយដែលមានរយៈពេល៥ឆ្នាំ។ ការប្រមូល ការគ្រប់គ្រង និងការប្រើប្រាស់ទិន្នន័យស្តីពីអំពើហិង្សា ផ្អែកលើយេនឌ័រ គួរតែអនុវត្តនូវវិធីសាស្ត្រផ្តោតលើសិទ្ធិមនុស្សដោយប្រកាន់ខ្ជាប់នូវគោលការណ៍នៃការចូលរួម ការបំបែកទិន្នន័យ ស្វ័យអត្តសញ្ញាណ តម្លាភាព ឯកជនភាព និងគណនេយ្យភាព។

៥.គួរបន្តការងាររបស់ខ្លួនលើការទប់ស្កាត់អាពាហ៍ពិពាហ៍កុមារ រួមទាំងបន្តនូវរាល់កិច្ចសហការរបស់ខ្លួនជាមួយអង្គការមូលដ្ឋាននិងអន្តរជាតិនានាទៅលើបញ្ហានេះ។

៦.គួរធ្វើវិសោធនកម្មក្រមខណ្ឌច្បាប់រួមទាំងដាក់ចេញនូវច្បាប់ស្តីពីការរើសអើងប្រឆាំងស្ត្រី ពង្រីកនិយមន័យនៃអំពើបៀតបៀនផ្លូវភេទ និងធ្វើការត្រួតពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មច្បាប់អំពើហិង្សាក្នុងគ្រួសារ ដូចដែលគណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើងប្រឆាំងស្ត្រី បានផ្តល់ជាអនុសាសន៍។ ដូចជា៖

ក) ដាក់ចេញនូវច្បាប់ស្តីពីការរើសអើងប្រឆាំនិងស្ត្រី

ខ) ពង្រីកនិយមន័យនៃអំពើបៀតបៀនផ្លូវភេទនៅក្នុងក្រមព្រហ្មទណ្ឌ ដើម្បីដាក់បញ្ចូលនូវអំពើបៀតបៀន ផ្លូវភេទដែលកើតឡើងក្រៅកន្លែងការងារ និងអំពើបៀតបៀនដែលបង្កឡើងដោយអ្នកក្រោមឱវាទ ឬសហការីដែលមានតួនាទីស្មើគ្នា

គ) ធ្វើវិសោធន៍កម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះដើម្បី "កំណត់ ហាមឃាត់ និងកំណត់ទោសឧក្រិដ្ឋចំពោះរាល់សកម្មភាពនៃអំពើហិង្សាផ្អែកលើយេនឌ័រទាំងអស់ រួមទាំងអំពើហិង្សាក្នុងគ្រួសារ អំពើរំលោភសេពសន្ថវៈនៅក្នុងចំណងអាពាហិពិពាហ៍ ដើម្បីសម្រួលដល់នីតិវិធីក្នុងការទទួលបានដីការការពារ និងដើម្បីធានាថាជនរងគ្រោះ នៃអំពើហិង្សាក្នុងគ្រួសារទទួលបាន ដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ហើយជនល្មើសមានការទទួលខុសត្រូវចំពោះមុខច្បាប់"

៧. គួរចាត់វិធានការនានា ដើម្បីធានាថារាល់ក្របខណ្ឌច្បាប់ត្រូវបានអនុវត្តដោយ ត្រឹមត្រូវនៅគ្រប់ករណីនៃអំពើហិង្សាផ្អែកលើយេនឌ័រ ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដើម្បីធានាថាជនល្មើសមានការទទួលខុសត្រូវចំពោះសកម្មភាពរបស់ពួកគេ ហើយជនរងគ្រោះទទួលបាន យុត្តិធម៌ តាមរយៈការបន្តផ្តល់នូវជំនួយផ្លូវច្បាប់ និងអនុវត្តយុទ្ធនាការអប់រំផ្សព្វផ្សាយសាធារណៈអំពី សេរីភាពជាមូលដ្ឋាននិងសិទ្ធិមនុស្ស ព្រមទាំងផ្តល់ព័ត៌មានទាក់ទងនឹងមធ្យោបាយដាក់ពាក្យបណ្តឹង ក្នុងករណីអំពើហិង្សាផ្លូវភេទនិងអំពើហិង្សាផ្អែកលើ យេនឌ័រ។

៨.គួរសម្របសម្រួល បង្កើនការយល់ដឹងអំពីវប្បធម៌ប្រពៃណីសហគមន៍ជនជាតិ ដើមភាគតិចក្នុងចំណោមអាជ្ញាធរមានសមត្ថកិច្ចដែលមិនមែនជាជនជាតិដើមភាគតិច ដើម្បីបង្កើន លទ្ធភាពរបស់ពួកគេក្នុងការផ្តល់ការគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិចឲ្យកាន់តែប្រសើរ។

**អនុសាសន៍សម្រាប់ដៃគូអភិវឌ្ឍន៍ និងសហគមន៍អន្តរជាតិ**

១. ផ្តល់ការគាំទ្រដល់អង្គការសង្គមស៊ីវិលក្នុងការធ្វើការសិក្សាស្រាវជ្រាវទាក់ទងនឹងអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងស្ត្រីជនជាតិដើមភាគតិច

២.ផ្តល់ការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាលលក្ខណៈទូលំទូលាយ និងផ្តួចផ្តើមគំនិតលើកកំពស់ការយល់ដឹង ដើម្បីដោះស្រាយឬសគល់នៃអំពើហិង្សាផ្អែកលើយេនឌ័រ។

៣.ផ្តល់ការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រមូលទិន្នន័យជាទាងទាត់ និងគ្រប់ជ្រុងជ្រោយស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រ នៅតាមទីភ្នាក់ងាររដ្ឋាភិបាល និងក្រសួងពាក់ព័ន្ធនានា រួមទាំងធ្វើការបំបែក

ទិន្នន័យតាម អាយុ ភេទ និងជាតិពន្ធុ និងបង្កើតផែនការដើម្បីសម្រេចបាននូវទិន្នន័យបំបែកពេញលេញមួយដែលមានរយៈពេល៥ឆ្នាំ។

៤. គាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីទប់ស្កាត់អាពាហ៍ពិពាហ៍កុមារ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើក្រុមកុមាររស់នៅក្នុងសហគមន៍ជនជាតិដើមភាគតិច។ កម្មវិធីអន្តរាគមន៍នានាគួរតែ ផ្តោតការយកចិត្តទុកដាក់ទៅលើទាំងកុមារា និងកុមារី ដើម្បីលើកទឹកចិត្តពួកគេកុំឲ្យរៀបការមុនអាយុ ១៨ឆ្នាំ និងលើកទឹកចិត្តក្មេងស្រីកុំឲ្យមានកូនក្នុងវ័យជំទង់។

៥. គាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើវិសោធនកម្មក្របខណ្ឌច្បាប់ ដើម្បីធានានូវការគោរពតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ។

## ៥.២.២.សកម្មភាពចំបាច់នានាដើម្បីពង្រឹងការឆ្លើយតបចំពោះអំពើហិង្សាផ្អែកលើយេនឌ័រប្រឆាំងស្ត្រីជនជាតិដើមភាគតិច

**<u>អនុសាសន៍ជូនចំពោះរាជរដ្ឋាភិបាលកម្ពុជា</u>**

១. អនុវត្តនូវរាល់អនុសាសន៍របស់គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសអើង ប្រឆាំងនឹងស្ត្រីភេទ ដែលបានធ្វើឡើងនៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់ឆ្នាំ២០១៩។ អនុសាសន៍ទាំងអស់បានផ្តល់ដំណោះស្រាយទៅ លើ ទិដ្ឋភាពផ្សេងៗទាក់ទងនិងស្ត្រី។ អនុសាសន៍ដែលផ្តោតលើលទ្ធភាពទទួលបានយុត្តិធម៌ និងដោះស្រាយ អំពើហិង្សាផ្អែកលើយេនឌ័រ រួមមាន៖

ក) បង្កើតគម្រោងជំនួយផ្នែកច្បាប់គ្រប់ជ្រុងជ្រោយប្រកបដោយស្ថេរភាព និងគាំទ្រមូលនិធិរយៈពេលវែងដោយប្រើប្រាស់ថវិកាជាតិ [...] និងធានានូវលទ្ធភាពទៅតុលាការនិងដំណើរការរឿងក្តីប្រកបដោយប្រសិទ្ធិភាពសម្រាប់ស្ត្រីទាំងអស់ ជាពិសេសស្ត្រីនៅទីជនបទ ស្ត្រីជនជាតិដើមភាគតិច ស្ត្រីក្រុមភាគតិច និងស្ត្រីមានពិការភាព។

ខ) លុបបំបាត់ស្លាកស្នាមមាក់ងាយលើស្ត្រីនិងក្មេងស្រីដែលដាក់ពាក្យបណ្តឹងអំពីករណីរំលោភសិទ្ធិរបស់ពួកគេ តាមរយៈការបង្កើនការយល់ដឹងក្នុងចំណោមសាធារណៈជនអំពីសិទ្ធិមនុស្ស។

គ) ផ្សព្វផ្សាយព័ត៌មានស្តីពីយន្តការនិងនីតិវិធីស្វែងរកដំណោះស្រាយនៅក្នុងករណីអំពើហិង្សាប្រឆាំងស្ត្រី និងក្មេងស្រី ជាពិសេសនៅតាមតំបន់ជនបទ

ឃ) ពង្រឹងដល់ការយល់ដឹងត្រឹមត្រូវអំពីយេនឌ័រ និងការឆ្លើយតបតម្រូវការយេនឌ័រនៅក្នុងប្រព័ន្ធយុត្តិធម៌ រួមបញ្ចូលទាំងការបង្កើតវត្តមានស្ត្រីនៅក្នុងវិស័យយុត្តិធម៌ និងផ្តល់ការពង្រឹងសមត្ថភាពជាលក្ខណៈ ប្រព័ន្ធដល់ចៅក្រម ព្រះរាជអាជ្ញារ មន្ត្រីនគបាល និងមន្ត្រីអនុវត្តច្បាប់ផ្សេងទៀតអំពីអនុសញ្ញាស៊ីដ.វ និងសេចក្តីសន្និដ្ឋានបញ្ចប់ និងយុត្តាធិការដែលមានចែងនៅក្នុងពិធីសារបន្ថែមនិងអនុសាសន៍រួមផ្សេងទៀត

ង) ដាក់ចេញនូវវិធានការជាក់លាក់ដើម្បីពង្រឹងឯករាជ្យភាព និងមិនលំអៀងនៅក្នុងប្រព័ន្ធយុត្តិធម៌ និងដើម្បីធានាថាគ្រប់ករណីនៃអំពើហិង្សាផ្អែកលើយេនឌ័រ និងអំពើហិង្សាប្រឆាំងនិងស្ត្រី រួមទាំងអំពើហិង្សា ក្នុងគ្រួសារ អំពើរំលោភសេពសន្ថវៈ និងអំពើរំលោភសេពសន្ថវៈនៅក្នុងចំណងអាពាហ៍ពិពាហ៍ ត្រូវបាន ស៊ើបអង្កេតយ៉ាងហ្មត់ចត់ ហើយជនល្មើសត្រូវបានផ្តន្ទាទោស ជនរងគ្រោះទទួលបានដំណោះស្រាយ

ច) ពង្រឹងយន្តការប្រយុទ្ធប្រឆាំងនិងអំពើពុករលួយ រយៈការដាកចេញ និងអនុវត្តន៍វិធានការដាក់ពិន័យតឹងរឹង ដើម្បីជម្រុញឲ្យមន្ត្រីសាធារណៈមានការទទួលខុសត្រូវខ្ពស់ និងដើម្បីស្តារឡើងវិញនូវទំនុកចិត្តរបស់ស្ត្រីទៅលើប្រព័ន្ធយុត្តិធម៌។

២. ធានាថាជនរងគ្រោះរស់រានជីវិតពីអំពើហិង្សាផ្អែកលើយេនឌ័រ អាចរកបានរាល់សេវាកម្មពាក់ព័ន្ធផ្សេងៗ រួមទាំងសម្រាប់ ជនរងគ្រោះរស់រានជីវិតដែលជាជនជាតិដើមភាគតិច ដោយគិតគូដល់តម្រូវការ ចាំបាច់នានាដើម្បីដោះស្រាយឧបសគ្គដែលបង្កឡើងដោយភាសា និងវប្បធម៌របស់ជនជាតិដើមភាគតិច ដូចជា៖

ក) ធានាថាសេវាកម្មច្បាប់ សេវាកម្មសុខាភិបាល និងប្រឹក្សាព្យាបាលផ្លូវចិត្ត និងសេវាកម្មផ្សេងទៀត អាចរកបាននៅក្បែរៗតំបន់ដែលជនរងគ្រោះរស់នៅ

ខ) បែងចែកធនធានហិរញ្ញវត្ថុ និងធនធានមនុស្សជាជំហានៗ ដើម្បីធានាដល់ប្រតិបត្តិការនៃសេវាកម្មទាំងនោះ

គ) ធានាថាជនរងគ្រោះរស់រានជីវិតជនជាតិដើមភាគតិច អាចទទួលបានសេវាកម្មទាំងអស់នោះ ដោយប្រើប្រាស់ភាសាដើមជនជាតិភាគតិច

ឃ) ដាក់បញ្ចូលដំណោះស្រាយនៃតម្រូវការរយៈពេលវែងរបសជនរងគ្រោះរស់រានជីវិត ដូចជាការប្រឹក្សា ព្យាបាលផ្លូវចិត្ត និងជំនួយផ្នែកជីវភាព។

៣. ចាត់វិធានការនានា ដើម្បីធានាថា ក្របខណ្ឌច្បាប់ ត្រូវបានអនុវត្តដោយសមរម្យនៅក្នុងគ្រប់ទម្រង់ការចោទប្រកាន់ទាំងឡាយ និងគ្រប់ករណីនៃអំពើហិង្សាផ្អែកលើយេនឌ័រ ស្របជាមួយវិធាន និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដើម្បីធានាឲ្យមានការទទួលខុសត្រូវពីជនល្មើសទាំងនោះ។

៤. បង្កើនកិច្ចសន្ទនាដែលដឹកនាំដោយជនជាតិដើមភាគតិចដើម្បីជម្រុញឲ្យមានការប្រើប្រាស់យន្តការដែលផ្តោតលើអត្ថប្រយោជន៍របស់ជនរងគ្រោះ នៅពេលដែលប្រើប្រាស់យន្តការបែបប្រពៃណីនៅក្នុងករណីនៃអំពើហិង្សាផ្អែកលើយេនឌ័រ

៥. រៀបចំកម្មវិធីបណ្តុះបណ្តាលគ្រប់ជ្រុងជ្រោយ និង ផ្តួចផ្តើមគំនិតលើកកម្ពស់ការយល់ដឹងដល់មន្ត្រីសាធារណៈដើម្បីឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះការចោទប្រកាន់និងករណីអំពើហិង្សាលើយេនឌ័រ ស្របតាមក្របខ័ណ្ឌច្បាប់ជាតិនិងអន្តរជាតិ។

៦. លើកទឹកចិត្តដល់អាជ្ញាធរថ្នាក់ជាតិ និងមូលដ្ឋាន ឲ្យបង្កើនការយល់ដឹងអំពីទំនៀមទម្លាប់ និងវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិចនិងបុគ្គលមិនមែនជនជាតិដើមភាគតិច ដើម្បីទប់ស្កាត់ការធ្វើបុរេវិនិច្ឆ័យ និងការរើសអើង។ កម្មវិធីនេះអាចធ្វើឡើងតាមរយៈការកម្មវិធីផ្លាស់ប្តូរវប្បធម៌ ដំណើរទស្សនៈកិច្ចសិក្សា និងកម្មវិធីបញ្ជ្រាបនៅតាមសហគមន៍

៧. បង្កើនការយល់ដឹងអំពីសិទ្ធិស្ត្រី និងការយល់ដឹងត្រឹមត្រូវអំពីយេនឌ័រ នៅក្នុងសហគមន៍ជនជាតិដើមភាគតិច ជាពិសេសដោះស្រាយបទដ្ឋានសង្គមដែលរើសអើង។ កិច្ចខិតខំប្រឹងប្រែងនេះគួរតែដឹកនាំដោយតំណាងសហគមន៍ជនជាតិដើមភាគតិច។

៨. បង្កើនការសម្របសម្រួលរវាងភ្នាក់ងារពាក់ព័ន្ធដែលទទួលបន្ទុកដោះស្រាយករណីនៃអំពើហិង្សាផ្អែកលើយេនឌ័រ ដើម្បីធានាថាជនរងគ្រោះ រួមទាំងជនជាតិដើមភាគតិចផងដែរ អាចទទួលបានសេវាកម្ម។ ការសម្របសម្រួលរវាងអាជ្ញាធរឃុំ ស្រុក និងខេត្តគួរតែធ្វើឲ្យបានប្រសើរឡើង ដើម្បីធានាថាជនល្មើស ដែលបានរត់គេចខ្លួនពីតំបន់មួយ អាចត្រូវបានចាប់ខ្លួនដោយអាជ្ញាធរនៅតំបន់ផ្សេងដើម្បីនាំខ្លួនមក ផ្តន្ទាទោសនៅតុលាការ។ ការសម្របសម្រួលរវាងអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរខេត្ត គួរតែធ្វើឲ្យល្អប្រសើរដើម្បីសម្រួលដល់លទ្ធភាពទទួលបានព័ត៌មានរបស់ជនរងគ្រោះ ចំពោះសំណុំរឿងដែលកំពុងជាប់គាំង។

៩. បណ្តាញទូរស័ព្ទទាន់ហេតុការណ៍គួរតែមានការដាក់បញ្ចូលភាសាជនជាតិដើមភាគតិច ដើម្បីផ្តល់ភាពងាយស្រួលដល់ស្ត្រីជនជាតិដើមភាគតិចក្នុងការរាយការណ៍ករណីអំពើហិង្សាផ្អែកលើយេនឌ័រ។

**<u>អនុសាសន៍សម្រាប់ដៃគូអភិវឌ្ឍន៍ និងសហគមន៍អន្តរជាតិ</u>**

១. បន្តការគាំទ្រដល់ដៃគូអភិវឌ្ឍន៍ និងសហគមន៍អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែល កំពុងបំពេញបេសកកម្មដើម្បីដោះស្រាយអំពើហិង្សាផ្អែកលើយេនឌ័រ។

២. ផ្តល់ការគាំទ្រដល់បណ្តាអង្គការជនជាតិដើមភាគតិចដែលមានជំហរនិងបេសកកម្មការងារជាក់លាក់ដើម្បីជម្រុញឲ្យមានការផ្លាស់ប្តូរនៅក្នុងសហគមន៍ជនជាតិដើមភាគតិច។

៣. ផ្តល់ការគាំទ្រ និងលើកទឹកចិត្តដល់បណ្តាអង្គការ សមាគម នានាដែលកំពុងផ្តល់សេវាប្រឹក្សាផ្នែកចិត្តវិទ្យាសង្គម ដើម្បីនាំយកសេវាកម្មរបស់ពួកគេទៅដល់ស្ត្រីជនជាតិដើមភាគតិច។

៤ ផ្តល់ការគាំទ្រដល់រាជរដ្ឋាភិបាលដើម្បី៖

ក) បង្កើនការបែងចែកធនធានហិរញ្ញវត្ថុនិងធនធានមនុស្ស ដើម្បីផ្តល់សេវាកម្មពាក់ព័ន្ធដល់ជនរងគ្រោះនៃអំពើហិង្សាផ្អែកលើយេនឌ័រ និងធានាថាសេវាកម្មទាំងអស់នោះអាចរកបាន។

ខ) ពង្រឹងការសម្របសម្រួលរវាងអាជ្ញាធរពាក់ព័ន្ធដែលទទួលបន្ទុកដោះស្រាយករណីនៃអំពើហិង្សាផ្អែកលើយេនឌ័រ ដើម្បីសម្រួលដល់ជនរងគ្រោះក្នុងការទទួលបានសេវាកម្ម និងជនល្មើសត្រូវបាននាំខ្លួនមកផ្តន្ទាទោស

គ) ធានាថាអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានមានការយល់ដឹងអំពីទំនៀមទម្លាប់ និងវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិច និងចាត់វិធានការនានាដើម្បីពង្រឹងការយល់ដឹងរវាងបុគ្គលដែលមិនមែនជនជាតិដើមភាគតិច និងសហគមន៍ជនជាតិភាគតិច ដើម្បីទប់ស្កាត់ការធ្វើបុរេវិនិច្ឆ័យ និងការរើសអើង។

ឃ) ដាក់បញ្ចូលភាសាជនជាតិដើមភាគតិចនៅក្នុងបណ្តាញទូរស័ព្ទទាន់ហេតុការណ៍ ដើម្បីផ្តល់ភាពងាយស្រួលដល់ស្ត្រីជនជាតិដើមភាគតិចក្នុងការរាយការណ៍ករណីអំពើហិង្សាផ្អែកលើយេនឌ័រ។